**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# តួនាទីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងវិស័យធនាគារ

ស្រាវជ្រាវពីថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០១៧

ឈ្មោះស្ថាប័ន៖ **ធនាគារជាតិនៃកម្ពុជា**

តាក់តែងឡើងដោយ

និស្សិតឈ្មោះ ៖ **ស៊ាម គន**

សាស្ត្រាចារ្យណែនាំ

លោក **ជា សែម**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និង ហិរញ្ញវត្ថុ

ជំនាក់ទី ១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាប័ត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុនៃសាកល វិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមលំអោនកាយគោរពនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក អ្នកម្តាយ ដែលបានចិញ្ចឹមបីបាច់ថែរក្សានិងផ្តល់នូវសេចក្តីស្រលាញ់ មេត្តាករុណាអប់រំទូន្មាន អោយមានសេចក្តីព្យាយាមអំណត់ក្លាហាន ព្រមទាំងបាន ធ្វើពលិកម្ម គ្រប់ បែបយ៉ាង ដល់កូន រួចបានបញ្ជូនកូនអោយមកបញ្ចប់ការសិក្សាដោយ ទទួលបាននូវចំណេះដឹងថ្លៃថ្លារហូតដល់ ចប់ចុងចប់ដើម។ កូនសូមក្រាបប្រណិបត្តិនិងសូមសំដែងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះអ្នកមានគុណទាំងពីរដែលមានចំពោះកូន។

ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យា ធិការរង លោក លោកស្រីព្រឹទ្ធបុរស លោក លោកស្រីអនុប្រធានការិយាល័យ លោក លោកស្រី ប្រធានដេប៉ាតឺមង់ លោក លោកស្រីអនុប្រធានដេប៉ាតឺមង់ ព្រមទាំងបុគ្គលិក សាស្រ្តាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានខិតខំប្រឹងប្រែងអស់ពី សមត្ថភាពទាំងកំលាំងកាយ កំលាំងចិត្ត និងកំលាំងប្រាជ្ញាក្នុងការពិនិត្យ កែតម្រូវ និងវាយតម្លៃសារណាបញ្ចប់ការសិក្សានេះអោយកាន់តែទទួលបាននូវលទ្ធផលល្អបន្ថែមទៀត។

ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកសាស្រ្តចារ្យ ជា សែម ដែលបានដឹកនាំក្រុមខ្ញុំបាទ ដោយផ្តល់នូវវិធីសាស្រ្តក្នុងការចុះស្រាវជ្រាវ និងប្រមូលព័ត៌មានយកមកចងក្រងទើបសរសេរបានជារបាយការណ៍សារណាមួយច្បាប់នេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមថ្លែងប្រសិទ្ធពរ សិរីបវរ ឯកឧត្តម លោកជំទាវ លោកលោកស្រី អ្នកនាងកញ្ញា ជួបប្រទះនូវពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងរយៈពេលបួនឆ្នាំមកនេះ ខ្ញុំបាទបានទទួលនូវចំណេះដឹងយ៉ាងច្រើន ហើយក៏ទទួលបានឱកាសក្នុងការចងក្រងនូវរបាយការណ៍ស្រាវជ្រាវនេះឡើង។ ប្រធានបទនៃរបាយការណ៍នេះ ផ្តើមចេញពីទស្សនៈវិស័យផ្ទាល់ខ្លួនទៅលើវិស័យធនាគារនៅប្រទេសកម្ពុជា។ យើងសង្កេត ឃើញថា វិស័យធនាគារគឺជាវិស័យមួយដ៏ចម្បងក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ សេដ្ឋកិច្ចរបស់កម្ពុជា។ បច្ចុប្បន្ននេះប្រជាជនកម្ពុជាមានការយល់ដឹងកាន់តែប្រសើរឡើងអំពី ការប្រើប្រាស់សេវាកម្មរបស់ធនាគារដើម្បីជា មធ្យោបាយក្នុងការទូទាត់ កម្ចីប្រាក់ បញ្ញើប្រាក់ និង ដំណាក់ប្រាក់ ជាពិសេសវិស័យធនាគារអាចជម្រុញអោយសាច់ប្រាក់របស់ពួកគេមានចលនា។ ចំពោះធនាគារខ្លួនឯងវិញក៏នៅបន្តខិតខំពង្រឹងនិងពង្រីកនូវផលិតផល និង សេវាកម្មរបស់ខ្លួន បន្ថែមទៀតដើម្បីបំពេញតម្រូវការនិងសម្រួលដល់អតិថិជន។ លើសពីនេះទៅទៀត គេបានសង្កេត ឃើញថា កំណើននៃធានាគារមានជាលំដាប់ពិសេសនៅឆ្នាំ ២០០៨។ ហេតុផលនេះហើយ ធនាគារជាតិនៃកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ និងផ្តល់ជាជំនួយទៅដល់ វិស័យធនាគារនិងហិរញ្ញវត្ថុនិងធ្វើយ៉ាងណាអោយមានទំនុកចិត្តលើប្រព័ន្ធធនាគារ អំពីសំណាក់ ប្រជាជន។

ដោយមានការពិគ្រោះយោបល់ជាមួយសាស្រ្តាចារ្យណែនាំ ហើយគាត់ក៏បានផ្តល់យោបល់អំពីកិច្ចការស្រាវជ្រាវដែលទាក់ទងទៅនឹងរបាយការណ៍នេះ ខ្ញុំបាទសម្រេចជ្រើសរើស សរសេររបាយណ៍ដែលទាក់ទងទៅនឹងប្រធានបទ "តួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងវិស័យហិរញ្ញវត្ថុ" ដែលមានសេចក្តីសង្ឃឹមថាការស្រាវជ្រាវនេះនឹងផ្តល់ជាប្រយោជន៍ដល់អ្នកអាន និង អ្នកសិក្សាអោយកាន់តែយល់បន្ថែមទៀតអំពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការត្រួត ពិនិត្យទៅលើភាពប្រក្រតីនៃការអនុវត្តច្បាប់ បទបញ្ញត្តិផ្សេងៗនិងមានចំណាត់កាកែរតម្រូវ បន្ថែមនៅក្នុងវិស័យហិរញ្ញវត្ថុ។

ដោយការសិក្សាមានលក្ខណៈទូលំទូលាយនិងពេលវេលាមានកាលកំណត់ ខ្ញុំបាទជឿជាក់ថាការស្រាវជ្រាវនេះពិតជាមានកង្វះខាត មិនបានល្អិតល្អន់គ្រប់ជ្រុងជ្រោយឡើយ បើទោះបីជា ខ្ញុំបាទបានខិតខំប្រឹងប្រែងអោយអស់លទ្ធភាពក្នុងការសរសេរនិងកែតម្រូវជាច្រើនលើកហើយ ក៏ដោយ។ ដូច្នេះ ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយក្នុងការទទួលយកនូវការរិះគុណនិងការកែតម្រូវបន្ថែមពីសំណាក់សាស្រ្តាចារ្យ និង មិត្តអ្នកអានទាំងអស់គ្នា។

# មាតិកា


បញ្ជីអក្សរកាត់.......................................................................................vi
បញ្ជីតារាង .........................................................................................vii
វាក្យស័ព្ទធនាគារ..................................................................................viii
បញ្ជីឧបសម្ព័ន្ធ.......................................................................................xi


## សេចក្ដីផ្ដើម


១. លំនាំដើម........................................................................................ ១
២. ចំណោទបញ្ហា ....................................................................................២
៣. កម្មវត្ថុនៃការស្រាវជ្រាវ...........................................................................២
៤. សារៈសំខាន់នៃការស្រាវជ្រាវ......................................................................២
៥. ទំហំនិងវិសាលភាពនៃការស្រាវជ្រាវ ..............................................................៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ...........................................................................៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................................................៣


## ជំពូក ១
## ទិដ្ឋភាពរបស់ធនាគារជាតិនៃកម្ពុជា


១.១.ប្រវត្តិរបស់ធនាគារជាតិ ......................................................................... ៥
១.២. ការគ្រប់គ្រងនិងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា .........................................៧
១.២.១. រចនាសម្ព័ន្ធនិងមុខងារនាយកដ្ឋានស្រាវជ្រាវនិងសហប្រតិបត្តិការអន្តរជាតិ ...... ៨
១.២.២. រចនាសម្ព័ន្ធនិងមុខងាររបស់នាយកដ្ឋានស្ថិតិ ........................................ ៨
១.៣. ផ្លាកសញ្ញារបស់ធនាគារជាតិនៃកម្ពុជា ......................................................... ៩
១.៤. ទីតាំង និង សាខារបស់ធនាគារជាតិនៃកម្ពុជា...................................................១០
១.៤.១. ទីស្នាក់ការ......................................................................................១០
១.៤.២. សាខារបស់ធនាគារជាតិនៃកម្ពុជា ...........................................................១០
១.៥. គោលនយោបាយកាតព្វកិច្ចប្រាក់បម្រុងរបស់ធនាគារកណ្ដាល.......................................១០
១.៥.១. ការឆ្លើយតបទៅនិងកាតព្វកិច្ចប្រាក់បម្រុង ....................................................១០
១.៥.២. ការកំណត់នូវប្រភេទខុសៗគ្នានៃប្រាក់បម្រុងនិងរូបិយវត្ថុ.......................................១១
១.៥.៣. ការតម្រូវអោយមានកាតព្វកិច្ចប្រាក់បម្រុង........................................................១១

១.៥.៤. ឥទ្ធិពលនៃការប្រែប្រួលប្រាក់បម្រុងកាតព្វកិច្ច ..................................................១១
១.៦. សេវាកម្មរបស់ធនាគារជាតិនៃកម្ពុជា.............................................................................. ១២
១.៦ .១.ការគ្រប់គ្រងគណនី .................................................................................................. ១២
១.៦.១. ១. ការចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ .......... ១២
១.៦.១.២. សេវាប្រាក់បញ្ញើ ...............................................................................................១៣
១.៦.២. សេវាកម្មផ្ទេរប្រូបិយវត្ថុ........................................................................................................១៤
១.៦.២.១.សេវាកម្មវេលុយក្នុងស្រុក ................................................................................១៤
១.៦.២.២.សេវាកម្មវេលុយក្រៅស្រុក................................................................................១៥
១.៦.៣. សកម្មភាពអង្គភាពទូទាត់....................................................................................................១៥
១.៦.៣.១. ការទូទាត់មូលបត្រប្រាក់រៀល ..........................................................................១៥
១.៦.៣.២. ការជាត់ទាត់បញ្ញាឥណទាន ............................................................................១៦
១.៦.៤. ប្រព័ន្ធទូទាត់ .......................................................................................................................១៦
១.៦.៥. សេវាកម្មឥណទាន...............................................................................................................១៨
១.៦.៦. ការអនុវត្តនៃកម្ចីជំនួយឥតសំណង ...................................................................................១៨
១.៦.៦.១. ហិរញ្ញប្បទានឥតសំណងក្នុងគម្រោង..................................................................១៨
១.៦.៦.២. កម្ចីសម្បទានបរទេស .......................................................................................១៩
១.៦.៧. ការគ្រប់គ្រងចរាចរណ៍ធនបត្រ............................................................................................១៩
១.៦.៧.១. សកម្មភាពបេឡាប្រតិបត្តិការ ............................................................................១៩
១.៦.៧.២. ការគ្រប់គ្រងគម្រោងសាច់ប្រាក់ ...................................................................... ២០

# **ជំពូក ២**

# **រំលឹកទ្រឹស្តី**

២.១. និយមន័យធនាគារជាតិ ..................................................................................................... ២២
២.២. លក្ខណៈពិសេសរបស់ធនាគារកណ្តាល................................................................................... ២២
២.៣. មូលហេតុដែលនាំអោយមានការត្រួតពិនិត្យទៅលើធនគារពាណិជ្ជ..............................២៣
២.៤. ធនាគារពាណិជ្ជ.................................................................................................................. ២៤
២.៤.១. ការវិវត្តរបស់ធនាគារពាណិជ្ជ................................................................................................ ២៤
២.៤.២. តួនាទីរបស់ធនាគារពាណិជ្ជ ................................................................................................ ២៥
២.៤.២.១. អន្តរការិយកម្ម........................................................................................................ ២៥

២.៤.២.២. តួនាទីទូទាត់ .......... ២៦
២.៤.២.៣. តួនាទីឥណទាន .......... ២៦
២.៤.២.៤. តួនាទីចែករំលែងហានិភ័យ .......... ២៦
២.៤.២.៥. តួនាទីផ្តល់ដំបូន្មានសម្រាប់ការវិនិយោគ ឬ សន្សំ .......... ២៦
២.៤.២.៦. តួនាទីក្នុងនយោបាយរបស់រដ្ឋាភិបាល .......... ២៦
២.៥.៣. ហានិភ័យសំខាន់ៗក្នុងវិស័យធនាគារ .......... ២៦
២.៥.៣.១. ហានិភ័យឥណទាន .......... ២៦
២.៥.៣.២. ហានិភ័យសាច់ប្រាក់ងាយស្រួល .......... ២៧
២.៥.៣.៣. ហានិភ័យអត្រាការប្រាក់ .......... ២៧
២.៥.៣.៤. ហានិភ័យសោធនភាព .......... ២៧
២.៥.៣.៥. ហានិភ័យទីផ្សារ .......... ២៧
២.៥.៣.៦. ហានិភ័យអត្រាប្តូរប្រាក់ .......... ២៨
២.៥.៣.៧. ហានិភ័យប្រតិបត្តិការ .......... ២៨

## ជំពូក ៣
## ការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា

៣.១. ការអនុវត្តនិងការដឹកនាំគោលនយោបាយរូបិយវត្ថុ .......... ២៩
៣.២. គោលដៅនៃគោលនយោបាយរូបិយវត្ថុ .......... ២៩
៣.២.១.ស្ថិរភាពថ្លៃ .......... ២៩
៣.២.២. ស្ថិរភាពនៃអត្រាការប្រាក់ .......... ២៩
៣.២.៣. ស្ថិរភាពនៃអត្រាប្តូរប្រាក់ .......... ៣០
៣.២.៤. ត្រួតពិនិត្យកំណើនបរិមាណរូបិយវត្ថុ .......... ៣០
៣.២.៥.ស្ថិរភាពនៃទីផ្សារហិរញ្ញវត្ថុ .......... ៣០
៣.៣.ឧបករណ៍គោលនយោបាយរូបិយវត្ថុ .......... ៣០
៣.៣.១. ប្រតិបត្តិការទីផ្សារចំហរ .......... ៣១
៣.៣.២. អត្រាអប្បហារ (Discounted rate) .......... ៣១
៣.៣.៣. ប្រាក់បម្រុងកាតព្វកិច្ច (Reserve requirement) .......... ៣២
៣.៤. ស្ថានភាពថ្លៃនិងប្រាក់រៀល .......... ៣៣

៣.៤.១. ការវិវត្តិថ្លៃទំនិញ និង អតិផរណា ............ ៣៣
៣.៤.២. ស្ថានភាពអត្រាប្តូរប្រាក់ ............ ៣៣
៣.៤.២.១. ស្ថានភាពប្រាក់រៀលធៀបនិងដុល្លាអាមេរិច ............ ៣៣
៣.៤.២.២. ស្ថានភាពប្រាក់រៀលធៀបនិងរូបិយវត្ថុមួយចំនួន ............ ៣៤

## ជំពូក ៤

## តួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងវិស័យហិរញ្ញវត្ថុ

៤.១. តួនាទីនិង ភារៈកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ............ ៣៦
៤.១.១. ធនាគារិករបស់រដ្ឋ ............ ៣៦
៤.១.២. ធនាគារិកសម្រាប់ធនាគារពាណិជ្ជ ............ ៣៦
៤.១.៣. កំណត់គោលនយោបាយរូបិយវត្ថុ ............ ៣៦
៤.១.៤. ត្រួតពិនិត្យប្រព័ន្ធហិរញ្ញវត្ថុ ............ ៣៧
៤.១.៥. ត្រិះរិះរកការអនុវត្ត និងត្រួតពិនិត្យនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ ............ ៣៧
៤.១.៦. ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រក្រតី ............ ៣៨
៤.១.៧. ផ្តល់(ដកហូត) អាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ............ ៣៩
៤.១.៨. ពិនិត្យប្រព័ន្ធទូទាត់ក្នុងប្រទេសនិងកែលម្អប្រសិទ្ធភាពទូទាត់អន្តរធនាគារ ............ ៣៩
៤.១.៩. ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុ ............ ៣៩
៤.១.១០.ទទួលខុសត្រូវនិងអនុវត្តផែនការដែលជាលទ្ធផលនៃការចូលរួមជាមួយស្ថាប័ន អន្តរជាតិសាធារណៈក្នុងកិច្ចការធនាគារ ឥណទាន រូបិយវត្ថុ ............ ៣៩
៤.១.១១. តម្លើងតារាងជញ្ជីងទូទាត់ ............ ៣៩
៤.១.១២. ចូលរួមក្នុងការគ្រប់គ្រងបំណុលនិងឥណទេយ្យជាមួយប្រទេសក្រៅ ............ ៣៩
៤.១.១៣. ចូលរួមបង្កើតនិងត្រួតពិនិត្យទីផ្សាររូបិយវត្ថុនិងទីផ្សារហិរញ្ញវត្ថុ ............ ៤០
៤.១.១៤. ផ្តល់និងដកហូតអាជ្ញាប័ណ្ណចំពោះអាជីវកម្មប្តូរប្រាក់ សង្ហារឹម ត្បូងថ្ម ............ ៤០
៤.១.១៥. កំណត់អត្រាការប្រាក់ ............ ៤០
៤.២. ប្រតិបត្តិការរបស់ធនាគារកណ្តាល ............ ៤០
៤.២.១. ប្រតិបត្តិការប្រាក់បញ្ញើរ ............ ៤០
៤.២.២.ផ្នែកឥណទានចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ............ ៤១
៤.២.៣. ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ............ ៤១

៤.២.៣.១. ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ....................................៤១
៤.២.៣.២. ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស .................................. ៤២
៤.២.៣.៣. ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ......................... ៤២
៤.២.៣.៤. ការផ្តល់អាជ្ញាប័ណ្ណចំពោះអាជីវកម្មប្តូរប្រាក់...................................៤៣
៤.២.៣.៥. ផ្តល់អាជ្ញាប័ណ្ណចំពោះអាជីវកម្មនាំចូលនិងនាចេញលោហធាតុ.......៤៤
៤.៣. អគ្គនាយកដ្ឋានត្រួតពិនិត្យ..................................................................................៤៤
៤.៣.១. ការគ្រប់គ្រង ...........................................................................................៤៤
៤.៣.២. មុខងារនិងភារកិច្ច ...................................................................................៤៤
៤.៣.៣. នាយកដ្ឋានក្រោមឱវាទ..................................................................................៤៤
៤.៣.៣.១. នាយកដ្ឋានត្រួតពិនិត្យឯកសារ.....................................................៤៥
៤.៣.៣.២. នាយកដ្ឋានត្រួតពិនិត្យដល់ទីកន្លែង................................................៤៥
៤.៣.៣.៣. នាយកដ្ឋានផ្តល់អាជ្ញាប័ណ្ណ .........................................................៤៥
៤.៣.៣.៤. នាយកដ្ឋាននីតិកម្ម......................................................................៤៦

**សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍**

១. សេចក្តីសន្និដ្ឋាន ...........................................................................................៤៧
២. ការផ្តល់អនុសាសន៍..........................................................................................៤៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | : Asia Development Bank |
| NBC | : National Bank of Cambodia |
| WB | : World Bank |
| IMF | : International Monetary Fund |
| MIF | : Micro Finance |
| C | : Currency |
| USD | : United State Dollar |
| KHR | : Khmer Riel |
| ATM | : Automated Teller Machine |
| NEER | : Nominal Effectiveness Exchange Rate |
| REER | : Real Effectiveness Exchange Rate |

# បញ្ជីតារាង

តារាងទី១៖ ក្រាហ្វិកបង្ហាញពីចំនួនគណនីនៅឆ្នាំ២០១៤-២០១៥ ......................................... ១២
តារាងទី២៖ បង្ហាញពីប្រាក់បញ្ញើស្ថាប័នរដ្ឋ និង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ........................១៤
តារាងទី៣៖ ក្រាហ្វិក បង្ហាញពីការវេលុយក្នុងស្រុករបស់ធនាគារជាតិនៃកម្ពុជា .......................១៤
តារាងទី៤៖ ក្រាហ្វិកបង្ហាញ ពីចំនួនមូលបត្រគិតជារៀល និង ដុល្លា ពីឆ្នាំ ២០១២-២០១៥ .......១៥
តារាងទី៥៖ ក្រាហ្វិកបង្ហាញចំនួនប្រតិបត្តិការបញ្ជាផ្ទេរឥណទាននៅឆ្នាំ ២០១៤-២០១៥១៦ .....១៦
តារាងទី៦៖ ក្រាហ្វិកបង្ហាញទំហំឥណទានស្នើសុំ ................................................................. ១៧
តារាងទី៧៖ ក្រាហ្វិកបង្ហាញ ការងារការគ្រប់គ្រងសាច់ប្រាក់រៀល ....................................... ២០

# វាក្យស័ព្ទធនាគារ

- **ធនាគារអភិវឌ្ឍន៍អាស៊ី ADB ៖** មានទីស្នាក់ការនៅទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន ហើយបានបង្កើតឡើងតាំងពីឆ្នាំ១៩៦៦ ដើម្បីជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងសំដៅទៅកាត់បន្ថយភាពក្រីក្រនៅតំបន់អាស៊ីនិងប៉ាស៊ីហ្វិក តាមរយៈការផ្តល់ឥណទាន ជំនួយឥតសំណងការស្រាវជ្រាវសេដ្ឋកិច្ច ជំនួយផ្នែកគោលនយោបាយ និងបច្ចេកទេស ។
- **ជញ្ជីងទូទាត់៖** របាយការណ៍ស្ថិតិសង្ខេប ដែលកត់ត្រាប្រតិបត្តិការទូទាត់រវាងនិវេសជននិងអនិវេសជន នៅក្នុងពេលវេលាជាក់លាក់មួយ។ ជញ្ជីងទូទាត់រួមមាន គណនីចរន្ត គណនីមូលធន និង គណនីហិរញ្ញវត្ថុ។
- **រូបិយវត្ថុទូទៅ ៖** គឺជាការរួមបញ្ចូលនៃរូបិយវត្ថុដែលកាន់កាប់ដោយសាធារណជន និងប្រាក់បញ្ញើដែលសាធារណជនដាក់ផ្ញើនៅធនាគារពាណិជ្ជ។
- **ធនាគារកណ្តាល ៖** គឺស្ថាប័នជាតិមួយទទួលខុសត្រូវចំពោះការត្រួតពិនិត្យប្រព័ន្ធរូបិយវត្ថុជាតិ។ ធនាគារកណ្តាលមានទំនួលខុសត្រូវខ្ពស់ក្នុងការត្រួតពិនិត្យមើលលើគោលនយោបាយរូបិយវត្ថុដើម្បីអនុវត្តឲ្យបាននូវគោលដៅជាក់លាក់មួយដូចជា ស្ថិរភាពរូបិយវត្ថុ អតិផរណាទាប និងការងារពេញលេញ។ តួនាទីរបស់ធនាគារកណ្តាលជាទូទៅគឺ បោះពុម្ពលុយ បទប្បញ្ញត្តប្រព័ន្ធឥណទាន ត្រួតពិនិត្យធនាគារពាណិជ្ជ គ្រប់គ្រងទុនបម្រុងអន្តរជាតិនិងដើរតួជាអ្នកឲ្យខ្ចីចុងក្រោយ។
- **មូលប្បទានបត្រ ៖** មូលប្បទានបត្រគឺជាការបញ្ជាជាលាយលក្ខណ៍អក្សរដោយឥតលក្ខខ័ណ្ឌទៅកាន់ធនាគារិក ហើយចុះហត្ថលេខាដោយបុគ្គលដែលចេញបញ្ជា ដែលតម្រូវឱ្យធនាគារិកនោះផ្តល់ប្រាក់ក្នុងចំនួនកំណត់ណាមួយដល់បុគ្គលណាម្នាក់ ឬដល់អ្នកកាន់មូលប្បទានបត្រនោះ។ មូលប្បទានបត្រត្រូវតែអាចទូទាត់បាន និងស្របតាមច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់។
- **អត្រាប្តូរប្រាក់៖** អត្រាប្តូរប្រាក់គឺជាតម្លៃរូបិយវត្ថុរបស់ប្រទេសមួយធៀបនឹងរូបិយប័ណ្ណរបស់ប្រទេសដទៃទៀត។ អត្រាប្តូរប្រាក់ អាចមានន័យដូចខាងក្រោម ៖
  - នៅក្នុងន័យផ្ទាល់ ៖ តម្លៃក្នុងមួយឯកតារូបិយប័ណ្ណបរទេសគិតជារូបិយវត្ថុក្នុងស្រុក ។
  - នៅក្នុងន័យប្រយោល ៖តម្លៃក្នុងមួយឯកតានៃរូបិយវត្ថុក្នុងស្រុកគិតជារូបិយប័ណ្ណបរទេស
- **អតិផរណា ៖** ជាការកើនឡើងកម្រិតថ្លៃជាទូទៅនៃទំនិញនិងសេវាក្នុងសេដ្ឋកិច្ច។ អតិផរណាត្រូវបានគណនាជាភាគរយ និង វាស់វែងកំណើនជា ខែ ត្រីមាស និង ឆ្នាំ ។
- **ទីផ្សាររូបិយវត្ថុអន្តរធនាគារ ៖** ទីផ្សារមួយដែលធនាគារផ្តល់និងខ្ចីពីគ្នាទៅវិញទៅមក ។
- **អត្រាការប្រាក់៖** គឺ ជាអត្រាដែលការប្រាក់ត្រូវបានបង់ដោយដោយ (កូនបំណុល) សម្រាប់ការសងប្រាក់និងការជួលប្រាក់ទៅអោយម្ចាស់បំណុលវិញ។

- **មូលនិធិរូបិយវត្ថុអន្តរជាតិ** ៖ អង្គការអន្តរជាតិ ដែលបានបង្កើតឡើងនៅឆ្នាំ១៩៤៥ ក្នុងគោលបំណងលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុអន្តរជាតិ និងសហប្រតិបត្តិការរូបិយវត្ថុ ជួយសម្របសម្រួលពាណិជ្ជកម្មអន្តរជាតិ និងជំរុញអនិកម្មភាព កំណើនសេដ្ឋកិច្ចប្រកមដោយចីរភាព និងកាត់បន្ថយភាពក្រីក្រក្នុងពិភពលោក ។
- **អ្នកឱ្យខ្ចីចុងក្រោយ** ៖ មុខងាររបស់ធនាគារកណ្តាលក្នុងការផ្តល់ឥណទានដល់ធនាគារ ដើម្បីដោះស្រាយបញ្ហាសន្ទនីយភាពដែលបណ្តាលមកពីភាពខុសគ្នានៃមូលនិធិ និងដើម្បីទប់ស្កាត់វិបត្តិស្រាច់ប្រាក់ងាយស្រួល។
- **សន្ទនីយភាព** ៖ កម្រិតដែលទ្រព្យសកម្ម ឬសញ្ញាប័ណ្ណ អាចត្រូវបានទិញ ឬលក់នៅក្នុងទីផ្សារដោយពុំមានការប៉ះពាល់ដល់តម្លៃទ្រព្យសកម្មនោះ។ ទ្រព្យសកម្មដែលមានភាពងាយស្រួលក្នុងការទិញនិងលក់ អាចចាត់ទុកជាទ្រព្យសកម្មដែលមានសន្ទនីយភាព។ សន្ទនីយភាពឆ្លុះបញ្ចាំងពីសមត្ថភាព ក្នុងការបម្លែងទ្រព្យសកម្មមួយឱ្យទៅជាសាច់ប្រាក់។
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** ៖ គ្រឹះស្ថាន មានឯកទេសក្នុងការផ្តល់សេវាហិរញ្ញវត្ថុដូចជាផ្តល់កម្ចីនិងទទួលប្រាក់បញ្ញើរ សម្រាប់ក្រុមឬបុគ្គលក្រីក្រនិងមានចំណូលទាប និងសហគ្រាសធន់តូច។
- **គោលនយោបាយរូបិយវត្ថុ** ៖ មធ្យោបាយដែលអាជ្ញាធររូបិយវត្ថុរបស់ប្រទេសមួយគ្រប់គ្រងលើការផ្គត់ផ្គង់រូបិយវត្ថុ ក្នុងគោលបំណងកំណត់អត្រាអតិផរណា ឬអត្រាការប្រាក់ ដើម្បីធានាបាននូវស្ថិរភាពថ្លៃ និងការជឿជាក់លើរូបិយវត្ថុជាតិ។ គោលដៅនៃគោលនយោបាយនេះគឺរួមចំណែកដល់ ស្ថិរភាពនិងកំណើនសេដ្ឋកិច្ច បន្ថយអត្រានិកម្មភាព និងព្យាករអត្រាប្តូរប្រាក់ជាមួយរូបិយប័ណ្ណផ្សេងៗទៀត។
- **មូលបត្រអាចជួញដូរបាន** ៖ បំណុលមានការប្រាក់រយៈពេលខ្លី ដែលបោះផ្សាយដោយធនាគារកណ្តាលត្រូវបានកំណត់ជាប្រាក់រៀលនិងដុល្លារអាមេរិកក្នុងតម្លៃប្រមាណ២០០០លានរៀល។
- **គណៈកម្មការ អត្រាប្តូរប្រាក់ផ្លូវការ** ៖ អត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជាត្រូវបានកំណត់ដោយគណៈកម្មការ អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ដែលមានសមាជិកមកពីនាយកដ្ឋានពាក់ព័ន្ធដូចជា នាយកដ្ឋានបោះផ្សាយ នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ នាយកដ្ឋានស្ថិតិ និងនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ។
- **ប័ណ្ណទូទាត់** ៖ ប័ណ្ណដែលរួមមានប័ណ្ណជាច្រើនប្រភេទអាចប្រើប្រាស់ដោយម្ចាស់ប័ណ្ណសម្រាប់ការទូទាត់។ ប័ណ្ណទូទាត់មានចំនួន ៤ ប្រភេទគឺ ប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ ប័ណ្ណដកនិងដាក់ប្រាក់តាមម៉ាស៊ីនស្វ័យប្រវត្ត និងប័ណ្ណបង់ប្រាក់ជាមុន ។
- **ប្រព័ន្ធទូទាត់** ៖ ផ្អែកតាមនិយមន័យរបស់ធនាគារទូទាត់អន្តរជាតិ ប្រព័ន្ធទូទាត់រាប់បញ្ចូលនូវឧបករណ៍នីតិវិធីធនាគារ និងជាពិសេសប្រព័ន្ធផ្ទេរមូលនិធិអន្តរធនាគារ ដែលធានាឲ្យមានចរាចរណ៍សាច់ប្រាក់។ ជាទូទៅប្រព័ន្ធទូទាត់ត្រូវបានស្គាល់ថាជាមធ្យោបាយមួយ ដែលមូលនិធិត្រូវបានផ្ទេរដោយអ្នកចូលរួមក្នុងប្រព័ន្ធនោះ ។

- **ប្រកាស** ៖ បទប្បញ្ញត្តិដែលបានដាក់ចេញដោយរដ្ឋមន្ត្រី ឬទេសាភិបាលធនាគារកណ្តាល ដែលត្រូវអនុលោមទៅតាមច្បាប់និងអនុក្រឹត្យ។
- **ស្ថិរភាពថ្លៃ** ៖ ស្ថានភាពមួយដែលថ្លៃនៅក្នុងសេដ្ឋកិច្ចមួយមិនមានការប្រែប្រួលខ្លាំងក្នុងរយៈពេលណាមួយ។ ស្ថិរភាពថ្លៃអាចមានន័យថាសេដ្ឋកិច្ចមិនជួបប្រទះអតិផរណាឬបរិត្តផរណាខ្ពស់ ។
- **ប្រាក់បម្រុងកាតព្វកិច្ច** ៖ ចំនួននៃប្រាក់បញ្ញើ ដែលធនាគារពាណិជ្ជត្រូវរក្សាទុកក្នុងទម្រង់ជាសាច់ប្រាក់សុទ្ធ ឬបញ្ញើជាមួយធនាគារកណ្តាល។ ធនាគារកណ្តាលគឺជានិយ័តករដែលអាចកំណត់ប្រាក់បម្រុងកាតព្វកិច្ច។ ធនាគារកណ្តាលប្រើប្រាស់ប្រាក់បម្រុងកាតព្វកិច្ចជាមធ្យោបាយសម្រាប់គ្រប់គ្រងសន្ទនីយភាពក្នុងទីផ្សារ។ ប្រាក់បម្រុងកាតព្វកិច្ចទាបអនុញ្ញាតិឲ្យមានសន្ទនីយភាពខ្ពស់ក្នុងប្រព័ន្ធធនាគារ។ ប្រាក់បម្រុងកាតព្វកិច្ចខ្ពស់ ធ្វើឲ្យមានសន្ទនីយភាពទាប ។
- **រៀល** ៖ រូបិយវត្ថុជាតិនៃប្រទេសកម្ពុជា។
- **ក្រុមធនាគារពិភពលោក** ៖ អង្គការអន្តរជាតិចំនួន៥ដែលចូលរួមក្នុងការផ្តល់ហិរញ្ញប្បទាន ក្នុងអត្រាការប្រាក់ទាប និងផ្តល់អនុសាសន៍ដល់ប្រទេសដែលកំពុងប្រឈមមុខនឹងភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច តាមរយៈការជួយជ្រោមជ្រែងប្រទេសទាំងនោះលើវិស័យមួយចំនួនដូចជា វិស័យសុខាភិបាល អប់រំ និង កសិកម្ម។

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី ១ : រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារជាតិ

ឧបសម្ព័ន្ធទី ២ : ផ្លាកសញ្ញារបស់ធនាគារជាតិនៃកម្ពុជា

ឧបសម្ព័ន្ធទី ៣ : តារាងសមាសភាពដឹងនាំធនាគារជាតិនៃកម្ពុជា

ឧបសម្ព័ន្ធទី ៤ :ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតដល់អាជីវកម្មប្តូរប្រាក់

ឧបសម្ព័ន្ធទី ៥ :ប្រកាសស្តីពីប្រកាសស្តីពីលក្ខខណ្ឌតិកសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី៦ :ប្រកាសស្តីពីការកំណត់ជាថ្មីនៃដើមទុនចុះបញ្ជីនិងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ

ឧបសម្ព័ន្ធទី ៧ : ប្រកាសស្តីពីការចុះបញ្ជីរបស់មីក្រូហិរញ្ញវត្ថុនិងការសុំអាជ្ញាប័ណ្ណ

ឧបសម្ព័ន្ធទី ៨ : ប្រកាសការវេប្រាក់របស់ពាណិជ្ជតាមរយៈធនាគារជាតិនៃកម្ពុជា

ឧបសម្ព័ន្ធទី ៩ : ប្រកាសការផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មលោហធាតុនិងត្បូងមានតំលៃ

ឧបសម្ព័ន្ធទី ៩ : ប្រកាសស្តីពីប្រាក់តំកល់ធនាលើដើមទុន

ឧបសម្ព័ន្ធទី ១០ : ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី១១ :ប្រកាសស្តីពីការប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតអា ជីវកម្មប្តូរប្រាក់

ឧបសម្ព័ន្ធទី ១២ :ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសជនបទ

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.១. លំនាំដើម

មិនថាប្រទេសអភិវឌ្ឍន៍ក្តី ប្រទេសដែលមិនអភិវឌ្ឍន៍ក្តី វិស័យធនាគារត្រូវបានគេចាត់ទុកថាជាវិស័យមួយដែលមានសារៈសំខាន់ខ្លាំងសម្រាប់ប្រទេសមួយ។ វិស័យហិរញ្ញវត្ថុនិងធនាគារប្រៀបបានទៅនឹងប្រេងរំអិលមួយដែលជួយអោយមានដំណើរការផ្នែកហិរញ្ញវត្ថុ និងជម្រុញអោយមានកំណើនសេដ្ឋកិច្ច។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងធនាគារមានការកើនឡើងជាលំដាប់ ហេតុនេះហើយបើគ្មានការត្រួតពិនិត្យ និង គ្រប់គ្រងវិស័យធនាគារនេះអោយបានត្រឹមត្រូវនោះទេ វាក៏អាចធ្វើអោយមានវិបត្តិហិរញ្ញវត្ថុជាប្រព័ន្ធ មានការដួលរលំសេដ្ឋកិច្ច ព្រមទាំងការខាតបង់អត្ថប្រយោជន៍សេដ្ឋកិច្ចទាំងមូល តួយ៉ាងដូចជា ករណីវិបត្តិហិរញ្ញវត្ថុសកលលោកកាលពីឆ្នាំ ២០០៨ជាដើម។ នៅក្នុងអំឡុងពេលនោះ ទីផ្សារភាគហ៊ុនបានធ្លាក់ចុះយ៉ាងខ្លាំងហើយជាពិសេសនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗបានដួលរលំ។ ហើយរដ្ឋាភិបាលតាមរយៈធនាគារជាតិមានតួនាទីយ៉ាងសំខាន់ ក្នុងការជួយសម្របសម្រួលអោយមានភាពប្រក្រតីផ្នែកសេដ្ឋកិច្ចតាមរយៈការប្រើប្រាស់កញ្ចប់ថវិការបស់ខ្លួនដើម្បីស្រោចស្រង់ស្ថានការណ៍នេះ។ ដោយសារតែហេតុនេះហើយ ទើបទាមទារអោយធនាគារកណ្តាលនៅគ្រប់ប្រទេសរិះរកវិធីសាស្ត្រដើម្បីត្រួតពិនិត្យនិងគ្រប់គ្រងទៅលើធនាគារពាណិជ្ជទាំងអស់ ក្នុងគោលបំណងដើម្បីរក្សាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសក៏ដូចជាសម្រាប់ពិភពលោកទាំងមូល។

ចំពោះប្រទេសកម្ពុជាវិញ យើងមើលឃើញថាវិស័យហិរញ្ញវត្ថុនិងធនាគារមានការផ្លាស់ប្តូរច្រើនដោយប្រទេសកម្ពុជាយើងមានការរីកចម្រើនទៅលើគ្រប់វិស័យ ជាពិសេស វិស័យហិរញ្ញវត្ថុនេះតែម្តង។ បន្ទាប់ពីប្រព័ន្ធសេដ្ឋកិច្ចកម្ពុជាត្រូវបានផ្លាស់ប្តូរពីសេដ្ឋកិច្ចផែន ការទៅជាសេដ្ឋកិច្ចទីផ្សារសេរីប្រព័ន្ធធនាគារត្រូវបានពង្រឹងឡើងវិញ និងធ្វើកំណែទម្រង់ជាបន្តបន្ទាប់ហើយបទបញ្ញត្តិចាស់ៗមួយចំនួនត្រូវបានកែប្រែ និងធ្វើវិសោធនកម្មអោយស្របទៅតាមស្តង់ដាអន្តរជាតិ។ ជាលទ្ធផល សាធារណជនចាប់ផ្តើមកាន់តែមានជំនឿទុកចិត្តលើប្រព័ន្ធធនាគារដែលជាសញ្ញាណវិជ្ជមានមួយ ឆ្ពោះទៅរកភាពជឿនលឿនថែមទៀតក្នុងការផ្តល់សេវាដូចជា ប្រាក់បញ្ញើ ឥណទាន និង ផ្ទេរប្រាក់។

ប៉ុន្តែស្របពេលជាមួយនឹងការរីកចម្រើននៅក្នុងប្រតិបត្តិការទាំងនោះ វាក៏បានបង្ករអោយមានការព្រួយបារម្ភចំពោះធនាគារជាតិនៃកម្ពុជាដែរ ព្រោះធនាគារជាតិមានតួនាទីជាអ្នកគ្រប់គ្រងតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារទាំងអស់នោះ។ ប្រសិនបើ

ធនាគារណាមួយជួបប្រទះនូវបញ្ហាឬក៏ដួលរលំ នោះវានឹងធ្វើអោយប៉ះពាល់ដល់សេដ្ឋកិច្ចជាប្រព័ន្ធ ហើយប្រសិនបើមានករណីធ្ងន់ធ្ងរ ហើយក៏បង្កអោយមានការបាត់បង់នូវជំនឿទុកចិត្តពីសាធារណជនមកលើប្រព័ន្ធធនាគារផងដែរ។

ដោយសារហេតុនេះហើយទើបទាមទារអោយធនាគារជាតិនៃកម្ពុជា ត្រូវតែបង្កើនការត្រួតពិនិត្យរបស់ខ្លួនទាំងការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងដើម្បីការពារអត្ថប្រយោជន៍របស់សារធារណជន និងធ្វើអោយមានភាពរឹងមាំនៅក្នុងប្រព័ន្ធធនាគារផង។

## ២. ចំណោទបញ្ហា

ចាប់តាំងពីធនាគារជាតិបានចាប់បដិសន្ធិមក ធនាគារជាតិបានចូលរួមក្នុងសកម្មភាពសម្របសម្រួលលើវិស័យហិរញ្ញវត្ថុជាច្រើន ហើយធនាគារមួយនេះដើរតួនាទីយ៉ាងសំខាន់ដើម្បីកំណត់ និងអនុវត្តគោលនយោបាយរូបិយវត្ថុក្នុងគោលបំណងដើម្បីរក្សាស្ថិរភាពថ្លៃទំនិញទូទៅ និងរក្សាតម្លៃប្រាក់រៀលអោយមានស្ថិរភាព ពោលគឺផ្តោតទៅលើបញ្ហាស្ថិរភាពរូបិយវត្ថុនិងស្ថិរភាពហិរញ្ញវត្ថុ។ ចំពោះសៀវភៅនេះខ្ញុំបាទនឹងធ្វើការបង្ហាញយ៉ាងលំអិតថាតើធនាគារជាតិនៃកម្ពុជាមានកិច្ចការងារនិងតួនាទីបែបណាក្នុងវិស័យហិរញ្ញវត្ថុ?

## ៣. កម្មវត្ថុនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងយល់អំពី៖

- ❖ លក្ខណៈទូទៅ និងការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា
- ❖ ប្រតិបត្តិការរបស់ធនាគារនិងហិរញ្ញវត្ថុ
- ❖ តួនាទីរបស់ធនាគារជាតិនៃកម្ពុជា
- ❖ ច្បាប់ និងបទបញ្ញត្តិដែលធនាគារពាណិជ្ជត្រូវអនុវត្ត

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ និង ការចងក្រងរបាយការណ៍ត្រូវបានគេធ្វើឡើងក្នុងគោលបំណង៖

- ❖ ធ្វើការស្វែងយល់បន្ថែមពីកិច្ចការងាររបស់ធនាគារជាតិនៃកម្ពុជា ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ
- ❖ បង្កើនការយល់ដឹងអំពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជា
- ❖ ស្វែងយល់បន្ថែមពីការផ្សារភ្ជាប់រវាងទ្រឹស្តីដែលបានសិក្សានៅសាកលវិទ្យាល័យនិងដំណើរការនៃការអនុវត្តជាក់ស្តែងរបស់ធនាគារជាតិនៃកម្ពុជា

❖ ផ្តល់ជាឯកសារជំនួយក្នុងការអាននិងការសិក្សារៀនសូត្រចំពោះអ្នកជំនាន់ក្រោយ។

## ៥. ទំហំ និង វិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើង តាមរយៈការទាញយកឯកសារតាមគេហទំព័ររបស់ធនា គារជាតិនៃកម្ពុជា បណ្ណាល័យ បណ្ណាគារនិងប្រភពផ្សេងៗទៀតដើម្បីជាឯកសារនិងចងក្រងសៀវភៅនេះឡើង ហើយវាផ្តោតសំខាន់ទៅលើតែតួនាទីនិងការអនុវត្តលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជាទៅលើធនាគារពាណិជ្ជតែប៉ុន្មោះ។ ហើយខ បាទមិនបានធ្វើការវិភាគទៅលើទិន្នន័យទាំងនេះទេពីព្រោះពត័មានទាំងនេះត្រូវបានធនាគារជាតិនៃកម្ពុជាធ្វើការវិភាគរួចហើយ។ ការស្រាវជ្រាវនេះបានចាប់ផ្តើមពីថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៧។ បន្ថែមលើសនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះធ្វើឡើងតាមរយៈការប្រមូលឯកសារតាមប្រភពដែលមានស្រាប់ ដោយមិនបានស្រាវជ្រាវដល់ធនាគារជាតិនៃកម្ពុជានោះទេដូច្នេះហើយព័ត៌មានខ្លះមិនត្រូវបានដាក់បញ្ចូលទេ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីអោយស្រាវជ្រាវបានចប់សព្វគ្រប់ទាន់ពេលវេលា និងសម្រេចប្រកបដោយផ្លែផ្កាល្អកម្មសិក្សាការីមានវិធីសាស្ត្រមួយចំនួនដែលត្រូវបានយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យ និងព័ត៌មានផ្សេងៗដែលទាក់ទងនឹងការស្រាវជ្រាវនេះ៖

❖ ទិន្នន័យតំបូង: ជាប្រភេទទិន្នន័យនិងព័ត៌មាន ដែលបានយកមកការសាកសួរនិងធ្វើសុំយោបល់ពីមន្ត្រីជំនាញដែលមានការយល់ដឹងអំពីមុខងារនិងតួនតាទីរបស់ធនាគារជាតិនៃកម្ពុជា។

❖ ទិន្នន័យបន្ទាប់បន្សំ: ជាប្រភេទទិន្នន័យ និងព័ត៌មានមួយចំនួនបន្ថែមទៀតដែលបានមកពីសៀវភៅច្បាប់ បទបញ្ញត្តិ និងសៀវភៅសិក្សាមេរៀនមួយចំនួនដែលបានស្រាវជ្រាវពីបណ្ណាល័យ បណ្ណាគារ និងជាពិសេសនោះគឺតាមគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជាតែម្តង។

## ៧. រចនាសម្ព័ន្ធការស្រាវជ្រាវ

ជំពូកខាងក្រោមនេះ ត្រូវបានរៀបចំឡើងដើម្បីធ្វើអោយមាន ការយល់ដឹងជុំវិញបញ្ហាដែលបានចោទឡើងចំពោះប្រធានបទ "តួនាទីរបស់ធនាគាជាតិនៃកម្ពុជាក្នុងធនាគារនិងហិរញ្ញវត្ថុ"។ រាល់ជំពូកទាំងអស់នៅក្នុងសៀវភៅនេះមានការពន្យល់លំអិតអំពីតួនាទីរបស់ធនាគារជាតិ ហើយជំពូកនីមួយៗ ត្រូវបានបែងចែកជា៖

❖ សេចក្តីផ្តើម៖ លំនាំបញ្ហា ចំណោទបញ្ហា កម្មវត្ថុនៃការស្រាវជ្រាវ ទំហំនៃការស្រាវជ្រាវ វិធីសាស្រ្តនៃការស្រាវជ្រាវ ប្រមូលទិន្នន័យ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

❖ ជំពូក ១ ៖ ស្ថានភាពទូទៅរបស់ធនាគារជាតិនៃកម្ពុជា

❖ ជំពូក២៖ រំលឹកទ្រឹស្តីដែលនៅក្នុងនោះបង្ហាញអំពីនិយមន័យ និងសម្រង់សម្តីរបស់អ្នកស្រាវជ្រាវផ្សេងៗ

❖ ជំពូក ៣ ៖ ការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា

❖ ជំពូក ៤ ៖ តួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ

❖ សន្និដ្ឋាន និង ការផ្តល់អនុសាសន៍

# ជំពូក១

# ទិដ្ឋភាពទូទៅរបស់

# ធនាគារជាតិនៃកម្ពុជា

# ជំពូក ១

# ទិដ្ឋភាពទូទៅរបស់ធនាគារជាតិនៃកម្ពុជា

## ១.១. ប្រវត្តិរបស់ធនាគារជាតិនៃកម្ពុជា[1]

ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៥៤ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង និង បន្ទាប់ពីវិទ្យាស្ថានបោះប្រាក់ឥណ្ឌូចិនត្រូវបានបិទទ្វារ។ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយប្រាក់រៀលជាឯករាជ្យរបស់ខ្លួនដើម្បីបញ្ចប់ជាស្ថាពរនូវសម្ព័ន្ធភាពជាមួយប្រាក់វៀតណាមនិងឡាវ។ ពេលនោះប្រព័ន្ធធនាគារក្នុងប្រទេសត្រូវបានបង្កើតឡើងដោយមានធនាគាររដ្ឋ និងធនាគាឯកជនធ្វើប្រតិបត្តិការណ៍ទន្ទឹមគ្នាលើដែនដីរបស់ប្រទេសកម្ពុជា។

នៅឆ្នាំ ១៩៦៤ ដើម្បីបម្រើអោយគោលនយោបាយកសាងជាតិនៃសម័យសង្គមរាស្ត្រនិយមគេបានធ្វើកំណែទម្រង់ប្រព័ន្ធធនាគារជាបន្តបន្ទាប់ ដើម្បីតម្រូវតាម សេចក្តីត្រូវការនៃសេដ្ឋកិច្ចជាតិនាសម័យនោះ។ គេបានប្រែក្លាយធនាគារជាតិនៃកម្ពុជា ពីទម្រង់ស្ថាប័នពាក់កណ្តាលស្វយ័តទៅជាធនាគាររដ្ឋក្រោមទម្រង់ ជាស្ថាប័នសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម។ ចំណែកឯធនាគាពាណិជ្ជ និង ធនាគារបរទេសមួយចំនួនត្រូវបានបិទទ្វារ ហើយរដ្ឋបានបង្កើតធនាគារដែលកាន់កាប់ដោយរដ្ឋមួយចំនួនដូចជា ធនាគារឥណទានជាតិ ធនាគារអភិវឌ្ឍន៍ និង ធនាគារកសិកម្មជនបទ។ ចាប់តាំងពីចុងឆ្នាំ ១៩៧០ រហូតដល់ខែ មេសា ឆ្នាំ១៩៧៥ រដ្ឋបានធ្វើសេរីភាវូបណីយកម្មទៅលើប្រព័ន្ធធនាគារ។ ធនាគារឯកជនត្រូវបានអនុញ្ញាតអោយធ្វើសកម្ម ភាពទន្ទឹមគ្នា និងធនាគាររដ្ឋដែរតែក្រោមការបញ្ជាណែនាំនិងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារ ប្រព័ន្ធធនាគារទូទាំងប្រទេសត្រូវបានលុបបំបាត់ចោល អគារធនាគារជាតិត្រូវបានកម្ទេចហើយរូបិយវត្ថុជាតិត្រូវបានបញ្ឈប់អោយប្រើប្រាស់។

រហូតមកដល់ឆ្នាំ ១៩៧៩ ទើបធនាគារជាតិនៃកម្ពុជាត្រូវបានរៀបចំឡើងវិញក្នុងនាមជាធនាគារកណ្តាលរបស់ប្រទេសនៅថ្ងៃទី ១០ ខែ តុលា។ នៅពេលដែលធនាគារជាតិនៃកម្ពុជា ត្រូវបានស្តារឡើងវិញពីកម្រិតសូន្យទាំងហេដ្ឋារចនាសម្ព័ន្ធនិងធនធានមនុស្សត្រូវបានប្រែប្រូល និងកសាងជាបណ្តើរៗរហូតបង្កើតបានជាស្ថាប័នធនាគារជាតិមួយដែលមានឈ្មោះថា "ធនាគារជាតិនៃប្រជាជនកម្ពុជា"។ ដោយសារអគារធនាគារក្រហមត្រូវបានកម្ទេចទៅហើយនោះ ធនាគារ

[1] ដកចេញពីសៀវភៅរបស់រូបិយវត្ថុនិងធនាគាររបស់លោក ងួន ហេង

ជាតិនៃប្រជាជនកម្ពុជា បានបើកស្នាក់ការកណ្តាលរបស់ខ្លួនជាបណ្តោះអាសន្ននៅលើអគារអតីតធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម ហើយបានរៀបចំរចនាសម្ព័ន្ធក្បាលម៉ាស៊ីនដឹកនាំ និងសកម្មភាពប្រតិបត្តិការនៅទីស្នាក់ការកណ្តាល និងបានពង្រីកទៅបណ្តាខេត្តក្រុងទូទាំងប្រទេស។ ធនាគារជាតិនៃប្រជាជនកម្ពុជាបានបោះផ្សាយប្រាក់រៀលឡើងវិញនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៨០ ដើម្បីជួយសម្របសម្រួលដល់ការទូទាត់ក្នុងជីវភាពរស់នៅរបស់ប្រជាជន។ ចំណែកឯអគារធនាគារជាតិនៃកម្ពុជាដែលបាក់បែកត្រូវបានគេរុះរើរសាងសង់ជាថ្មីឡើងវិញនៅឆ្នាំ១៩៩០។[2]

ចាប់ពីឆ្នាំ ១៩៨៩ ប្រព័ន្ធធនាគារត្រូវបានកែទម្រង់។ ធនាគារខេត្ត-ក្រុងទាំងអស់បានប្តូរមកជាធនាគារខេត្ត-ក្រុងវិញ ហើយធ្វើសកម្មភាពនៅដែនដីរបស់ខ្លួន តាមរបបស្វ័យភិបាលសេដ្ឋកិច្ច និងស្វ័យភាពហិរញ្ញវត្ថុដោយមានធនាគារជាតិនៃប្រជាជនកម្ពុជា ជាអ្នកបញ្ជាណែនាំ និងត្រួតពិនិត្យ។ ក្រោយមានសន្និសញ្ញាសន្តិភាពក្រុងប៉ារីស ថ្ងៃទី ២៣ ខែតុលាឆ្នាំ១៩៩១ របត់នយោបាយមួយត្រូវបានបង្កើតឡើងដោយរបបសេដ្ឋកិច្ចត្រូវបានផ្លាស់ប្តូរពីរបបសេដ្ឋកិច្ចផែនការទៅជារបបសេដ្ឋកិច្ចទីផ្សារ ដែលញុាំងអោយមានការកែប្រែប្រព័ន្ធធនាគារនៅកម្ពុជាពីប្រព័ន្ធធនាគារមួយថ្នាក់មកជាប្រព័ន្ធធនាគារដែលមានពីរថ្នាក់ ហើយរដ្ឋបានបើកទូលាយចំពោះអាជីវកម្មលើវិស័យធនាគារតាមរយៈការអនុញ្ញាត អោយមានធនាគារពាណិជ្ជក្រោមច្បាប់ក្នុងស្រុកឬក្រោមទម្រង់ជាសាខាធនាគារបរទេស។ ប្រការនេះធ្វើអោយធនាគារជាតិនៃកម្ពុជា ពង្រឹងតួនាទីរបស់ខ្លួនដើម្បីបង្កើនសមត្ថភាពបញ្ជាណែនាំ និងត្រួតពិនិត្យដោយបានបង្កើតច្បាប់និងប្រកាសផ្សេងៗជាបន្តបន្ទាប់រួមមាន៖

១) ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា រដ្ឋសភាបាន អនុម័តនៅថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦។ ច្បាប់នេះបានកំណត់បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជាគឺកំណត់និងដឹកនាំនយោបាយហិរញ្ញវត្ថុដើម្បីរក្សាថ្លៃអោយមានស្ថិរភាព។

២) ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ដែល រដ្ឋសភាបានអនុម័តនៅថ្ងៃទី ២២ សីហា ឆ្នាំ ១៩៩៧

៣) ច្បាប់ស្តីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ និងចុងក្រោយនេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចចងក្រងឯកសារ ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០០១ ដល់ឆ្នាំ ២០១០ ដែលជាឯកសារ យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាអោយមានភាពជឿនលឿន ប្រកប

---

[២] គេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា www.nbc.org.kh

ដោយជំនឿទុក ចិត្តពីសាធារណៈជន និងអាចធ្វើអោយមានសមាហរណកម្មចូលទៅក្នុង ប្រព័ន្ធហិរញ្ញវត្ថុ ពិភពលោក។

ក្នុងនាមធនាគារកណ្តាល ដើម្បីលើកមុខមាត់និងកិត្យានុភាពរបស់ខ្លួនអោយសក្តិសមជាអាជ្ញាធរអាណាព្យាបាលលើវិស័យធនាគារ អគារធនាគារជាតិនៃកម្ពុជាត្រូវបានកែលម្អរផ្នែកសោភ័ណភាពនៅឆ្នាំ ២០០៣។ ប្រព័ន្ធធនាគារនៅកម្ពុជានាពេលបច្ចុប្បន្នគិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១១ រួមមានៈ ធនាគារជាតិនៃកម្ពុជាដែលមានសាខារបស់ខ្លួនទូទាំងប្រទេសចំនួន២១ ជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុដែលក្នុងនោះមានធនាគារពាណិជ្ជចំនួន ៣៧ ធនាគារឯកទេសចំនួន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣១ អង្គការមិនមែនរដ្ឋាភិបាល ២៨ និងមានតូបប្តូរប្រាក់ជាច្រើនកំពុងតែប្រតិបត្តិការប្រចាំថ្ងៃ ទូទាំងប្រទេស។

សរុបសេចក្តីមក ដើមកំណើតរបស់ធនាគារជាតិនៃកម្ពុជាចែកចេញជា បីដំណាក់កាលគឺៈ

១. ដំណាក់កាលទីពីឆ្នាំ ១៩៥៤ ដល់ឆ្នាំ ១៩៧៥ ជាដំណាក់កាលដែលធនាគារជាតិនៃកម្ពុជាមានឯករាជ្យក្នុងការធ្វើប្រតិបត្តិការមានស្វ័យភាពក្នុងការបោះផ្សាយប្រាក់រៀលដែលជារូបិយវត្ថុជាតិនិងបាន គ្រប់គ្រងប្រព័ន្ធធនាគារដោយខ្លួនឯងនៅលើដែនដីកម្ពុជា។

២. ដំណាក់កាលពីឆ្នាំ ១៩៥៤ ដល់ឆ្នាំ ១៩៧៩ ជាយុគសម័យដែលធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វាលែងដំណើរការនិងប្រព័ន្ធទាំងមូលត្រូវបានកម្ទេចចោលទាំងស្រុង។

៣. ដំណាក់កាលពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ជាដំណាក់កាលដែលធនាគារជាតិនៃកម្ពុជាត្រូវបានរស់ឡើងវិញនិងត្រូវបានពង្រឹងជាបណ្តើរៗរហូតទទួលបានការទទួលស្គាល់គួរជាទីមោទនៈពីមជ្ឍដ្ឋានអន្តរជាតិ។

## ១.២. ការគ្រប់គ្រងនិងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា

ក្រុមប្រឹក្សាភិបាល គឺជាអង្គការគ្រប់គ្រងថ្នាក់ខ្ពស់បំផុតរបស់ធនាគារជាតិនៃកម្ពុជា ហើយដឹកនាំដោយទេសាភិបាល។ នៅពេលដែលទេសាភិបាលអវត្តមាន ទេសាភិបាលរងជាអ្នកជំនួស។ ក្នុងករណីចាំបាច់ទេសាភិបាលអាចតែងតាំងឧបការីមួយរូប ឬ ច្រើនរូបជាតំណាងរបស់ខ្លួន។ ក្នុងតំណែងរបស់ទេសាភិបាល និងទេសាភិបាលរងមិនអាចជាមន្ត្រីរាជការ ទីប្រឹក្សាអង្គភាពសាធារណៈ ជាសមាជិករដ្ឋាភិបាល និង តំណាងអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងតំណាង មជ្ឈដ្ឋានឧត្តមសិក្សាបានទេ តែម្នាក់ៗអាចរក្សាលក្ខណៈជាមន្ត្រីរាជការបាន។

ទេសាភិបាលមានតួនាទី ជាអ្នកដឹកនាំទីមួយនៃធនាគារកណ្តាល និង ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាលើកិច្ចការអនុវត្តនយោបាយរបស់ខ្លួន។ ទេសាភិបាលត្រូវទទួលខុសត្រូវលើការដឹកនាំកិច្ចការរបស់ធនាគារជាតិនៃកម្ពុជា និងមានសិទ្ធិអំណាចធ្វើកិច្ចការទាំង ឡាយណាដែលមិន

បានកំណត់សម្រាប់ក្រុមប្រឹក្សានៅក្នុងច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ឬ បទបញ្ញត្តិទាំងអស់ដែលពាក់ព័ន្ធ។

**សមាសភាពបច្ចុប្បន្ន**[3] **(ឆ្នាំ ២០១៥)**

ក្រុមប្រឹក្សាភិបាលមានសមាជិក ០៧ រូប មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| ឯកឧត្តម ជូ គីមឡេង | តំណាងប្រមុខរបស់រដ្ឋាភិបាល | ជាសមាជិក |
| ឯកឧត្តម រស់ ស៊ីលវា | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ឯកឧត្តម អ៊ីវ ចុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| លោក ឡាយម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| លោកស្រី មៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក |

### ១.២.១. រចនាសម្ព័ន្ធ និងមុខងារនាយកដ្ឋានស្រាវជ្រាវនិងសហប្រតិបត្តិការអន្តរជាតិ

មុខងារសំខាន់ៗរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ៖

- តាមដាន សិក្សា វិភាគអំពីស្ថានភាព និងការវិវត្តនៃសេដ្ឋកិច្ចរូបិយវត្ថុ និងវិស័យហិរញ្ញវត្ថុក្នុងប្រទេស និង ក្រៅប្រទេសដែលអាចមានផលប៉ះពាល់ ដល់ការអនុវត្តនយោបាយរូបិយវត្ថុក្នុងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុរបស់ប្រទេស
- ស្រាវជ្រាវលើប្រធានបទនិងបញ្ហាទាំងឡាយ ដែលបម្រើដល់ការបំពេញតួនាទីប្រកបដោយប្រសិទ្ធិភាពរបស់ធនាគារជាតិនៃកម្ពុជា
- រៀបចំឯកសារ ចងក្រង បោះពុម្ពនិងបែងចែកព្រឹត្តិបត្រប្រចាំត្រីមាស របាយការណ៍ឆមាស និង ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា
- ទទួលបន្ទុកការងារសហប្រតិបត្តិការក្រៅប្រទេសលើវិស័យធនាគារ និងហិរញ្ញវត្ថុនិងបំពេញការងារផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ១.២.២. រចនាសម្ព័ន្ធ និង មុខងាររបស់នាយកដ្ឋានស្ថិតិ

ក្រុមប្រឹក្សាភិបាលជាគណៈគ្រប់គ្រង ដែលមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើផែនការ និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា នៅធនាគារជាតិនៃកម្ពុជា និងមានសមាសភាពចំនួន ៧ រូបគឺ ទេសាភិបាល ទេសាភិបាលរង តំណាងប្រមុខរដ្ឋាភិបាល តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងមជ្ឈដ្ឋានឧត្តមសិក្សា តំណាង មជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច និងតំណាងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា។ ទេសាភិបាលជាប្រធានក្រុមប្រឹក្សាភិបាល និងមានតួនាទីជានាយកប្រតិបត្តិនៃធនាគារជាតិនៃកម្ពុជា ជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលខុស

[៣] គេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា www.nbc.org.kh

ត្រូវចំពោះកិច្ចការអនុវត្តគោលនយោបាយនិងប្រតិបត្តិការប្រចាំថ្ងៃ។ ទេសាភិបាលត្រូវបានតែងតាំងដាក់ជំនួស និងបញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យដែលយោងតាមសំណើរបស់រាជរដ្ឋាភិបាល។

ក្នុងកម្រិតបច្ចេកទេស ធនាគារជាតិនៃកម្ពុជាមានប្រាំអគ្គនាយកដ្ឋានគឺ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា និងអគ្គាធិការ ដ្ឋានដែលក្នុងនោះរួមមាន២១ នាយកដ្ឋាន ដឹកនាំដោយប្រធាននាយកដ្ឋាន។ នាយកដ្ឋាន និងអគ្គនាយកដ្ឋានមានតួនាទី ទទួលខុសត្រូវចំពោះការអនុវត្តមុខងារប្រចាំថ្ងៃនៃប្រតិបត្តិការធនាគារកណ្តាល និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា។4

- ❖ អគ្គលេខាធិការដ្ឋានៈ ជាសេនាធិការផ្ទាល់របស់ថ្នាក់ដឹកនាំ ដោយបំពេញភារកិច្ចតាមដែនសមត្ថកិច្ចដែលកំណត់អោយ សម្រាប់វិស័យការងារដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលនឹងគ្រប់គ្រងផ្ទាល់នូវខុទ្ទកាល័យ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានគណនេយ្យ នាយកដ្ឋានគ្រប់គ្រងសាខា និងមជ្ឈមណ្ឌលសិក្សាបច្ចេកទេសធនាគារ។
- ❖ អគ្គនាយកដ្ឋានៈ គឺជាសេនាធិការជំនាញរបស់ថ្នាក់ដឹកនាំដោយបំពេញភារកិច្ចតាមដែនសមត្ថកិច្ចដែលកំណត់អោយ សម្រាប់វិស័យសកម្មភាពដែលទាក់ទងនឹងអាជីវកម្មស្នូលនៃស្ថាប័ន។ អគ្គនាយកដ្ឋាននេះគ្រប់គ្រងផ្ទាល់នូវនាយកដ្ឋានត្រួតពិនិត្យ នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និង នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ។
- ❖ អគ្គាធិការដ្ឋានៈ ជាសេនាធិការត្រួតពិនិត្យសំខាន់របស់ដឹកនាំ ដោយបំពេញភារកិច្ចទូលំទូលាយខាងសវនកម្មផ្ទៃក្នុ លើអង្គភាពគ្រប់ថ្នាក់ដែលនៅក្រោមឪវាទផ្ទាល់របស់ធនាគារជាតិនៃកម្ពុជា។ ពោលគឺគ្រប់គ្រងផ្ទាល់នូវនាយកដ្ឋានសវនកម្មផ្ទៃក្នុង និង នាយកដ្ឋានអធិការកិច្ច។
- ❖ អគ្គបេឡាៈ គឺជាសេនាធិការជំនាញរបស់ថ្នាក់ដឹកនាំដោយបំពេញភារកិច្ចតាមដែនសមត្ថកិច្ចដែលកំណត់អោយ សម្រាប់វិស័យសកម្មភាពដែលទាក់ទងទៅនឹងរូបិយវត្ថុជាតិ និង កាន់កាប់រូបិយប័ណ្ណ។ អគ្គបេឡាគ្រប់គ្រងផ្ទាល់នូវនាយកដ្ឋានបោះផ្សាយនិង នាយកដ្ឋានរោងពុម្ព។
- ❖ អគ្គនាយកដ្ឋានបច្ចេកទេសៈគឺជាផ្នែកមួយនៃធនាគារជាតិនៃកម្ពុជាដែលមានបេសកកម្មចម្បងគឺអនុវត្តការត្រួតពិនិត្យឡើងវិញជាប្រចាំលើការប្រតិបត្តិ ឬ លទ្ធផលនៃការប្រតិបត្តិការរបស់នាយកដ្ឋានទាំងអស់។ ហើយអគ្គនាយកដ្ឋានបច្ចេកទេសធ្វើការវិភាគ សិក្សា សរុប និងទាញសេចក្តីសន្និដ្ឋានទៅលើលទ្ធផលនៃការត្រួតពិនិត្យឡើងវិញជាប្រចាំនិងលើកយោបល់ ផ្តល់ការកោតសរសើរ កែលម្អ ដាក់ពិន័យ ឬវិធានការសមស្របផ្សេងៗទៅតាមការជាក់ស្តែង។

## ១.៣. ផ្លាកសញ្ញារបស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា មានរូបសញ្ញាសម្គាល់របស់ខ្លួនដែលមានអក្សរ "រ " មានពណ៌ប្រាក់ជាតំណាង និងរង្វង់គូរស្រូវពណ៌មាសព័ទ្ធជុំវិញ។

4 ដកស្រង់ចេញពីសៀវភៅរបាយការណ៍បញ្ចប់កាសិក្សារបស់និស្សិត សៅ ឧត្តម ឆ្នាំ ២០១៤

- អក្សរ "រ" តំណាងអោយប្រាក់រៀលដែលបានបោះផ្សាយ
- ក្បូរស្រូវតំណាងអោយវិស័យកសិកម្មដែលមានក្បូរស្រូវបីជួរអមសងខាងអក្សរ"រ" ក្នុងមួយជួរមាន ៧ គ្រាប់តំណាងអោយថ្ងៃ ៧ មករា។

## ១.៤. ទីតាំង និង សាខារបស់ធនាគារជាតិនៃកម្ពុជា[5]

### ១.៤.១. ទីស្នាក់ការ

ធនាគារជាតិនៃកម្ពុជា មានទីតាំងតាមបណ្តោយផ្លូវ ១១០-៦៧ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យកណ្តាលរបស់ធនាគារជាតិនៃកម្ពុជា គឺស្ថិតនៅរាជធានីភ្នំពេញ ដែលមានបុគ្គលិកចំនួន ១៣៨៤ នាក់ ហើយនៅការិយាល័យកណ្តាលមាន ៩៧៩នាក់ និងតាមបណ្តាសាខានៅខេត្តមាន ៤០៥ នាក់។

### ១.៤.២. សាខារបស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា មានសាខាចំនួន ២១ នៅក្នុង ២៥ រាជធានីខេត្ត នៅក្នុងនោះរួមមានខេត្តដូចជាៈ រាជធានីភ្នំពេញ កណ្តាល កំពង់ចាម បាត់ដំបង ព្រៃវែង សៀមរាប កំពង់ធំ តាកែវ ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ព្រះសីហនុ កោះកុង ព្រះវិហារ ក្រចេះ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង បន្ទាយមានជ័យ និងស្វាយរៀង។

## ១.៥ .គោលនយោបាយកាតព្វកិច្ចប្រាក់បម្រុងរបស់ធនាគារកណ្តាល

នៅពេលដែលធនាគារពាណិជ្ជធ្វើការស្នើសុំបង្កើតឡើង ធនាគារជាតិនៃកម្ពុជា តម្រូវអោយធនាគារពាណិជ្ជទាំងឡាយត្រូវទុកមួយផ្នែកនៃប្រាក់បញ្ញើតាមតម្រូវការ និងប្រាក់បញ្ញើមានកាលកំណត់នៅធនាគារជាតិជាប្រាក់បម្រុងកាតព្វកិច្ច។ កាតព្វកិច្ចរបស់ប្រាក់បម្រុង គឺធានាដល់សុវត្ថិភាពប្រាក់និងភាពរឹងមាំមួយរបស់ធនាគារពាណិជ្ជ។ នៅក្រោមនិ-យ័តកម្មនេះប្រាក់បម្រុងនេះនឹងក្លាយទៅជាទ្រព្យសកម្មដែលមានលក្ខណៈបង្ខាំងទុក នៅអំឡុងពេលមានវិបត្តិព្រោះប្រាក់បម្រុងនេះមិនអាចអោយគេប្រើប្រាស់បានទេ។

### ១.៥.១. ការឆ្លើយតបទៅនិងកាតព្វកិច្ចប្រាក់បម្រុង

ស្ថាប័នទទួលប្រាក់បញ្ញើអាចទទួលបានមូលនិធិពីប្រភពផ្សេងៗ ដើម្បីឆ្លើយតបទៅនិងកាតព្វកិច្ចប្រាក់បម្រុង តាមរយៈការលក់មូលបត្រ ឬ ទ្រព្យសកម្មផ្សេងទៀតអោយទៅស្ថាប័នប្រាក់បញ្ញើ ឬ ការខ្ចីពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត។ ជាទូទៅ ស្ថាប័នទទួលប្រាក់បញ្ញើអាចបង្កើនប្រាក់បម្រុងដោយខ្ចីពីធនាគារជាតិ ឬ ដោយការលក់សញ្ញាប័ណ្ណទៅអោយធនាគារកណ្តាល។

---

[5] ព្រឹត្តិបត្រប្រចាំត្រីមាសទី១ របស់វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

### ១.៥.២. ប្រភេទខុសគ្នានៃប្រាក់បម្រុងនិងរូបិយវត្ថុ

ប្រភេទខុសៗគ្នានៃប្រាក់បម្រុងនិងរូបិយវត្ថុគោលៈ

- ❖ ប្រាក់បម្រុងលើស គឺជាភាពខុសគ្នារវាងទំហំនៃប្រាក់បម្រុងសរុបនិងប្រាក់បម្រុងដែលគេបានកំណត់ ឬ ប្រាក់បម្រុងលើសស្មើនឹងប្រាក់បម្រុងពិតដកប្រាក់បម្រុងដែលបានកំណត់។
- ❖ ប្រាក់បម្រុងដែលគេអោយខ្ចី គឺ ជាប្រាក់បម្រុងដែលស្ថាប័នទទួលប្រាក់បញ្ញើខ្ចីពីធនាគារកណ្តាល។
- ❖ ប្រាក់បម្រុងដែលគេមិនធ្វើការខ្ចី៖ អ្នកផ្គត់ផ្គង់ប្រាក់បម្រុងចុងក្រោយពីធនាគារកណ្តាលអាចផ្តល់បំណុលផ្ទាល់ខ្លួន តាមរយៈប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារកណ្តាលដោយទិញនូវមូលបត្រពីធនាគារនានាក្នុងប្រតិបត្តិការទូទាត់ដែលជាប្រតិបត្តិទីផ្សារបើកចំហ។ ប្រភេទប្រាក់នៃប្រាក់បម្រុងនេះ ហៅថាប្រាក់បម្រុងដែលមិនមានលក្ខណៈខ្ចី។

### ១.៥.៣. ការតម្រូវអោយមានការតព្វកិច្ចប្រាក់បម្រុង[6]

ហេតុអ្វីបានជាគេតម្រូវអោយមានកាតព្វកិច្ចប្រាក់បម្រុង ដល់ស្ថាប័នទទួលប្រាក់ដែលបញ្ញើនេះជាចំ ?ណុចខ្លះៗដែលបញ្ជាក់ការតម្រូវអោយមានកាតព្វកិច្ចប្រាក់បម្រុង។

- ❖ ស្ថាប័នទទួលប្រាក់បញ្ញើត្រូវទុកប្រាក់បម្រុងរបស់ខ្លួនតាមកាតព្វកិច្ច
- ❖ ស្ថាប័នទទួលប្រាក់បញ្ញើមានបទពិសោធន៍គ្រប់គ្រាន់ ដើម្បីបញ្ជាក់នូវចំនួនមូលនិធិដែលគេត្រូវការអោយមានប្រាក់បម្រុងដើម្បីឆ្លើយតបទៅនិងការដកសាច់ប្រាក់ឬការដកប្រាក់បញ្ញើ
- ❖ ស្ថាប័នទទួលប្រាក់បញ្ញើទាមទារអោយមាន សន្ទនីយភាពគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការរបស់អ្នកផ្ញើប្រាក់។

តើកាតព្វកិច្ចប្រាក់បម្រុងនេះបានការពារអ្នកដាក់ប្រាក់បញ្ញើដែរឬទេ? ខាងក្រោមនេះជាចំណុចដែលទាក់ទងទៅនឹងការជួយទៅដល់អ្នកដាក់ប្រាក់បញ្ញើ។

- ❖ កាតព្វកិច្ចប្រាក់បម្រុង គឺជាឧបករណ៍គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិហើយបើសិនជាប្រាក់បម្រុងដែលគេទាមទារនេះមានស្ថិរភាពនោះ មេគុណរូបិយវត្ថុក៏មានស្ថិរភាពដែរ។ វាមានន័យថា ធនាគារកណ្តាលអាចត្រួតពិនិត្យការផ្គត់ផ្គង់រូបិយវត្ថុឲ្យកាន់តែមានប្រសិទ្ធិភាព តាមរយៈប្រតិបត្តិការទីផ្សារបើកចំហ។
- ❖ ការប្រែប្រួលកាតព្វកិច្ចប្រាក់បម្រុងប៉ះពាល់ដល់ការផ្គត់ផ្គត់រូបិយវត្ថុ តាមរបៀបពីរយ៉ាងគឺធ្វើអោយប្រែប្រួលកម្រិតបម្រុងលើស និង មេគុណរូបិយវត្ថុ។

### ១.៥.៤. ឥទ្ធិពលនៃការប្រែប្រួលប្រាក់បម្រុងកាតព្វកិច្ច

ធនាគារកណ្តាលអាចធ្វើអោយប្រែប្រួលដល់កាតព្វកិច្ចប្រាក់បម្រុង បើសិនគេចង់ធ្វើអោយមានការប្រែប្រួលបានលឿនដល់ការផ្គត់ផ្គង់រូបិយវត្ថុ។ ឧបមាថា បើសិនជាធនាគារជាតិនៃកម្ពុជា

---

6 គេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា www.nbc.org.kh

ចង់រិតបន្តឹងរូបិយវត្ថុរបៀបណា មួយយប់ ឬ មួយថ្ងៃនោះ គេអាចបង្កើននូវអត្រាប្រាក់បម្រុងដែលគេទាមទារចំពោះធនាគារធំៗ។ គេក៏អាចបង្កើននូវកាតព្វកិច្ចប្រាក់បម្រុងលើប្រាក់បញ្ញើមានកាលកំណត់ដែរ ហើយម្យ៉ាងវិញទៀតបើសិនជាធនាគារកណ្តាលចង់បន្ធូរបន្ថយលក្ខខណ្ឌឥណទាននោះគេកាត់បន្ថយនូវអត្រាប្រាក់បម្រុងតាមច្បាប់កំណត់។

## ១.៦. សេវាកម្មរបស់ធនាគារជាតិ[7]

ធនាគារជាតិនៃកម្ពុជា ធ្វើប្រតិបត្តិការផ្តល់សេវាកម្មមួយចំនួនដូចជា ការគ្រប់គ្រងគណនី សេវាទូទាត់ សេវាផ្ទេរប្រាក់ ផ្តល់ហិរញ្ញវត្ថុនិងការគ្រប់គ្រងប័ណ្ណសងតាមបញ្ជានិងការផាត់ទាត់ឧបករណ៍ទូទាត់សងប្រាក់ជូនរាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ។ ក្រៅពីនេះធនាគារជាតិនៃកម្ពុជាបានបោះផ្សាយនិងគ្រប់ គ្រងមូលបត្រអាចជួញដូរបាន ដើម្បីសម្រួលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការគ្រប់គ្រង សន្ទនីយភាពនិងជម្រុញការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ។

### ១.៦.១. ការគ្រប់គ្រងគណនី

ធនាគារជាតិបានគ្រប់គ្រងគណនីចំនួន ១៣៧៥ ជាប្រាក់រៀលនិងប្រាក់ដុល្លាររបស់ធនាគារនិងស្ថាប័នរដ្ឋដែលរួមមាន គណនីចរន្ត គណនីប្រាក់ដំកល់ធានាដើមទុន គណនីបម្រុងកាតព្វកិច្ចនិងគណនីប្រាក់បញ្ញើមានកាលកំណត់។ បើប្រៀបធៀបទៅឆ្នាំ ២០១៤ ចំនួនគណនីបានកើនឡើង៧៥% ហើយភាគច្រើនជាគណនីប្រាក់បញ្ញើ និង ប្រាក់គណនីចរន្តរបស់ធនាគារស្ថាប័នហិរញ្ញវត្ថុនិងគណនីគម្រោងរបស់រដ្ឋាភិបាល។

*ក្រាហ្វិក ១៖ ក្រាហ្វិកបង្ហាញពីចំនួនគណនីនៅឆ្នាំ ២០១៣-២០១៥*




[illegible]
ងាររដ្ឋាភិបាល ផ្តល់សេវាកម្មទូទាត់ សម្របសម្រួលកិច្ចការសាធារណៈ សេវាកម្មបើកប្រាក់ខែតាមរយៈប្រព័ន្ធធនាគារ និងការដកប្រាក់របស់មន្ត្រីយោធាជាដើម។ នៅឆ្នាំ ២០១៥នេះ ធនាគារ

[7] ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំ២០១៤

ជាតិបានបើកគណនីថ្មីចំនួន ១១ ជូនក្រសួងនិងភ្នាក់ងាររបស់រដ្ឋាភិបាល អង្គភាពក្រោមបង្គាប់ដែលទទួលបុរេប្រទានមុន pitty cash និង ការចំណាយផ្សេងទៀតដោយផ្ទាល់ពីអគ្គនាយកដ្ឋានរតនាគារជាតិ (General Department of the National Treasury)។[8]

លើសនេះទៀត ធនាគារជាតិបានត្រៀមខ្លួនគាំទ្រនិងចូលរួមចំណែកក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងសាធារណៈជំហានទី៣ ដែលជាគោលនយោបាយភ្ជាប់និងថវិកា។ ដើម្បីចូលរួមចំនែកក្នុងកម្មវិធីកំណែទម្រង់នេះអោយមានប្រសិទ្ធិភាពនិងគណនេយ្យភាព ធនាគារជាតិបានសហការជាមួយ ក្រុមបច្ចេកវិទ្យាព័ត៌មានក្នុងអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍន៍ទំនាក់ទំនងគ្នារវាងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) និងប្រព័ន្ធដាក់ប្រាក់ក្នុងធនាគារតាម online banking system ដើម្បីសម្របសម្រួលការគ្រប់គ្រង ការសង្កេត ការផ្ទេរ និងការទទួលថវិកាអោយមានប្រសិទ្ធិភាពនិងទៀងទាត់។

### ១.៦.១.២. សេវាកម្មប្រាក់បញ្ញើ[9]

ប្រាក់បញ្ញើជារៀលរបស់គ្រឹះស្ថានភាពធនាគារនិងហិរញ្ញវត្ថុបានកើនឡើងដល់ ១.៧ ទ្រីលានរៀល (កើន៦៤% ឆ្នាំលើឆ្នាំ) ដែលរួមចំណែកដោយកំណើនគួរអោយគត់សំគាល់ នៃអត្រាប្រាក់បញ្ញើទូទាត់ (settlement Account Deposit) (១.៧ ដង) និងការកើនឡើងនៃប្រាក់បញ្ញើជាប្រាក់បម្រុងកាតព្វកិច្ចជារៀល។ កំណើនខ្ពស់នៃប្រាក់បញ្ញើទូទាត់បានបង្ហាញថា តម្រូវការប្រាក់រៀលសម្រាប់ប្រតិបត្តិការទូទាត់នៅក្នុងសេដ្ឋកិច្ចមានការកើនឡើង។ ទន្ទឹមនិងនេះ ប្រាក់បញ្ញើជាប្រាក់រៀលកាតព្វកិច្ចជារៀលបានកើនឡើងដោយសារកំណើនប្រាក់បញ្ញើជារៀលរបស់សារធារណៈជូននៅក្នុងប្រព័ន្ធធនាគារដែលបង្ហាញពីកំណើនទំនុកចិត្តលើប្រាក់រៀល។ បើធៀបនិងឆ្នាំ ២០១៤ បញ្ញើជាដុល្លាអាមេរិចបានកើនឡើង ២៥.៥% ជាចម្បងដោយសារកំណើនប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិច។ ការកើនឡើងនេះបណ្ដាលមកពីការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចកំណើនប្រាក់ចំណូល គួបផ្សំនិងការពង្រឹងជំនឿទុកចិត្តលើប្រព័ន្ធធនាគារផងដែរ។

*ក្រាហ្វិក២៖ បង្ហាញពីប្រាក់បញ្ញើស្ថាប័នរដ្ឋ និង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ*



### ១.៦.២. សេវាកម្មប្រាក់បញ្ញើ

#### ១.៦.១.២. វាកម្មក្នុងស្រុក

នៅឆ្នាំ ២០១៥ តម្រូវការលុយរៀលនៅក្នុងសកម្មភាពសេដ្ឋកិច្ចនៅតាមទីក្រុងនិងបណ្តាខេត្តមានការកើនឡើងនូវអត្រាប្រហាក់ប្រហែលទៅនិងឆ្នាំ ២០១៤ ដែរ ហើយយើងក៏អាចឆ្លុះបញ្ចាំងឲ្យឃើញថា កំណើននៃបរិមាណរូបិយវត្ថុដែលបានផ្ទេរពីធនាគារជាតិទៅបណ្តាសាខាធនាគារជាតិផ្សេងទៀត។ ការវេរលុយចេញទៅសាខាតាមខេត្តរបស់ធនាគារ កណ្តាលគឺមានការកើនឡើង ៥% ហើយការវេរលុយចូលធនាគារជាតិមាន ៣ %។ ម្យ៉ាងទៀត ការវេរលុយចេញជាប្រាក់ដុល្លារគឺមាន ៧៧% បើធៀបនិងឆ្នាំចាស់ ខណៈពេលដែលការវេរលុយចូលមានការកើនឡើង ១៣.៥% ឆ្លើយតបទៅនិង សកម្មភាពសេដ្ឋកិច្ចទូទាំងប្រទេស។

*ក្រាហ្វិក ៣៖ បង្ហាញពីការវេរលុយក្នុងស្រុករបស់ធនាគារជាតិនៃកម្ពុជា*




#### ១.៦.២.២. សេវាកម្មវេលុយក្រៅស្រុក

ការវេរលុយពីបរទេសមកចូលធនាគារជាតិនៃកម្ពុជា ជាប្រាក់រៀលដុល្លារបានកើនឡើងជាង ១០០% នៅឆ្នាំ ២០១៥ ខណៈពេលដែលការវេលុយទៅក្រៅបានធ្លាក់ចុះ២%។ កំណើនដ៏ខ្ពស់

នៃការវេលុយដុល្លាទៅក្រៅស្រុកនេះបានបង្ហាញអោយឃើញថា ការហូរចូលនៃលំហូរមូលធនទៅក្នុងប្រទេសកម្ពុជានេះគឺធ្វើអោយមានការវិត្តិនៃសកម្មភាពសេដ្ឋកិច្ច។ តែទោះបីជាយ៉ាងណាក៏ដោយ វាមិនមានឥទ្ធិពលទៅលើកម្រិតនៃដំណើរការធ្វើប្រាក់ដុល្លារូបនីយកម្មនៅប្រទេសកកម្ពុជាដែរ។ ម្យ៉ាងទៀត ការវេលុយផ្សេងទៀតដូចជា ប្រាក់អឺរូ ដុល្លាអូស្ត្រាលី លុយយេន លុយជោននិង Yuan បានកើនឡើងអោយគត់សម្គាល់ដែរ។

### ១.៦.៣. សកម្មភាពទូទាត់

មានសមាជិកចំនួន៣៨ នៅក្នុងអង្គភាពទូទាត់ថ្នាក់ជាតិនិងមជ្ឈមណ្ឌលដោះដូរមូលបត្រនៅសាខារបស់ធនាគារជាតិ ដែលមាន ១៩ កន្លែងនៅខេត្តសៀមរាប ១៤ នៅក្រុងព្រះសីហនុ ១៣ នៅបាត់ដំបង ១២ នៅកំពង់ចាម៥ នៅស្វាយរៀងនិង៤ នៅបន្ទាយមានជ័យ។ នៅឆ្នាំ ២០១៥ ការទូទាត់មូលបត្របានធ្វើឡើងក្នុងរយៈពេល ២៣៣ថ្ងៃ។

#### ១.៦.៣.១. ការទូទាត់មូលបត្រប្រាក់រៀល

ការជឿទុកចិត្តរបស់សាធារណៈក្នុងប្រព័ន្ធធនាគារ គឺជាកត្តាសំខាន់មួយដែលបន្តកំណើនសកម្មភាពទូទាត់នៅគ្រឹះស្ថានទូទាត់ថ្នាក់ជាតិ ដែលមានតួនាទីសកម្មនិងមានសារៈសំខាន់ក្នុងការសម្របសម្រួលប្រតិបត្តិការទូទាត់តាមរយៈប្រព័ន្ធធនាគារ។ តួនាទីទាំងនេះត្រូវបានបង្ហាញយ៉ាងច្បាស់ តាមរយៈការកើនឡើងនូវចំនួនមូលបត្រដែលទូទាត់ជាប្រាក់ដុល្លារ និង ប្រាក់រៀល។

*ក្រាហ្វិក៤៖ បង្ហាញពីចំនួនមូលបត្រគិតជារៀល និង ដុល្លា ពីឆ្នាំ ២០១២-២០១៥*




៣២២០៤ ប្រតិបត្តិការស្មើនិង៩៣៩៤០លានដុល្លាអាមេរិច។ បើធៀបនិងរយៈពេលដូចគ្នាឆ្នាំមុន ចំនួនប្រតិបត្តិការណ៍បានកើនឡើង៥៤ % និងចំនួនប្រាក់កើនឡើង១២%។

*ក្រាហ្វិក៥៖ បង្ហាញពីចំនួនប្រតិបត្តិការបញ្ញាផ្ទេរឥណទាននៅឆ្នាំ ២០១៤-២០១៥*







បានកាត់បន្ថយការចំណាយប្រតិបត្តិការ បង្កើននូវប្រសិទ្ធិភាពក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងសម្រួលលំហូរសន្ទនីយភាពក្នុងទីផ្សារហិរញ្ញវត្ថុ។

បន្ទាប់ពីបានដាក់អោយដំណើរការនូវប្រព័ន្ធផាត់ទាត់ជាតិកាលពីចុងឆ្នាំ២០១២ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍន៍និងភាពរីកចម្រើននៃទីផ្សារកន្លងមក ប្រព័ន្ធនេះបានជួយសម្រួលដល់ការផាត់ទាត់ជាលក្ខណៈមជ្ឈការលើប្រតិបត្តិការអន្តរធនាគារ តាមរយៈមូលប្បទានបត្រនិងបញ្ជទូទាត់អេឡិចត្រូនិច។ បន្ថែមពីនេះការដាក់អោយដំណើរការប្រព័ន្ធនេះ បានធ្វើអោយមានការបញ្ជូនទិន្នន័យផាត់ទាត់រវាងសភាផាត់ទាត់ជាតិ និងធនាគារសមាជិកកាន់តែរហ័សនិងមានសុវត្ថិភាព ជាពិសេសជម្រុញការទូទាត់ជាអេឡិចត្រូនិចតាមរយៈ Credit remittance ដែលបច្ចុប្បន្នមាននិន្នាការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

នៅក្នុងឆ្នាំ ២០១៥នេះ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍន៍និងកំពុងរៀបចំដាក់ អោយប្រើប្រាស់ប្រព័ន្ធ FAST ក្នុងគោលបំណងជំរុញការប្រើប្រាស់ប្រាក់រៀល និងការទូទាត់សងប្រាក់ជាអេឡិចត្រូនិចអោយកាន់តែមានប្រសិទ្ធិភាព ព្រមទាំងលើកកម្ពស់ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅកម្ពុជា។ ប្រព័ន្ធនេះអនុញ្ញាតអោយអតិថិជនជាអ្នកអាចទទួលផលមូលនិធិភ្លាមៗ (real time)។ ដើម្បីជម្រុញការដាក់ប្រព័ន្ធ FAST អោយដំណើរការបានឆាប់រហ័ស ធនាគារជាតិនៃកម្ពុជាបានជួបប្រជុំជាច្រើនលើកជាមួយគ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើលើគោលនយោបាយ និងបច្ចេកទេសនិងការកំណត់នូវគ្រឹះស្ថានដែលបានត្រៀមខ្លួនក្នុងការអនុវត្តធ្វើសន្ទានកម្មប្រព័ន្ធ ក្នុងនាមជា សមាជិកស្ថាបនិកប្រព័ន្ធ។ ប្រព័ន្ធ FAST នេះត្រូវបានរំពឹងទុកថានិងដាក់អោយដំណើរការបាននៅពេលខាងមុខ។

ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាបាននឹងកំពុងរៀបចំអភិវឌ្ឍ National Shared Switch ដែលជាប្រព័ន្ធរួមបញ្ចូលគ្នាមួយសម្រាប់សម្រួលដល់ប្រតិបត្តិការទូទាត់អន្តរធនាគារ តាមរយៈម៉ាស៊ីន ATM ម៉ាស៊ីន POS ក្នុងគោលដៅបង្កើននូវប្រសិទ្ធិភាពសេវាទូទាត់ កាត់បន្ថយចរាចរសាច់ប្រាក់នៅលើទីផ្សារដែលនឹងអាចរួមចំណែកយ៉ាងសកម្ម ក្នុងគោល នយោបាយលើកកម្ពស់ ការ

ប្រើប្រាស់ប្រាក់រៀលរបស់រដ្ឋាភិបាល និងដើម្បីឆ្លើយតបទៅនឹងតម្រូវការសមាហរណកម្មអាស៊ាន នៅពេលខាងមុខ។[10]

ក្នុងនាមជាអាជ្ញាធរគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធទូទាត់និងសេវាទូទាត់សងប្រាក់ធនាគារជាតិនៃកម្ពុជា បានពង្រឹងក្របខណ្ឌបទបញ្ញត្តិលើប្រព័ន្ធទូទាត់ដើម្បីធានាអោយបាននូវប្រសិទ្ធិភាព និងប្រសិទ្ធិភាពនៃប្រព័ន្ធទូទាត់ក្នុងនោះរួមមានៈ

១)ប្រកាសស្តីពីការទទួលស្គាល់និងការផ្សព្វផ្សាយសេវាទូទាត់សងប្រាក់ពាណិជ្ជកម្មឆ្លងប្រទេស

២) ប្រកាសស្តីពីការការពារអតិថិជនសម្រាប់ប្រតិបត្តិការទូទាត់អេឡិចត្រូនិច

៣) និតិវិធីនិងវិធានសម្រាប់ប្រព័ន្ធFAST

៤) កិច្ចព្រមព្រៀងសេវាផ្ទេរប្រាក់ Online ជាដើម។

ធនាគារជាតិនៃកម្ពុជាកំពុងតែពិនិត្យលទ្ធភាពក្នុងការរៀបចំប្រកាសដើម្បី គ្រប់គ្រងផ្គត់ផ្គង់សេវាទូទាត់សងប្រាក់ស្ថាប័នដែលចេញផ្សាយ E-money និងស្ថាប័នដែលជាប្រតិបត្តិករប្រព័ន្ធទូទាត់សងប្រាក់ផងដែរ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមជាមួយក្រសួងពាណិជ្ជកម្មក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច" និងបានសហការជាមួយ UNCITRIAL រៀបចំសិក្ខាសាលាលើប្រធានបទស្តីពី ក្របខណ្ឌគតិយុត្តិសម្រាប់ពាណិជ្ជកម្មនិងការទូទាត់សងប្រាក់ជាអេឡិចត្រូនិចប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធិភាព។

### ១.៦.៥. សេវាកម្មឥណទាន

ការអនុវត្តតាមប្រកាសស្តីពី "ការផ្តល់សន្ទនីយភាពជូនសមាជិកសភាផាត់ទាត់ជាតិ" ធនាគារជាតិនៃកម្ពុជា បានចុះកិច្ចសន្យាផ្តល់ឥណទានវិបារូបន៍ជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក។ ចំពោះគ្រឹះស្ថានធនាគារជាសមាជិកសភាផាត់ទាត់សរុបចំនួន ៣៧ ធនាគារក្នុងនោះ ធនាគារចំនួន ២៥ បានចុះកិច្ចសន្យាឥណទានវិបារូបន៍ជាប្រាក់រៀលផងនិងជាប្រាក់ដុល្លារអាមេរិកផង ហើយធនាគារចំនួន ១២ទៀត បានចុះកិច្ចសន្យាឥណទានវិបារូបន៍តែជាប្រាក់ដុល្លាររអាមេរិកប៉ុណ្ណោះ។ ក្នុងឆមាសនេះ ធនាគារជាតិនៃកម្ពុជាបានចុះកិច្ចសន្យាផ្តល់ឥណទានវិបារូប៍ជាប្រាក់ដុល្លារអាមេរិច ចំនួន ១៧៩ លានដុល្លារអាមេរិចនិងជាប្រាក់រៀលចំនួន ២៣១.៧០២ លានរៀល ហើយធនាគារតែ ២ ប៉ុន្នោះដែលបានប្រើប្រាស់ឥណទានវិបារូន៍ជា ប្រាក់រៀលមានចំនួន ១.៤០០ លានរៀលនិងជាប្រាក់ដុល្លាអាមេរិចមានចំនួន ៣.៥ លានដុល្លាអាមេរិច។

*ក្រាហ្វិក៦៖ បង្ហាញពីទំហំឥណទានស្នើសុំ*



## ១.៦.៦. ការអនុវត្តនៃកម្ចីនិងជំនួយឥតសំណង

### ១.៦.៦.១. ហិរញ្ញប្បទានឥណទានឥតសំណងក្នុងគម្រោង

ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើ Banking Arrangement សម្រាប់ ហិរញ្ញប្បទានឥតសំណងថ្មីបន្ថែមទៀតចំនួន ៣ គម្រោង គឺ៖

១) គម្រោងពង្រីកផ្លូវជាតិលេខ១

២) គម្រោងកែលម្អមន្ទីរពេទ្យនៅខេត្តស្វាយរៀង

៣)គម្រោងជួយសម្រួលប្រព័ន្ធចរាចរណ៍នៅក្នុងភ្នំពេញ។

ដោយឡែក គម្រោងហិរញ្ញប្បទានមានចំនួន ៨ គម្រោងដែលទទួលបានពីមុនមកហើយកំពុងត្រូវបានអនុវត្តមាន៖

- គម្រោងអាហារូបករណ៍អភិវឌ្ឍធនធានមនុស្ស
- គម្រោងពង្រីកមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក
- គម្រោងពង្រីកផ្លូវជាតិលេខ១
- គម្រោងកែលម្អសម្ភារៈបរិក្ខារនៃការស្តារឡើងវិញនូវស្ពានហាលខាងលិចប្រាសាទអង្គរវត្ត
- គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តកំពង់ចាមនិងបាត់ដំបង
- គម្រោងកសាងនិងស្តារឡើងវិញនូវវារីអគ្គិសនីខ្នាតតូចក្នុងខេត្តរតនៈគីរី
- គម្រោងការពារទឹកជំនន់ក្នុងរាជធានីភ្នំពេញជំហានទី ៣
- គម្រោងបំពាក់ឧបករណ៍សម្រាប់សកម្មភាពបោសសម្អាតមីនជំហានទី៦

លើសពីនេះទៅទៀត មានគម្រោងចំនួន៥ ត្រូវបានបញ្ចប់ជាស្ថាពររួមមាន៖

១) គម្រោងសាងសង់ស្ពានអ្នកលឿង

២) គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស

៣) គម្រោងស្តារនិងកាត់បន្ថយគ្រោះមហន្តរាយដោយសារទឹកជំនន់

៤) គម្រោងកែលម្អពេទ្យបង្អែកខេត្តព្រះសីហនុ

៥)គម្រោងសាងសង់អាគារមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រនិងបំពាក់បរិក្ខារមន្ទីរពិ សោធន៍នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

### ១.៦.៦.២. កម្ចីសម្បទានបរទេស

ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខា Banking Arrangement ដើម្បីទូទាត់ប្រាក់កម្ចីសម្បទានថ្មីចំនួន ៣ គម្រោងបន្ថែមទៀតរួមមាន៖

១/គម្រោងស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រពនិងប្រព័ន្ធរំដោះទឹកនៅតំបន់ខាងត្បូងរាជធានីភ្នំពេញ

២ /គម្រោងពង្រីកបណ្តាញខ្សែបញ្ជូលរាជធានីភ្នំពេញ

៣/ គម្រោងស្តារឡើងវិញនូវកំណាត់ផ្លូវជាតិលេខ៥ ព្រែកក្តាមនិងថ្លាម្អម

## ១.៦.៧. ការគ្រប់គ្រងចរាចរណ៍ធនបត្រ

### ១.៦.៧.១. សកម្មភាពបេឡាប្រតិបត្តិការ

ការទទួលសាច់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជាបានកើនឡើង១៨.៥ ភាគរយ ធៀបនិងឆ្នាំ២០១៤ ដោយសារកំណើននៃការបញ្ចូលសាច់ប្រាក់ពីឃ្លាំងសម្របសម្រួលបោះផ្សាយ ១៦.៥ភាគរយ ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ៤៣.៩ភាគរយ ប្រាក់បញ្ញើអគ្គីសនីកម្ពុជា១០.៩ ភាគរយ ប្រាក់បញ្ញើអាជីវករ ១០.៦ភាគរយ ការទទួលសាច់ប្រាក់ពីសាខាធនាគារជាតិនៃកម្ពុជាតាមរាជធានីខេត្ត ១.២ភាគរយ និងការទទួលសាច់ប្រាក់ពីស្ថប័នផ្សេងៗ ៣២.១ ភាគរយ ខណៈដែលប្រាក់បញ្ញើរតនាគារជាតិបានថយចុះ ២២.៦ ភាគរយ។

ចំណែកឯការបើកប្រាក់រៀលវិញកើនឡើង ១៨.៤ ភាគរយ ធៀបនិងឆ្នាំ ២០១៤ ដោយសារកំណើនការបញ្ចេញសាច់ប្រាក់ទៅឃ្លាំងសម្របសម្រួលបោះផ្សាយ ៣៣.២ ភាគរយ ការដកប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥៥.៣ ភាគរយ សាខាធនាគារជាតិនៃកម្ពុជារាជធានីខេត្ត ៤៣.៣ ភាគរយ និងការដកប្រាក់ពីស្ថាប័នផ្សេងៗ ២៦ ភាគរយ ខណៈដែលការដកប្រាក់បញ្ញើរតនាគារជាតិបានថយចុះ ១១.៨ ភាគរយ និងការដកប្រាក់បញ្ញើអាជីវករ ៣៩.១ ភាគរយ។

*ក្រាហ្វិក៧ ៖ បង្ហាញពីការទទួលនិងបើកសាច់ប្រាក់រៀល*




៨.៩%

ដូចគ្ន

### ១.៦.៧.២. ការគ្រប់គ្រងសាច់ប្រាក់[11]

ធនាគារជាតិនៃកម្ពុជា បានបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលអោយបានកាន់តែទូលំទូលាយជាប់ជាប្រចាំ តាមរយៈការប្រមូលនិងកម្ទេចក្រដាសប្រាក់ចាស់ ទក់ រហែក និងជំនួសដោយក្រដាសប្រាក់ថ្មីៗ ជាក់ស្តែង ការរាប់ក្រដាសប្រាក់បានកើនឡើង ៤០ ភាគរយ ការដូរ

11 ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា

ក្រដាសប្រាក់ចាស់ ទក់ រហែក បានកើនឡើង ១២.៤ ភាគរយ ការកាត់កម្ទេចនិងដុតបំផ្លាញចោល ក្រដាសប្រាក់ចាស់ ទក រហែកកើនឡើង ១៩.៦ ភាគរយធៀបនឹងឆ្នាំ ២០១៤។

*ក្រាហ្វិក៨ ៖ បង្ហាញពីការងារការគ្រប់គ្រងសាច់ប្រាក់រៀល*




តាមដាននិងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចជាប្រចាំ។ ជាក់ស្តែងធនាគារជាតិនៃកម្ពុជាបានដកហូតប្រាក់រៀលក្លែងក្លាយប្រភេទថតចម្លងចំនួន ១៦៨ សន្លឹកនិងក្រដាសប្រាក់ដុល្លារអាមេរិចក្លែងក្លាយចំនួន ៤២១ សន្លឹក។

នៅឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយក្រដាសប្រាក់រៀលគំរូថ្មីចំនួន ៣ ប្រភេទ និងបានបោះកាក់អនុស្សាវរីយ៍អាស៊ានផងដែរ៖

- ❖ ប្រភេទ ១០០រៀល និង ៥០០រៀល បោះផ្សាយថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៥ ដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ ការដាក់អោយប្រើប្រាស់ស្ពានមិត្តភាពកម្ពុជា-ជប៉ុន អ្នកលឿង និងខួបអនុស្សាវរីយ៍លើទី៣៥ឆ្នាំ នៃប្រតិបត្តិការធនាគារកណ្តាល។
- ❖ ប្រភេទ ១០០០០រៀល បោះផ្សាយនៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៥ ដើម្បីអបអរសាទរព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
- ❖ បោះកាក់អនុស្សាវរីយ៍អាស៊ាន ដើម្បីចូលរួមអបអរសាទរការបង្កើតសហគមន៍ សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ ២០១៥។

# ជំពូក ២

# រំលឹកទ្រឹស្តី

# ជំពូក ២
# រំលឹកទ្រឹស្តី

## ២.១. និយមន័យធនាគារជាតិ[12]

និយមន័យធនាគារជាតិគឺជាអាជ្ញាធររូបិយ គឺជាអាជ្ញាធររូបិយវត្ថុនៃប្រទេសមួយដែលត្រួតពិនិត្យលើការផ្គត់ផ្គង់រូបិយវត្ថុជាតិនិង ឥណទានបោះពុម្ពផ្សាយរូបិជាតិនិងធ្វើការគ្រប់គ្រងអត្រាប្តូរប្រាក់ (ច័ន្ទវិទ្ធី ២០១២) ។

ធនាគារជាតិ គឺជាស្ថាប័នមួយនៅក្នុងរចនាសម្ព័ន្ធធនាគារដែលក្នុងប្រទេសមួយ។ ធនាគារជាតិជាអ្នកត្រួតពិនិត្យនៅរាល់សកម្មភាពរបស់ធនាគារពាណិជ្ជទាំងឡាយនិងដើរតួនាទីជា ធនាគារសម្រាប់ធនាគារពាណិជ្ជទាំងអស់។ ម៉្យាងទៀត ធនាគារកណ្តាលដើរតួជាភ្នាក់ងារ និងជាអ្នកផ្តល់ដំបូន្មានដល់រដ្ឋាភិបាលក្នុងបញ្ហាហិរញ្ញវត្ថុ។ ធនាគារកណ្តាលគឺជាអ្នកដែលធ្វើអោយមានសមតុល្យបរទេសនៅក្នុងប្រទេសនិងទទួលខុសត្រូវចំពោះការរក្សាអត្រាប្តូរប្រាក់។ តួនាទីរបស់ធនាគារកណ្តាលគឺ ត្រួតពិនិត្យនូវបរិមាណរូបិយវត្ថុនៅក្នុងប្រទេស។

ចំណែកលោក Hyman P. Minsky (2008) បានអោយនិយមន័យដល់ធនាគារកណ្តាលថាជាស្ថាប័នដែលទទួលខុសត្រូវចំពោះរាល់ការការពារនូវរាល់បញ្ហា ដែលបណ្តាលអោយមានអស្ថិរភាពហិរញ្ញវត្ថុ ហើយការត្រួតពិនិត្យជាប្រចាំរបស់ធនាគារកណ្តាលទៅលើធនាគារពាណិជ្ជ ឬ ក៏រូបិយវត្ថុ ហើយធនាគារកណ្តាលក៏ជាអ្នកផ្តល់កម្ចីចុងក្រោយបង្អស់ដល់រាល់ធនាគារពាណិជ្ជផងដែរ ។

ដូចនេះជារួម ធនាគារជាតិ គឺជាអង្គភាពហិរញ្ញវត្ថុដ៏ធំមួយឬ ជាអាជ្ញាធរហិរញ្ញវត្ថុនៃប្រទេសដែលមានតួនាទីឯករាជ្យបោះផ្សាយក្រដាសប្រាក់ និងគ្រប់គ្រងប្រតិបត្តិការនានាស្តីពីរូបិយវត្ថុ ឥណទាន និង ធនាគារដោយមានគោលបំណងរក្សាតម្លៃរូបិយវត្ថុ និង ស្ថិរភាពប្រព័ន្ធធនាគារ។

## ២.២. លក្ខណៈពិសេសរបស់ធនាគារជាតិនៃកម្ពុជា

ធនាគារកណ្តាល គឺជាប្រភេទធនាគារមួយដែលជាកម្មសិទ្ធរបស់រដ្ឋមានតួនាទី ឯករាជ្យបោះផ្សាយក្រដាសប្រាក់ និង គ្រប់គ្រងប្រតិបត្តិការនានាស្តីពីរូបិយវត្ថុ ឥណទាន និងធនាគារដោយមានគោលបំណងរក្សាតម្លៃរូបិយវត្ថុជាតិ និងស្ថានភាពប្រព័ន្ធធនាគារ។ តាមរយៈលក្ខណៈនេះធនាគារកណ្តាលបានអនុវត្តនូវឧបករណ៍សំខាន់បំផុត គឺគោលនយោបាយរូប័យវត្ថុពីព្រោះធនាគារកណ្តាលមានតួនាទីពិសេសក្នុងការគ្រប់គ្រង និងអនុវត្តម៉ាក្រូសេដ្ឋកិច្ចទូទាំងប្រទេស។

[12] ងួន ហេង *រូបិយវត្ថុនិងធនាគារ* ឆ្នាំ២០១៣

មកដល់បច្ចុប្បន្ននេះ នៅលើពិភពលោកមានការរៀបចំរចនាសម្ព័ន្ធធនាគារកណ្តាលជា ២ ប្រភេទគឺ ៖

- ❖ ធនាគារកណ្តាលមិនមែនអាស្រ័យលើការគ្រប់គ្រងរបស់រដ្ឋាភិបាលទេ គឺស្វ័យតមានន័យថាធនាគារកណ្តាលអនុវត្តប្រតិបត្តិការរបស់ខ្លួនដោយឯករាជ្យពីរដ្ឋាភិបាល។
- ❖ ប្រសិនបើធនាគារកណ្តាលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលនោះ រដ្ឋាភិបាលអាចបោះផ្សាយក្រដាសប្រាក់តាមអំពើចិត្ត ដើម្បីទប់ស្កាត់ឱនភាពជញ្ជីងពាណិជ្ជកម្មទូទាត់ថវិការរដ្ឋ។ នេះជាកត្តាមួយដែលអាចបណ្តាលអោយមានអតិផរណាផងដែរព្រោះក្រដាសប្រាក់ដែលចរាចរលើទីផ្សារមានច្រើនហួសហេតុពេក។ ពេលនោះធនាគារកណ្តាលមិនអាចអនុវត្តនូវនយោបាយរូបិយវត្ថុ និងរក្សាលំនឹងរូបិយវត្ថុជាតិអោយបានពេញទំហឹងនោះទេ។ ការរៀបចំបែបនេះមាននៅដូចជា ប្រទេសអាមេរិច និង អាល្លឺម៉ងជាដើម។

## ២.៣. មូលហេតុដែលនាំអោយមានការត្រួតពិនិត្យទៅលើធនាគារពាណិជ្ជ[13]

វិស័យហិរញ្ញវត្ថុរបស់ប្រទេសមួយជាកត្តាសំខាន់ក្នុងការអភិវឌ្ឍន៍ជាតិខ្លួន។ ធនាគារមានតួនាទីយ៉ាងសំខាន់ ជាពិសេសគឺជាអន្តរការិយហិរញ្ញវត្ថុ ពោលគឺប្រមូលនិធិភ្នាប់ពីភ្នាក់ងារដែលមានសាច់ប្រាក់ងាយស្រួលនៅទំនេរ ឬ លើសទៅអោយភ្នាក់ងារដែលមានតម្រូវការសាច់ប្រាក់។ ដូចជាលោក Joseph Schumpeter (1996) បានលើកឡើងថា "ធនាគារឹកមិនមែនត្រឹមតែជាការីប៉ុណ្ណោះទេ ប៉ុន្តែធនាគារឹកផ្តល់លទ្ធភាពអោយមនុស្សធ្វើការច្នៃប្រឌិតបម្រើសង្គម "។

វាមានការលំបាកណាស់ក្នុងការប្រមូលនិធិដែលលើសលុបទាំងនោះ ចូលមកក្នុងប្រព័ន្ធធនាគារ ដូចនេះធនាគារត្រូវមានយុទ្ធសាស្ត្រទីផ្សារដើម្បីទាក់ទាញម្ចាស់មូលនិធិដោយផ្តល់អត្រាការប្រាក់ខ្ពស់ និង ផ្តល់សេវាកម្មទំនើបផ្សេងៗដូចជា ប័ណ្ណឥណទាន មូលប្បទានប័ត្រ ប្រតិបត្តិការ on-line ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) ជាដើម។ ទន្ទឹមគ្នានេះដែរ ធនាគារក៏ត្រូវបង្កើតយុទ្ធសាស្ត្រទាក់ទាញអ្នកខ្ចីប្រាក់ ដើម្បីទទួលបានផលចំនេញពីការប្រើប្រាស់មូលនិធិដែលបានដាក់ផ្ញើ។

ការទទួលប្រាក់បញ្ញើនិងផ្តល់ប្រាក់កម្ចី ជាកិច្ចការមួយមើលទៅហាក់ដូចជាមានភាពងាយស្រួល ប៉ុន្តែប្រតិបត្តិការធនាគារប្រព្រឹត្តទៅអាចប្រឈមមុខនឹងហានិភ័យ។ ធនាគារកណ្តាលដែលអាជ្ញាធរបញ្ញត្តិករបានយកចិត្តទុកដាក់យ៉ាងខ្លាំង លើដំណើរការអាជីវកម្មរបស់ធនាគារដោយសារហេតុផលដូចខាងក្រោម៖

- ❖ ធនាគារធ្វើអាជីវកម្មដោយប្រើប្រាស់ប្រភពមូលនិធិ ដែលជាប្រាក់បញ្ញើរបស់អតិថិជន ឬ សាធារណជន និងទឹកប្រាក់មួយភាគច្រើន បានមកពីមូលនិធិរបស់ម្ចាស់ធនាគារ។ ការព្រួយបារម្ភរបស់អាជ្ញាធរត្រួតពិនិត្យ គឺធ្វើយ៉ាងណាអោយម្ចាស់ប្រាក់បញ្ញើមានលទ្ធភាពដក

13 របាយការណ៍សារណារបស់និស្សិត ៣៧ មករា (តួនាទីរបស់ធនាគារជាតិនៃកម្ពុជា

ប្រាក់សរុបពួកគេ ពីប្រព័ន្ធធនាគារវិញតាមតម្រូវការនិងដើម្បីការពារកុំអោយធនាគារ ធ្វើការផ្ទេរហានិភ័យនៃអាជីវកម្មរបស់ពួកគេអោយម្ចាសបញ្ញើ។

- ❖ ការដួលរលំធនាគារអាចជះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ចប្រទេសជាតិ។ ពេលម្ចាស់ប្រាក់បញ្ញើបាត់បង់ជំនឿទុកចិត្តលើប្រព័ន្ធធនាគារ សេដ្ឋកិច្ចជាតិទាំងមូលត្រូវរងការខូចខាតដែលបណ្តាលមកពីកង្វះទុននិងកិត្តិស័ព្ទរបស់ប្រទេស ចំពោះវិនិយោគបរទេស។ នៅក្នុងសង្គមមួយដែលគេទទួលស្គាល់ថាវិស័យធនាគារ ជាវិស័យមួយសំខាន់សម្រាប់ការប្រកបជំនួញ នោះកង្វះខាតវិស័យធនាគារនៅក្នុងស្រុកជាកត្តារុញច្រានវិនិយោគិនអោយចាកចេញពីប្រទេស ឬ មិនមកធ្វើការវិនិយោគ។ ការប្រើប្រាស់ប្រព័ន្ធធនាគារជាមធ្យោបាយមួយសម្រាប់ជំនួញ ក្នុងការកាត់បន្ថយហានិភ័យសាច់ប្រាក់ងាយស្រួល ជួយសម្រួលដល់ការធ្វើហិរញ្ញប្បទានពង្រីកអាជីវកម្មការដោះដូរទំនិញ និងសេវាអោយមានភាពងាយរលូន។
- ❖ ការប្រយុទ្ធប្រឆាំងនឹងការសម្អាតប្រាក់ និង ការធ្វើហិរញ្ញប្បទានភេរវកម្ម អំពើពុករលួយ និងសកម្មភាពខុសច្បាប់ផ្សេងៗ អាចប្រព្រឹត្តទៅបានយ៉ាងងាយស្រួលប្រសិនបើសាច់ប្រាក់ត្រូវបានចរាចរដោយសេរី នៅក្នុងសេដ្ឋកិច្ចដោយមិនឆ្លងកាត់ប្រព័ន្ធ ធនាគារ។ សកម្មភាពឧក្រិដ្ឋផ្សេងៗអាចត្រូវបានកាត់បន្ថយមួយកម្រិត ប្រសិនបើសាច់ប្រាក់ និងទ្រព្យសម្បត្តិមានតម្លៃត្រូវបានរក្សាទុកនៅកន្លែងមានសុវត្ថិភាព ដែលមានអត្ថប្រយោជន៍ទាំងរូបវន្ត និងទាំងសេដ្ឋកិច្ចផង។
- ❖ ប្រព័ន្ធធនាគារគ្មានប្រសិទ្ធិភាព អាចបង្កការលំបាកដល់ធនាគារកណ្តាលក្នុងការ អនុវត្តគោលនយោបាយរូបិយវត្ថុក្នុងគោលដៅ ថែរក្សាស្ថិរភាពថ្លៃអាចមានភាពស្មុគស្មាញ។
- ❖ វត្តមាននៃប្រព័ន្ធធនាគារប្រកបដោយភាពរឹងមាំ និងមានសុវត្ថិភាពគឺជាសូចនាករដ៏ល្អស្តីពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសជាតិទាំងមូលឲ្យមានការរីកចម្រើនឆាប់រហ័ស។

## ២.៤. ធនាគារពាណិជ្ជ[14]

### ២.៤.១. ការវិវត្តិរបស់ធនាគារពាណិជ្ជ

ធនាគារបានចាប់ផ្តើមកើតឡើងតាមរយៈមុខងារប្តូរលុយរបស់ជាងមាស។ ចំពោះការធ្វើចរាចរលុយនៅក្នុងប្រទេសនីមួយៗ និងក្នុងតំបន់នីមួយៗជាពិសេសចំពោះពាណិជ្ជកម្មអន្តរជាតិទាមទារអោយមាន ការប្តូរប្រាក់នៅតាមច្រកព្រំដែនដើម្បីងាយស្រួលក្នុងការទិញលក់ទំនិញ។ ដូច្នេះគេត្រូវបង្កើតហាងប្តូរប្រាក់ ដើម្បីធ្វើការជួញដូរនូវរូបិយប័ណ្ណរបស់ប្រទេសមួយជាមួយនិងរូបិយប័ណ្ណប្រទេសផ្សេងទៀត។ ចំពោះជាងមាសដែលប្រកបរបរប្តូរប្រាក់ទាំងនោះ (ជាក្រដាសប្រាក់) បានបង្កើតមុខរបរមួយទៀតគឺ រក្សាទុកលុយអោយអ្នកដែលមកផ្ញើរ។ ពីមួយថ្ងៃទៅមួយថ្ងៃពួកគេកាន់តែមានចំណូលខ្ពស់ឡើងៗដោយសារមានពាណិជ្ជករ យកប្រាក់មកផ្ញើកាន់តែច្រើន។

---

14 គេហទំព័ររបស់ធនាជាតិ www.nbc.org.kh

ពេលនោះម្ចាស់ហាងមាសមានតួនាទីជាអ្នកប្តូរប្រាក់ ទូទាត់ជំនួស រក្សាលុយទុក អោយ និង បោះពុម្ពលុយ។ ហើយធនាគារប្រភេទនេះហៅថា ធនាគារជាងមាស។ ដំបូង បណ្តាធនាគារប្រភេទនេះបានប្រើប្រាស់មូលធនផ្ទាល់ខ្លួននៅក្នុងប្រតិបត្តិការរបស់គេ ប៉ុន្តែកត្តានេះមិនអាចស្ថិតស្ថេរបានយូរទេ។ តាមរយៈប្រតិបត្តិការជាក់ស្តែង ម្ចាស់ធនាគារយល់ថា ជានិច្ចកាលអ្នកផ្ញើលុយ និងអ្នកខ្ចីលុយមិនដកលុយព្រមគ្នាទេ ដូច្នេះហើយបានជាធ្វើអោយបរិមាណលុយសល់នៅធនាគារច្រើន។ ដូចនេះម្ចាស់ធនាគារក៏យកលុយមកផ្តល់កម្ចីបន្ថែម។ ប្រតិបត្តិការប្រាក់កម្ចីបានបង្កើនប្រាក់ចំណេញកាន់តែច្រើនឡើងៗ។ មួយវិញទៀត ធនាគារបានផ្តល់ប្រាក់កម្ចីម៉្យាងដែលអនុញ្ញាតអោយអតិថិជនធ្វើការចាយវាយលើពីប្រាក់ចំនូលរបស់ខ្លួន ហើយការផ្តល់កម្ចីបែបនេះមានហានិភ័យខ្ពស់ណាស់។ កាលណាស្ថានភាពនេះមានកាន់តែច្រើនឡើងធ្វើអោយធនាគារជាច្រើនគ្មានលទ្ធភាពសងបំណុលនិងចុងក្រោយគឺត្រូវក្ស័យធន។

ការក្ស័យធនរបស់ធនាគារទាំងនេះបានជះឥទ្ធិពលអាក្រក់ដល់អ្នកអាជីវកម្ម។ បើទោះជាមានធនាគារដែលមិនទាន់ដួលរលំ ក៏អត្រាការប្រាក់ខ្ពស់ជាហេតុធ្វើអោយពួកគេមិនអាចទទួលយកបាន។ ដូច្នោះហើយ ពួកគេក៏បង្កើតធនាគារដោយខ្លួនឯងដែលហៅថា ធនាគារពាណិជ្ជ។ ធនាគារពាណិជ្ជ ត្រូវបានបង្កើតឡើងដោយពួកអាជីវករ ហើយធនាគារក៏អនុវត្តនូវមុខងារធនាគារមុនដែរគឺទទួលប្រាក់បញ្ញើ ទូទាត់ជំនួស និង ផ្តល់ប្រាក់កម្ចី។ ដើម្បីទប់ស្កាត់ហានិភ័យ ធនាគារនេះគ្រាន់តែផ្តល់កម្ចីរយៈពេលខ្លីតែប៉ុណ្ណោះ គឺមិនផ្តល់កម្ចីរយៈពេលវែងនិងមធ្យមទេ ហើយក៏មិនផ្តល់កម្ចីដល់រដ្ឋាភិបាលដែរ។

តាមរយៈការរីកចម្រើននៃសេដ្ឋកិច្ច និង បច្ចេកទេសបានធ្វើអោយប្រតិបត្តិការរបស់ធនាគារកាន់តែរីកចម្រើនដែរ គឺតាំងពីធនាគារបុគ្គលរហូតដល់បង្កើតបាននូវភាគហ៊ុន។ ក្រោយមកទៀតធនាគារបានផ្តល់កម្ចីរយៈពេលវែងទៀត និងផ្តល់កម្ចីដល់អ្នកប្រើប្រាស់ អ្នកទិញភាគហ៊ុន និងបង្កើតឡើងនូវប្រភេទប្រាក់បញ្ញើជាច្រើនទៅតាមតម្រូវការរបស់អតិថិជន។ ក្រៅពីការទទួលប្រាក់បញ្ញើ ធនាគារនៅសុំខ្ចីលុយពីធនាគារកណ្តាល និង ធនាគារផ្សេងទៀត។

### ២.៤.២. តួនាទីរបស់ធនាគារពាណិជ្ជ[15]

ធនាគារពាណិជ្ជដើរតួយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ចដូចជា៖ អន្តរការិកម្ម តួនាទីទូទាត់ តួនាទីធនាឥណទាន តួនាទីចែករំលែកហានិភ័យ តួនាទីផ្តល់តំបូន្មានសម្រាប់ការវិនិយោគ ឬ សន្សំ និងតួនាទីនយោបាយរបស់រដ្ឋាភិបាល។

#### ២.៤.២.១. អន្តរការិយកម្ម

15 ឃឹម សារិត *ហានិភ័យធនាគារ* ឆ្នាំ ២០១៥

ធនាគារពាណិជ្ជ ជាអ្នកបំលែងសាច់ប្រាក់ពីសាច់ប្រាក់សន្សំដែលទទួលបានពីអ្នកដែលលើសសាច់ប្រាក់ដូចជា អ្នកសន្សំ ឬ អ្នកដាក់ប្រាក់បញ្ញើអោយក្លាយជាសាច់ប្រាក់ឥណទានដល់អ្នកដែលខ្វះសាច់ប្រាក់ដូចជា អ្នកវិនិយោគ គ្រួសារ សហគ្រាស ឬ រដ្ឋាភិបាល។

**២.៤.២.២. តួនាទីទូទាត់**

ធនាគារពាណិជ្ជធ្វើការសម្រួលដល់ការទូទាត់របស់អតិថិជនខ្លួន តាមរយៈការបង្កើតមធ្យោបាយទូទាត់មួយចំនួនដូចជា មូលប្បទានបត្រ និង កាតឥណទានជាដើម។

**២.៤.២.៣. តួនាទីឥណទាន**

ធនាគារពាណិជ្ជ គឺជាអ្នកធានាឥណទានដល់អតិថិជនរបស់ខ្លួនតាមរយៈការបង្កើតឧបករណ៍នានាដូចជា វិបារូបណ៍ និង លិខិតឥណទានជាដើម ដែលការធានាឥណទានច្រើនធ្វើឡើង សម្រាប់ការទូទាត់នាពេលអនាគត។

**២.៤.២.៤. តួនាទីចែករំលែកហានិភ័យ**[16]

ធនាគារពាណិជ្ជអាចបំពេញមុខងារ ចែករំលែកហានិភ័យរបស់អតិថិជនតាមរយៈបទពិសោធន៍ ជំនាញការនិងលក្ខណៈវិជ្ជាជីវៈព្រមទាំងបច្ចេកទេសវិទ្យាព័ត៌មានរបស់ខ្លួន។

**២.៤.២.៦. តួនាទីផ្តល់ដំបូន្មានសម្រាប់ការវិនិយោគនិងសន្សំ**

ធនាគារពាណិជ្ជបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ដំបូន្មានដល់អតិថិជនរបស់ខ្លួនក្នុងការសម្រេចចិត្តវិនិយោគ ឬ សន្សំពីព្រោះតែគាត់មានជំនាញគ្រប់គ្រាន់ផ្នែកហិរញ្ញវត្ថុ។

**២ .៦.២.៤.តួនាទីក្នុងនយោបាយរបស់រដ្ឋាភិបាល**

ធនាគារពាណិជ្ជជួយសម្រួលដល់គោលនយោបាយរដ្ឋាភិបាល ដើម្បីគ្រប់គ្រងការលូតលាស់ផ្នែកសេដ្ឋកិច្ច និង សម្រេចគោលនយោបាយសម្រាប់សង្គម។

**២.៤.៣. ហានិភ័យសំខាន់ៗក្នុងវិស័យធនាគារ**

តាមលក្ខណៈធម្មជាតិ ធនាគារមានទំនាក់ទំនងទៅនឹងការទទួលយកហានិភ័យ ហើយហានិភ័យសំខាន់ៗដែលធនាគារពាណិជ្ជប្រឈមមានដូចខាងក្រោម៖

**២.៤.៣.១. ហានិភ័យឥណទាន**

ការផ្តល់កម្ចីតម្រូវអោយធនាគារធ្វើការវិភាគ លើលទ្ធផលទូទាត់របស់អតិថិជន ប៉ុន្តែរាល់ការវិភាគមិនសុទ្ធតែមានសុក្រិតភាពទេ ដោយសារកត្តាជាច្រើនដែលប្រែប្រួលតាមពេលវេលា។ ធនាគារផ្តល់ឥណទានទៅអោយអតិថិជនដោយព្រមទទួលយកអតិថិជនមានបញ្ហាវិបត្តិហិរញ្ញវត្ថុ ពុំមានលទ្ធភាពក្នុងការទូទាត់ការប្រាក់ ឬ ប្រាក់ដើមមួយភាគ ឬ ទាំងស្រុងតាមកាលដែលបានព្រៀងនោះ

[16] គេហទំព័រ khmernote.com

ធ្វើអោយធនាគាររងការខាតបង់ ហើយជាមូលហេតុឈានទៅរកការក្ស័យធន ដោយសារការចុះថយនៃមូលធន ដែលមិនអាចឆ្លើយតបនឹងការខាតបង់បាន។

**២.៤.៣.២. ហានិភ័យសាច់ប្រាក់ងាយស្រួល**

ធនាគារក៏មានកង្វល់ខ្លាំង អំពីហានិភ័យសាច់ប្រាក់ងាយស្រួលបណ្តាលមកពីធនា-គារមិនមានមូលនិធិគ្រប់គ្រាន់ សម្រាប់បំពេញតាមតម្រូវការប្រាក់មិនបានគ្រោងទុក មានដូចជាការខ្វះខាតសាច់ប្រាក់សម្រាប់បើកអោយអតិថិជនដែលមកដកប្រាក់បញ្ញើ និង បើកប្រាក់កម្ចីដែលធនាគារបានព្រមព្រៀង និង ការផ្លាស់ប្តូរប្រភពមូលនិធិ។ បើធនាគារមិនមានសាច់ប្រាក់សម្រាប់ទូទាត់គ្រប់ពេលវេលាទេ នោះធនាគារនិងត្រូវបាត់បង់ទំនុកចិត្តពីអតិថិជន ហើយអតិជនឈប់ប្រើប្រាស់សេវាកម្មធនាគារនោះទៀត។ ដូចនេះធនាគារត្រូវបង្ខំចិត្តខ្ចីប្រាក់មានអត្រាការប្រាក់ខ្ពស់ពីប្រភពផ្សេងៗដែលជាការចំណាយមួយដែលធ្វើអោយប្រាក់ចំណេញថយចុះ។

**២.៤.៣.៣. ហានិភ័យអត្រាការប្រាក់**

ហានិភ័យអត្រាការប្រាក់កើតឡើងបណ្តាលមកពីការប្រែប្រួលនៃអត្រាការប្រាក់ និង លំហូរសាច់ប្រាក់ទៅតាមកាលវេលាផ្សេងគ្នា។ ការប្រែប្រួលនេះអាចមានឥទ្ធិពលខ្លាំងទៅលើកម្រិតចំណូលធៀបនឹងថ្លៃប្រតិបត្តិការធនាគារតម្លៃនៃទ្រព្យសកម្ម និងឧបករណ៍ក្រៅតារាងតុល្យការ។ កំណើននៃអត្រាការប្រាក់អាចកាត់បន្ថយប្រាក់ចំណេញរបស់ធនាគារ។ ប្រសិនបើ ចំណាយការប្រាក់លើមូលនិធិដែលបានខ្ចីនោះមានទំហំធំជាងចំណូលការប្រាក់លើឥណទាន និង វិនិយោគមូលប័ត្រ។

**២.៤.៣.៤. ហានិភ័យសោធនភាព**[17]

ធនាគារិកមានកង្វល់ដោយផ្ទាល់ ស្តីអំពីហានិភ័យចំពោះការគង់វង្សស្ថិតស្ថេររបស់ស្ថាប័នខ្លួនដែលគេហៅថា ហានិភ័យសោធនភាព។ ប្រសិនបើធនាគារមានបំណុលទានមិនបាន (Bad Debt) ច្រើន ឬ តម្លៃទីផ្សារនៃសញ្ញាប័ណ្ណដែលធនាគារវិនិយោគបានធ្លាក់ចុះ នោះធនាគារទទួលរងការខាតបង់ច្រើន ធ្វើអោយមូលធនធនាគារថយចុះព្រោះត្រូវស្រូបយកការខាតបង់ទាំងឡាយដែលបានកើតឡើង។ ប្រសិនបើអ្នកដាក់បញ្ញើនិងវិនិយោគដឹងពីបញ្ហារបស់ធនាគារ នោះពួកគេនឹងចាប់ផ្តើមដកប្រាក់របស់ពួកគេវិញ ពេលនោះធនាគារអាចប្រឈមមុខនិងការគ្មានលទ្ធភាពសងបំណុលបាន (Insolvency) ហើយអាចឈានដល់ការបិទទ្វារ។

**២.៤.៣.៥. ហានិភ័យទីផ្សារ** (Market Risk)

ហានិភ័យទីផ្សារកើតឡើង ពីការប្រែប្រួលតម្លៃមូលប័ត្រពាណិជ្ជកម្មនៃឧបករណ៍ហិរញ្ញវត្ថុ។ នៅពេលអត្រាការប្រាក់កើនឡើងនោះតម្លៃទីផ្សារ នៃសញ្ញាប័ណ្ណដែលធនាគារបានទិញធ្លាក់ចុះធ្វើ

---

17 ដកស្រង់ចេញរបាយការណ៍ប្រចាំឆ្នាំ២០១៥ របស់ធនាគារជាតិនៃកម្ពុជា

អោយធនាគាររងការខាតបង់។ ផ្ទុយមកវិញ បើអត្រាការប្រាក់ចុះនោះធនាគារទទួលបានចំណេញនៅពេលលក់វាចេញវិញដោយសារតម្លៃសញ្ញាប័ណ្ណកើនឡើង។ និយាយរួមគឺតម្លៃអត្រាការប្រាក់ និងទិសដៅសញ្ញាប័ណ្ណតែងតែផ្ទុយគ្នាជានិច្ច។

### ២.៤.៣.៦. ហានិភ័យអត្រាប្តូរប្រាក់ (Exchange Rate Risk)[18]

ហានិភ័យអត្រាប្តូរប្រាក់ គឺកើតឡើងពីប្រតិបត្តិការប្តូរប្រាក់ពីរូបិយប័ណ្ណមួយទៅរូបិយប័ណ្ណមួយទៀត។ ធនាគារប្រឈមមុខនឹងហានិភ័យនេះដោយសារតែតម្លៃរូបិយប័ណ្ណដែលធនាគារបានទិញលក់ប្រែប្រួលតាមស្ថានភាពទីផ្សារប្តូរប្រាក់។ ធនាគារដែលធ្វើប្រតិបត្តិការទិញលក់រូបិយប័ណ្ណសម្រាប់ខ្លួនផ្ទាល់ឬ សម្រាប់អតិថិជនរបស់ខ្លួនរមែងតែងតែជួបប្រទះនឹងហានិភ័យនៃការឡើងចុះថ្លៃរូបិយប័ណ្ណ ពោលគឺការប្រែប្រួលអត្រាទិញ និងអត្រាលក់រូបិយប័ណ្ណនៅលើទីផ្សារ។

### ២.៤.៣.៧. ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការកើតឡើងពីការបរាជ័យនៃការគ្រប់គ្រង និង សហប្រតិបត្តិការផ្ទៃក្នុង ជំហរក្នុង ការប្រជែង ការគ្រប់គ្រងព័ត៌មាន ការអភិវឌ្ឍន៍បច្ចេកវិទ្យា ព្រមទាំងភាពខ្វះសមត្ថភាពក្នុងការផលិតនិងផ្តល់សេវាកម្មជូនអតិថិជន។

18 ដកស្រង់ចេញពីគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា www.nbc.org.kh

# ជំពូក ៣
# ការអនុវត្តគោល
# នយោបាយរូបិយវត្ថុរបស់
# ធនាគារជាតិនៃកម្ពុជា

# ជំពូក ៣
# ការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា

## ៣.១. ការអនុវត្តនិងដឹងនាំគោលនយោបាយរូបិយវត្ថុ

តាមមាត្រា៣នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជាបានចែងថា "ធនាគារមានបេសកកម្មចម្បងគឺអនុវត្ត និង ដឹងនាំគោលនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនៃនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងរក្សាថ្លៃអោយមានស្ថិរភាពសំដៅបង្កលក្ខណៈងាយស្រួលធ្វើអោយសេដ្ឋកិច្ចមានកំណើនខ្ពស់"។ ក្នុងន័យនេះ ធនាគារកណ្តាលត្រូវធ្វើការងារក្នុងក្របខ័ណ្ឌនៃនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ពោលគឺត្រូវតែមានកិច្ចសហប្រតិបត្តិការរវាងថ្នាក់ដឹងនាំធនាគារជាតិ និងរដ្ឋាភិបាល ដើម្បីអនុវត្តនិង ដឹងនាំគោលនយោបាយរូបិយវត្ថុអោយមានប្រសិទ្ធិភាពបំផុត។

## ៣.២. គោលដៅនៃគោលនយោបាយរូបិយវត្ថុ

### ៣.២.១. ស្ថិរភាពថ្លៃ[19]

គោលដៅនៃគោលនយោបាយរូបិយវត្ថុ គឺធានាស្ថិរភាពថ្លៃដើម្បីបង្កើតអោយមានលក្ខខណ្ឌសមស្របដល់កំណើនសេដ្ឋកិច្ច។ ដូច្នេះគោលនយោបាយរូបិយវត្ថុពុំមានគោលដៅសម្របសម្រួលដោយផ្ទាល់នូវកំណើនសេដ្ឋកិច្ច ឬ ការបង្កើតការងារឡើយ ប៉ុន្តែសម្រាប់ធានាតែស្ថិរភាពថ្លៃប៉ុណ្ណោះព្រោះថា ស្ថិរភាពថ្លៃ គឺជាលក្ខខណ្ឌចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ចល្អ។ ស្ថិរភាពថ្លៃមិនមែនបានន័យថាគ្មានអតិផរណាទាល់តែសោះនោះទេ ពោលគឺអតិផរណាជាមធ្យមប្រចាំថ្ងៃត្រូវបានរក្សាក្នុងរង្វង់ ៥.៥. ភាគរយ។

នៅក្នុងបរិបទនេះស្ថិរភាពថ្លៃត្រូវបានគេយល់ដឹងតាមវិធីពីរយ៉ាង៖

- ស្ថិរភាពថ្លៃតាមន័យចង្អៀតមានន័យថា រក្សាអតិផរណាអោយនៅទាប និង មិនប្រែប្រួល
- ស្ថិរភាពថ្លៃតាមន័យទូលាយមានន័យថា ធ្វើអោយតម្លៃរូបិយវត្ថុមានស្ថិរភាព។

តម្លៃរូបិយវត្ថុជាតិមានស្ថិរភាព គឺជាលក្ខខណ្ឌដំបូងសម្រាប់ស្ថិរភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនិងកំណើនសេដ្ឋកិច្ច។ ប្រសិនបើលក្ខខណ្ឌនេះមិនបានសម្រេចនោះយើងមិនអាចបន្តប្រើរូបិយវត្ថុជារៀងរាល់ថ្ងៃប្រកបដោយទំនុកចិត្តទាំងស្រុងនោះទេ។

### ៣.២.២. ស្ថិរភាពនៃអត្រាការប្រាក់

ស្ថិរភាពនៃអត្រាការប្រាក់ ធ្វើអោយមានភាពមិនប្រាកដប្រជានៅក្នុងសកម្មភាពសេដ្ឋកិច្ចជាបន្ថែមវាមានការលំបាកក្នុងការរៀបចំគម្រោងសម្រាប់អនាគត។ អស្ថិរភាពនៃ អត្រាការប្រាក់មានឥទ្ធិពលដល់ការសម្រេចចិត្តរបស់អ្នកប្រើប្រាស់ នៅពេលដែលគេចង់ទិញផ្ទះ ឬ ចង់យកប្រាក់

19 ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា

ទៅវិនិយោគជាដើម។ ធនាគារកណ្តាលព្យាយាមទប់ស្កាត់អត្រាការប្រាក់អោយនៅចំណុចលំនឹងមួយសមស្រប។

### ៣.២.៣. ស្ថិរភាពនៃអត្រាប្តូរប្រាក់

បម្រែបម្រួលនៃអត្រាប្តូរប្រាក់ធ្វើអោយមានផលប៉ះពាល់ លើថ្លៃនៃផលិតផលដែលយើងនាំចូល ឬ នាំចេញ៖

- ❖ រូបិយវត្ថុថ្លៃខ្លាំងពេកធ្វើអោយទំនិញក្នុងស្រុកចុះថ្លៃធៀបនឹងបរទេស ដែលជាហេតុនាំអោយការនាំចេញកើនឡើង ហើយការនាំចូលមានការថយចុះក្នុងរយៈពេលវែងនឹងនាំអោយមានការឡើងថ្លៃនៃវត្ថុធាតុដើមដែលត្រូវនាំចេញពីបរទេស ដែលអាចធ្វើអោយសហគ្រាសក្នុងស្រុកជួបវិបត្តិក្នុងការផលិតនិងបណ្តាលអោយទំនិញឡើងថ្លៃ។
- ❖ រូបិយវត្ថុឡើងថ្លៃខ្លាំងពេកធ្វើអោយទំនិញក្នុងស្រុកឡើងថ្លៃធៀបនឹងបរទេស ជាហេតុនាំអោយការនាំចេញមានការថយចុះដែលអាចធ្វើអោយសហគ្រាសក្នុងស្រុក ជួបនឹងវិបត្តិក្នុងការផលិតនូវផលិតផលរបស់ខ្លួនដែល ជាហេតុនាំអោយមានការដួលរលំក្នុងរយៈពេលខ្លីនិងបណ្តាលអោយមានវិបត្តិជញ្ជីងទូទាត់។

ទាំងនេះបង្ហាញអោយឃើញថា បម្រែបម្រួលនៃអត្រាប្តូរប្រាក់បានបង្កអោយមានផលប៉ះពាល់លើថ្លៃផលិតផលដែលយើងនាំចូល ឬ នាំចេញ ហើយអាចឈានទៅរកការកើតមានឡើងនូវវិបត្តិសេដ្ឋកិច្ច។ ដូច្នេះ ធានាគារជាតិនៃកម្ពុជាមានបេសកកម្មស្វែងរក ស្ថិរភាពនៃអត្រាប្តូរប្រាក់តាមរយៈការលក់ដេញថ្លៃប្រាក់ដុល្លារ ឬ ការទិញយកប្រាក់ដុល្លារមកវិញ។

### ៣.២.៤. ត្រួតពិនិត្យកំណើនបរិមាណរូបិយវត្ថុ

បទពិសោធន៍បានបង្ហាញថាកំណើនដ៏លើសលុបនៃទ្រព្យធនជារូបិយវត្ថុ ដែលបានកាន់កាប់ដោយភ្នាក់ងារសេដ្ឋកិច្ច គឺជាកត្តានាំអោយមានការកើនឡើងនូវអតិផរណាដោយចៀសមិនផុត។ ដូច្នេះធនាគារជាតិនៃកម្ពុជា ត្រូវតែត្រួតពិនិត្យជាប្រចាំនូវការវិវត្តនៃបរិមាណរូបិយវត្ថុចរាចរដើម្បីធានាស្ថិរភាពថ្លៃដោយធ្វើយ៉ាងណាអោយកំណើនសេដ្ឋកិច្ច និងកំណើន GDP មានសមាមាត្រគ្នា។

### ៣.២.៥. ស្ថិរភាពនៃទីផ្សារហិរញ្ញវត្ថុ

ទីផ្សារហិរញ្ញវត្ថុ មានតួនាទីចម្បងក្នុងការកេណ្ឌប្រមូលមូលនិធិ ឬ ទុនរបស់អ្នកដែលសល់ទុនដោយមិនទាន់បានយកទៅប្រើប្រាស់ ផ្តល់អោយទៅអ្នកដែលកង្វះទុនក្នុងការវិនិយោគ។ វាជាការរួមចំណែកមួយក្នុងការលើកស្ទួយសកម្មភាពសេដ្ឋកិច្ច។ ការជម្រុញអោយមានស្ថិរភាពនៃទីផ្សារហិរញ្ញវត្ថុ គឺជាគោលដៅរបស់ធនាគារកណ្តាលក្នុងកាបញ្ចៀសនូវវិបត្តិហិរញ្ញវត្ថុ។

## ៣.៣. ឧបករណ៍គោលនយោបាយរូបិយវត្ថុ

ការគ្រប់គ្រងរូបិយវត្ថុរបស់ធនាគារជាតិរួមមាន ការដាក់ចេញនូវប្រាក់បម្រុងកាតព្វកិច្ចប្រតិបត្តិការទីផ្សារបើកចំហ និងអត្រាអប្បហារ។ ដូចយើងបានដឹងរួចហើយថាទំហំនៃប្រាក់បញ្ញើប្រតិបត្តិ

ការនៅបណ្តាធនាគារពាណិជ្ជ ឬ ស្ថាប័នទទួលប្រាក់បញ្ញើផ្សេងទៀតផ្អែកលើប្រាក់ដែលមាននៅក្នុងធនាគារពាណិជ្ជ ឬ ទទួលប្រាក់បញ្ញើផ្សេងទៀតនិងប្រាក់បម្រុងកាតព្វកិច្ចដែលកំណត់ដោយធនាគារកណ្តាល។ ដូចនេះធនាគារកណ្តាលអាចគ្រប់គ្រងទំហំប្រាក់បំរុងផ្តល់អោយដោយធនាគារពាណិជ្ជ ឬ ស្ថាប័នទទួលប្រាក់បញ្ញើតាមរយៈប្រតិបត្តិការទីផ្សាចំហ និងអត្រាអប្បហារ។

### ៣.៣.១. ប្រតិបត្តិការទីផ្សារចំហ

ប្រតិបត្តិការទីផ្សារបើកចំហ គឺជាឧបករណ៍មួយដែលធនាគារជាតិនៃកម្ពុជាអនុវត្តដើម្បីគ្រប់គ្រងសាច់ប្រាក់លើទីផ្សារតាមរយៈការទិញ-លក់សញ្ញាប័ណ្ណ ដែលបោះផ្សាយដោយរដ្ឋាភិបាលដែលគេហៅថា ប័ណ្ណរតនាគារ ជាមួយនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានាលើទីផ្សារ។ នៅពេលធនាគារចង់បង្កើនការផ្គត់ផ្គង់រូបិយវត្ថុនៅលើទីផ្សារ គឺធ្វើឡើងតាមរយៈការលក់ប័ណ្ណរតនាគារនិងផ្ទុយមកវិញការទិញប័ណ្ណរតនាគារនេះមកវិញ ដើម្បីកាត់បន្ថយនូវបរិមាណការផ្គត់ផ្គង់រូបិយវត្ថុនៅលើទីផ្សារមានន័យថា ប្រតិបត្តិការទីផ្សាចំហអាចជះឥទ្ធិពលដល់អត្រាការប្រាក់ ដោយធនាគារកណ្តាលអាចទិញ-លក់មូលបត្ររដ្ឋាភិបាលនៅលើទីផ្សារបន្ទាប់ ដើម្បីកែតម្រូវអត្រាប្តូរប្រាក់ទីផ្សារគោលដៅ គឺជាការកាត់បន្ថយឥទ្ធិពលនៃលំហូររូបិយប័ណ្ណ។ ឧទាហរណ៍៖ ធនាគារ ជាតិនៃកម្ពុជាលក់មូលបត្ររដ្ឋាភិបាលចារិកជារៀល ទៅអោយធនាគារពាណិជ្ជអ្នកវិនិយោគបរទេ សបានទិញមូលបត្រនោះពីធនាគារពាណិជ្ជ។ ដូច្នេះអ្នកវិនិយោគបរទេសបានធ្វើការដូរជា ប្រាក់ រៀលក្នុងការទូទាត់ហើយធនាគារពាណិជ្ជលក់ដុល្លារអោយធនាគារកណ្តាល ជាហេតុនាំអោយបរិមាណនៃការផ្គត់ផ្គង់ប្រាក់រៀលមានការកើនឡើង។ ហើយធនាគារជាតិនៃកម្ពុជា អាចជៀសវាង អតិផរណាតាមរយៈការលក់មូលបត្ររដ្ឋាភិបាលចារិកជារៀល ទៅអោយធនាគារពាណិជ្ជដើម្បី ស្រូបយកប្រាក់រៀលចូលមកក្នុងធនាគារជាតិវិញ។

### ៣.៣.២. អត្រាអប្បហារ

ការប្រែប្រួលអត្រាអប្បហារអាចជះឥទ្ធិពលទៅលើការផ្គត់ផ្គង់រូបិយវត្ថុ។ នៅពេលដែលធនាគារពាណិជ្ជជួបប្រទះនូវកង្វះទុនបម្រុង ឬ នៅពេលដែលអតិថិជនមកដកសាច់ប្រាក់ងាយស្រួលរបស់គេផ្ទួនៗខ្លាំងពេក ជាមូលហេតុធ្វើអោយធនាគារពាណិជ្ជចាំបាច់ខ្ចីពីធនាគារកណ្តាលហើយធនាគារពាណិជ្ជនោះត្រូវចំណាយទៅអោយធនាគារកណ្តាលជាការប្រាក់ ដែលអត្រាការប្រាក់នេះហៅថាអត្រាអប្បហារ "Discount Rate"។ ការសុំខ្ចីលុយពីធនាគារកណ្តាលធ្វើអោយធនាគារពាណិជ្ជអាចបង្កើនការវិនិយោគរបស់គេបាន ដែលនាំអោយមានលទ្ធភាពផ្តល់កម្ចីនិងការបង្កើតប្រាក់បញ្ញើ។ ធនាគារកណ្តាលមានសិទ្ធផ្លាស់ប្តូរអត្រាអប្បហារចំណែកឯធនាគារពាណិជ្ជអត្រាអប្បហារគឺជាចំណាយដើម្បីទទួលបាននូវទុនបម្រុងបន្ថែម។ នៅពេលអត្រាអប្បហារឡើងខ្ពស់ធនាគារពាណិជ្ជ អាចតំឡើងអត្រាការប្រាក់ដែលផ្តល់អោយអតិថិជនខ្ចីដើម្បីទទួលបាននូវប្រាក់ចំណេញ។

ដូច្នេះ កម្រិតការប្រាក់ខ្ពស់អាចទប់ស្កាត់ប្រជាជនមិនអោយបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ តាមវិធីខ្ចីពីបណ្តាធនាគារពាណិជ្ជបានទេ។ ផ្ទុយទៅវិញនៅពេលអត្រាអប្បហារទាបធ្វើអោយបណ្តាធនា

គារពាណិជ្ជអាចទទួលទុនបម្រុងលើសពីធនាគារកណ្តាល ដោយចំណាយទាបដែលបណ្តាលឲ្យធនាគារពាណិជ្ជមានលទ្ធភាពផ្តល់កម្ចី ក្នុងកម្រិតអត្រាការប្រាក់ទាបទៅអោយប្រជាជននាំអោយមានការពង្រីក ឬ បន្ថែមការផ្គត់ផ្គង់រូបិយវត្ថុ។

### ៣.៣.៣. ប្រាក់បម្រុងកាតព្វកិច្ច[20]

ប្រាក់បម្រុងកាតព្វកិច្ច( Reserve Requirement ) ជាទឹកប្រាក់ដែលធនាគារពាណិជ្ជយកទៅតម្កល់ទុកនៅក្នុងធនាគារជាតិនៃកម្ពុជា ដែលមានចំណូលសមាមាត្រតាមអត្រាកំណត់មួយនៃប្រាក់បញ្ញើដែលមាននៅក្នុងធនាគារនោះ។ ឧទាហរណ៍៖ ប្រាក់បញ្ញើនៅក្នុងធនាគារ "ក" ត្រូវមានចំនួន ១០០លានដុល្លារហើយអត្រាប្រាក់បម្រុងកាតព្វកិច្ចស្មើនិង១២ ភាគរយ ដែលនាំអោយធនាគារ "ក" នោះត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចចំនួន ១២លានដុល្លាររក្រោមរូបភាពជាប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិ។

ការប្រែប្រួលនូវភាគរយនៃប្រាក់បម្រុងកាតព្វកិច្ចរបស់ធនាគារកណ្តាល ដែលទាមទារទៅធនាគារពាណិជ្ជអាចអោយធ្វើប៉ះពាល់ ដល់ការពង្រីកឥណទានរបស់ធនាគារពាណិជ្ជមានន័យថាបើសិនជាធនាគារកណ្តាលបង្កើនអត្រាប្រាក់កាតព្វកិច្ច ធនាគារពាណិជ្ជត្រូវយកប្រាក់បញ្ញើច្រើនជាងមុនដាក់បញ្ចូលក្នុងប្រាក់បម្រុងកាតព្វកិច្ច ដែលធ្វើអោយធនាគារពាណិជ្ជសល់មូលនិធិតិចជាងមុន សម្រាប់ផ្តល់កម្ចីដែលអាចបណ្តាលអោយអត្រាការប្រាក់កើនឡើង។ ផ្ទុយទៅវិញនៅពេលធនាគារកណ្តាលបញ្ចុះអត្រាការប្រាក់បម្រុងកាតព្វកិច្ចនាំ អោយធនាគារពាណិជ្ជមានឪកាសពង្រីកប្រាក់កម្ចីរបស់ខ្លួនដោយធនាគារពាណិជ្ជ អាចនៅសល់ប្រាក់បញ្ញើច្រើនជាងមុន តែវាប៉ះពាល់ដល់អត្រាការប្រាក់ដែលធ្វើអោយអត្រាការប្រាក់ធ្លាក់ចុះ។

ធនាគារកណ្តាលត្រូវពិនិត្យអោយពេញលេញ នូវប្រាក់បម្រុងកាតព្វកិច្ចរបស់ធនាគារពាណិជ្ជទាំងអស់ដើម្បីធ្វើអោយមានទំនុកចិត្តនូវការរំពឹងទុកអំពីស្ថិរភាពអតិផរណា។ ការត្រួតពិនិត្យនូវប្រាក់បម្រុងរបស់ធនាគារពាណិជ្ជពិតជាសំខាន់ ព្រោះថាធនាគារកណ្តាលត្រូវតែគ្រប់គ្រងនូវតម្រូវការទាំងអស់លើរង្វង់ពាណិជ្ជកម្ម តាមរយៈការរៀបចំការផ្គត់ផ្គង់ប្រាក់បម្រុងរបស់ធនាគារ។ ការផ្គត់ផ្គង់ប្រាក់បម្រុងដែលលើស (Excess Reserve) គឺជាប្រាក់ដែលធនាគារពាណិជ្ជរក្សាទុកក្នុងទូរដែករបស់ខ្លួនដើម្បីបង្ការភាពរខ្វះខាតមូលនិធិសងទៅអោយអតិថិជនវិញ។ ដើម្បីទូទាត់នូវតម្រូវការលើប្រាក់បម្រុងរបស់ធនាគារច្រើនធ្វើអោយកម្ចី និងចំណាយថយចុះតាមរយៈការរិតបណ្តឹងការអោយខ្ចីនិងការបង្កើតអត្រាការប្រាក់។ ធនាគារកណ្តាលត្រួតពិនិត្យប្រាក់បម្រុងរបស់ធនាគារ គឺដើម្បីសម្រុះសម្រួលនៅពេលដែលវាតម្រូវអោយទិញ ឬ លក់ទ្រព្យសកម្មសម្រាប់ការគ្រប់គ្រងប្រាក់បម្រុងរបស់ធនាគារទាំងអស់ ដើម្បីអោយមានស្ថិរភាពអតិផរណា។

ម៉្យាងវិញទៀត នៅពេលដែលអត្រាប្រាក់កាតព្វកិច្ចមានការកើនឡើងធ្វើអោយការផ្គត់ផ្គង់សាច់ប្រាក់ថយចុះ ដោយសារតែធនាគារពាណិជ្ជនៅខ្វះសាច់ប្រាក់សម្រាប់ផ្តល់កម្ចី។ ផ្ទុយទៅវិញ

20 ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា

នៅពេលដែលអត្រាប្រាក់បម្រុងកាតព្វកិច្ចមានការថយចុះ ធ្វើអោយការផ្គត់ផ្គង់សាច់ប្រាក់មានការកើនឡើង ដោយសារតែធនាគារពាណិជ្ជនៅសល់សាច់ប្រាក់សម្រាប់ផ្តល់កម្ចី។ ធនាគារជាតិនៃកម្ពុជាអាចធ្វើអោយបរិមាណរូបិយវត្ថុដែលផ្គត់ផ្គង់ក្នុងខឿនសេដ្ឋកិច្ចមានការកើនឡើង ឬ ថយចុះតាមរយៈការកាត់បន្ថយ ឬ បង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ច។ អត្រាប្រាក់បម្រុងកាតព្វកិច្ចជាឧបករណ៍មួយដែលមានគុណសម្បត្តិសម្រាប់អោយធនាគារជាតិនៃកម្ពុជា ប្រើប្រាស់ជាមធ្យោបាយកែតម្រូវបរិមាណរូបិយវត្ថុ។

## ៣.៤. ស្ថានភាពថ្លៃនិងប្រាក់រៀល

### ៣.៤.១. ការវិវត្តថ្លៃទំនិញនិងអតិផរណា

ថ្លៃទំនិញទូទៅនៅលើទីផ្សារក្នុងស្រុកនៃប្រទេសកម្ពុជា បានរងសម្ពាធខ្ពស់ជាងឆ្នាំកន្លងទៅ។ កត្តាជាច្រើនព្រមទាំងគ្រោះទឹកជំនន់ដែលធ្វើអោយប៉ះពាល់ដល់ការផ្គត់ផ្គង់ក្នុងស្រុកបានរួមចំណែកដល់ការកើនឡើងនៃអតិផរណានាឆ្នាំនេះ។ ចំពោះកត្តាក្រៅប្រទេសកម្រិតអតិផរណាខ្ពស់នៃបណ្តាប្រទេសនានា ក្នុងតំបន់ដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗជាមួយប្រទេសកម្ពុជានិងការឡើងថ្លៃនៃប្រេងឥន្ធនៈ និងស្បៀងអាហារនៅលើទីផ្សារពិភពលោកក៏មានឥទ្ធិពលគួរអោយកត់សម្គាល់ផងដែរមកលើថ្លៃទំនិញនិងសេវាក្នុងស្រុក។

ប្រឈមនិងបញ្ហាខាងលើនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយរូបិយវត្ថុទន់ភ្លន់ ប្រុងប្រយ័ត្ន និងសមស្របដើម្បីសម្អាធអតិផរណា។ ការរក្សាស្ថិរភាពប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិច បានក្លាយជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការសម្រេចគោលដៅរូបិយវត្ថុក្នុងបរិបទនៃដុល្លារូបនីយកម្មខ្ពស់ក្នុងសេដ្ឋកិច្ចកម្ពុជា។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំមានកម្រិត ៥.៥ ភាគរយ នៅឆ្នាំ ២០១៤ ធៀបនិងឆ្នាំ២០១៥។

ធនាគារជាតិនៃកម្ពុជា ទទួលបាននូវលទ្ធផលយ៉ាងគាប់ប្រសើរក្នុងការបំពេញបេសកកម្មរបស់ខ្លួនក្នុងនាមជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា ការរក្សាស្ថេរភាពថ្លៃជាមួយនិងអត្រាអតិផរណាត្រឹម ៤% ក្នុងឆ្នាំ ២០១៣ ដែលជាអត្រាមួយទាបបំផុតនៅក្នុងតំបន់ព្រមទាំងរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់ក្នុងចន្លោះ ៤០៩៧ ទៅ៤១០១ ក្នុងរយៈពេល១០ ឆ្នាំ។ ស្ថិរភាព និង ការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុបានបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុដល់អ្នកដែលមានចំណូលទាប សហគ្រាសធុនតូច និងសាជីវកម្មក្នុងវិស័យផលិតកម្មបានចូលរួមចំណែកក្នុងការជម្រុញអោយមានកំណើនសេដ្ឋកិច្ចក្នុងប្រទេស។

### ៣.៤.២. ស្ថានភាពអត្រាប្តូរប្រាក់

#### ៣.៤.២.១. ស្ថានភាពអត្រាប្រាក់រៀលធៀបនិងដុល្លារអាមេរិច

នៅឆ្នាំ ២០១៥នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិចមានស្ថិរភាពល្អប្រសើរប្រហាក់ប្រហែលនឹងឆ្នាំមុនៗដែរ ដោយមានបម្រែបម្រួលប្រចាំខែជាមធ្យមប្រមាណ -0.១ ដល់ +0.១ ភាគរយ ប៉ុន្មោះ ទៅតាមការវិវត្តនៃរដូវកាល។ បើពិនិត្យលើអត្រាប្រចាំឆ្នាំប្រាក់រៀលមាន

កម្រិត ៤.០៤៨ រៀលក្នុងមួយដុល្លាអាមេរិច បានធ្លាក់ថ្លៃបន្ទិចប្រមាណ០.៧ ភាគរយបើធៀបនិងអត្រាមធម្យម៤០៤០ រៀលក្នុងមួយដុល្លាអាមេរិចនៅឆ្នាំ២០១៤ ដោយសារការបន្តរឡើងថ្លៃនៃប្រាក់ដុល្លាអាមេរិចនៅលើទីផ្សារអន្តរជាតិជាពិសេសធៀបនិងរូបិយប័ណ្ណក្នុងតំបន់ទោះបីជាតម្រូវការប្រាក់រៀលសម្រាប់បង់ពន្ធបានកើនឡើងប្រមាណ២២ ភាគរយក៏ដោយ។ ស្ថិរភាពដ៏ល្អប្រសើរនៃប្រាក់រៀលនេះ គឺដោយសារធនាគារជាតិនៃកម្ពុជាបានផ្គត់ផ្គង់ប្រាក់រៀល ក្នុងបរិមាណសមស្របដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារសម្រាប់ការគាំទ្រការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច។

<u>ក្រាហ្វិក១០ ៖ បង្ហាញពីស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបមិនដុល្លាអាមេរិក</u>




របស់កម្ពុជា។ នៅឆ្នាំនេះ សន្ទស្សន៍ NEER បានធ្លាក់ចុះគួរអោយកត់សម្គាល់ប្រមាណ ៤.៤ ភាគរយ ធៀបនឹងឆ្នាំមុនដែលបង្ហាញថាតម្លៃប្រាក់រៀលបានកើនឡើងគួរអោយគត់សម្គាល់ធៀបនិងរូបិយប័ណ្ណដៃគូពាណិជ្ជកម្មចម្បងៗ។ ការឡើងថ្លៃប្រាក់រៀលនេះដោយសារការធ្លាក់ថ្លៃនៃរូបិយប័ណ្ណប្រទេសទាំងនោះធៀបនឹងប្រាក់ដុល្លារអាមេរិច ជាពិសេសប្រាក់បាតថៃ ដុងវៀតណាម ដុល្លារសិង្ហបុរី និង ដុល្លារតៃវ៉ាន់ ខណៈប្រាក់រៀលមានស្ថិរភាពធៀបនឹងប្រាក់ដុល្លារអាមេរិច។

ទន្ទឹមនិងនេះ សន្ទស្សន៍ REER បានធ្លាក់ចុះប្រមាណ ៦.២ ភាគរយ ធៀបនឹងឆ្នាំ២០១៤ ដោយសារការធ្លាក់ថ្លៃរូបិយប័ណ្ណប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា គួបផ្សំនិងកម្រិតទាបនៃអតិផរណាប្រទេសទាំងនោះ ដែលប្រទេសមួយចំនួនដូចជាប្រទេសថៃ សិង្ហបុរី និងតៃវ៉ាន់ ជួបប្រទះនិងអតិផរណា។ គួរបញ្ជាក់ថាក្នុងបរិការណ៏ជាប្រទេសដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាអនុវត្តរបបអត្រាប្តូរប្រាក់បណ្តែតមានការគ្រប់គ្រង ដោយរក្សាស្ថិរភាពតម្លៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិច។ ដូច្នេះ ការឡើងថ្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណ

21 ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា

ប្រទេសដៃគូពាណិជ្ជកម្ម (REER ថយចុះ) មានន័យថាប្រាក់ដុល្លារអាមេរិចឡើងថ្លៃធៀបនិងរូបិយប័ណ្ណប្រទេសទាំងនោះផងដែរ ហើយជាហេតុដែលធ្វើអោយភាពប្រកួតប្រជែងរបស់កម្ពុជាថយចុះ។

# ជំពូក ៤

# តួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងវិស័យធនាគារ

# ជំពូក ៤
# តួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងវិស័យហិរញ្ញវត្ថុ

## ៤.១. តួនាទីនិងភារៈកិច្ចរបស់ធនាគារជាតិនៃកម្ពុជា

### ៤.១.១. ធនាគារិកសម្រាប់រដ្ឋ

ធនាគារកណ្តាលទទួលខុសត្រូវចំពោះការបោះពុម្ពរូបិយវត្ថុជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋ និងគោលនយោបាយរូបិយវត្ថុរបស់ជាតិ។

### ៤.១.២. ធនាគារិកសម្រាប់ធនាគារពាណិជ្ជ

ធនាគារកណ្តាលទទួលប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនានា និងមានឥទ្ធិពលលើប្រាក់បម្រុងរបស់ធនាគារនានា។ ធនាគារកណ្តាលផ្តល់កម្ចីដល់ធនាគារនានា។

### ៤.១.៣. កំណត់គោលនយោបាយរូបិយវត្ថុ[22]

ធនាគារជាតិ មានកាតព្វកិច្ចនិងការទទួលខុសត្រូវចំពោះការធ្វើយ៉ាងណាអោយមានស្ថិរភាពរូបិយវត្ថុរបស់ប្រទេសកម្ពុជា។ ធនាគារជាតិក៏មានតួនាទីទាមទាកម្រិតនៃប្រាក់បម្រុងធនាគារពាណិជ្ជ និងដាក់អោយប្រើប្រាស់នូវនយោបាយអត្រាការប្រាក់របស់ខ្លួនផងដែរ។

បេសកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់និងដឹងនាំគោលនយោបាយរូបិយវត្ថុសំដៅរក្សាស្ថិរភាពថ្លៃដើម្បីរួមចំណែកជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយប្រុងប្រយ័ត្ន។ អតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាបក្នុងអត្រាមធ្យមប្រចាំឆ្នាំតិចជាង ៥ ភាគរយ ដែលសមស្របសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ទោះបីជាយ៉ាងណាក្តីក្នុងបរិការណ៍សេដ្ឋកិច្ចដែលមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុនៅមានកម្រិតនៅឡើយ ស្របពេលដែលធនាគារជាតិនៃកម្ពុជាពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដើរតួជាអ្នកអោយខ្ចីចុងក្រោយ។ បច្ចុប្បន្ននេះ ឧបករណ៍គោលនយោបាយរូបិយវត្ថុដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាស្ថិរភាពថ្លៃគឺការដាក់អត្រាប្រាក់បម្រុងកាតព្វកិច្ចនិងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាកំពុងតែអភិវឌ្ឍន៍ ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្ថែម ដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ តាមរយៈការចេញផ្សាយមូលបត្រអាចជួយដូរបាន ការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុនិងការពង្រឹងការប្រើប្រាស់ប្រាក់រៀល។

---

22 ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា

### ៤.១.៤. ត្រួតពិនិត្យប្រព័ន្ធហិរញ្ញវត្ថុ

ធនាគារជាតិមានតួនាទីជាអ្នកធានាចំពោះស្ថិរភាពប្រព័ន្ធធនាគារ និងដាក់និយ័តកម្មប្រព័ន្ធហិរញ្ញវត្ថុនិងអភិវឌ្ឍន៍ខ្លួនឯង។ បន្ថែមលើសនេះទៀត ធនាគារជាតិនៃកម្ពុជាក៏ជាអ្នកដែលដើរតួនាទីជាអ្នកអោយកម្ចីដល់ធនាគារពាណិជ្ជដែលទាល់ច្រកចុងក្រោយដែរ នេះមានន័យថា ធនាគារពាណិជ្ជអាចធ្វើការស្នើសុំខ្ចីប្រាក់ពីធនាគារជាតិបាននៅពេលដែលខ្លួនត្រូវការសាច់ប្រាក់ បន្ទាន់។

### ៤.១.៥. ត្រិះរិះរក អនុវ ត្តនិង ត្រួតពិនិត្យនយោបាយរូបិវត្ថុនិងអត្រាប្តូរប្រាក់

គោលនយោបាយអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា គឺជាឧបករណ៍នយោបាយមួយរបស់គោលនយោបាយរូបិយវត្ថុ ដែលមានគោលដៅចម្បងរក្សាស្ថិរភាពថ្លៃ។ ជាមួយនឹងការអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ធនាគារជាតិនឹងធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាព អត្រាប្តូរប្រាក់ ទៅតាមគោលដៅដែលបានកំណត់។ អត្រាប្តូរប្រាក់ផ្លូវការ ជាអត្រាទិញ-លក់រវាងរូបិយវត្ថុជាតិនិងរូបិប័ណ្ណបរទេសផ្សេងទៀត។ អត្រាប្តូរប្រាក់ផ្លូវការនេះត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជានិងដាក់អោយប្រើប្រាស់សម្រាប់រាល់ប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជានិងភាគីពាក់ព័ន្ធ។ លើសនេះ ក្រសួងស្ថាប័នរាជរដ្ឋាភិបាលក៏ដូចជាសារធារណៈជនអាចប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការនេះទៅតាមគោលដៅរៀងខ្លួនហើយអត្រានេះក៏អាចប្រើប្រាស់ប្រើដោយវិស័យឯកជនផងដែរ។

### ធនាគារជាតិនៃកម្ពុជាកំណត់អត្រាប្តូរប្រាក់ផ្លូវការដូចតទៅ៖

១) "គណៈកម្មការកំណត់អត្រាប្តូរប្រាក់ផ្លូវការ" ដែលរួមមានសមាសភាពមកពីនាយកដ្ឋានពាក់ព័ន្ធដូចជា នាយកដ្ឋានគ្រប់គ្រងប្តូរប្រាក់ នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានស្ថិតិ និងនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិគឺជាអ្នកកំណត់អត្រាប្តូរប្រាក់ផ្លូវការ។

២)សមាជិកគណៈកម្មការនេះ ជួបប្រជុំគ្នាជារៀងរាល់ព្រឹក ដើម្បីពិភាក្សានិងវិភាគទៅលើសូចនាករសំខាន់ៗមួយចំនួន ដែលត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ។ បន្ទាប់មក អត្រាប្តូរប្រាក់ផ្លូវការនេះ ដាក់ជូនថ្នាក់អគ្គនាយកបច្ចេកទេសសម្រេចនិងផ្សព្វផ្សាយជាសាធារណៈ។

៣)ករណីដែលទីផ្សារមានការប្រែប្រួលខ្លាំង គណៈកម្មការនឹងមានការប្រជុំជាបន្ទាន់ ដើម្បីរកដំណោះស្រាយ និងកំណត់យុទ្ធសាស្ត្រ ។

### ៤.១.៦. វិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតី

ធនាគារជាតិធ្វើការវិភាគ និង តាមដាននូវស្ថានភាពសេដ្ឋកិច្ច និង រូបិយវត្ថុ ជាប្រក្រតីដើម្បីដឹងថាតើស្ថានភាពសេដ្ឋកិច្ច និង រូបិយវត្ថុមានសភាពបែបណា ហើយប្រែប្រួលយ៉ាងដូចម្តេច ?រួចហើយធនាគារជាតិនៃកម្ពុជានឹងធ្វើការលើកសំណើ និងវិធានការជូនរាជរដ្ឋាភិបាលដើម្បីរៀបចំគោលនយោបាយរបស់ខ្លួន ដើម្បីធ្វើយ៉ាងណាអោយមានស្ថិរភាពសេដ្ឋកិច្ច និងរូបិយវត្ថុ។

### ៤.១.៧.ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ[23]

ធនាគារជាតិនៃកម្ពុជាត្រូវបានអនុញ្ញាត និងទទួលខុសត្រូវក្នុងការដឹកនាំការត្រួតពិនិត្យធនាគារនានានៅព្រះរាជាណាចក្រកម្ពុជា។ ធនាគារនេះធ្វើការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្សេងទៀតអោយធ្វើអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសបានដែរ។ ហើយធនាគារនេះក៏មានសិទ្ធក្នុងការដកហូតអាជ្ញាប័ណ្ណ ចំពោះស្ថាប័នហិរញ្ញវត្ថុណាដែលមិនបានអនុវត្តតាមនូវបទបញ្ជា ឬ លក្ខខណ្ឌតិក របស់ធនាគារជាតិដែលបានកំណត់។

### ៤.១.៨. ត្រួតពិនិត្យប្រព័ន្ធទូទាត់ និងកែលម្អប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ

ធនាគារជាតិនៃកម្ពុជាមានការទទួលខុសត្រូវដែលកំណត់ដោយច្បាប់ ក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់។ ដើម្បីឲ្យប្រព័ន្ធទូទាត់សងប្រាក់ដំណើរការប្រកបដោយប្រសិទ្ធិភាពនិងសុវត្ថិភាព ធនាគារជាតិនៃកម្ពុជាអាចចេញផ្សាយប្រកាស កំណត់ពីលក្ខខណ្ឌសម្រាប់អ្នកផ្តល់សេវាទូទាត់សងប្រាក់ ព្រមទាំងផ្តល់អាជ្ញាប័ណ្ណនិងចុះបញ្ជីសម្រាប់គ្រឹះស្ថានផ្អែកលើលក្ខខ័ណ្ឌដែលបានកំណត់។

ក្នុងកិច្ចការងារអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយដៃគូអភិវឌ្ឍអន្តរជាតិនិងភាគីពាក់ព័ន្ធក្នុងប្រទេស ជាពិសេសវិស័យធនាគារដែលតំណាងដោយសមាគមធនាគារកម្ពុជា។ ហើយក្នុងគោលដៅសម្រួលនូវទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជាសមាគមធនាគារកម្ពុជាក៏បានបង្កើតជាអនុគណៈកម្មការប្រព័ន្ធទូទាត់ ដែលមានតួនាទីអនុវត្តការងារទាក់ទងនឹងគោលនយោបាយ ការគ្រប់គ្រង និងប្រតិបត្តិការទូទាត់ផងដែរ ។

ធនាគារជាតិនៃកម្ពុជា ជាអ្នកដែលត្រួតពិនិត្យនូវប្រព័ន្ធទូទាត់ទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជានឹងកែលម្អរប្រសិទ្ធិភាព ក្នុងការទូទាត់របស់អន្តរធនាគារតាមរយៈការអនុវត្តគោលនយោបាយនិងក្រឹតក្រមច្បាប់ដែលបានកំណត់ដោយរដ្ឋាភិបាលដូចជា៖

- ត្រួតពិនិត្យនិងផ្តល់អាជ្ញាប័ណ្ណដល់ធនាគារ និង ស្ថាប័នឥណទានផ្សេងៗ
- ធ្វើការត្រួតពិនិត្យឥណទានរបស់ធនាគារពាណិជ្ជនឹងស្ថាប័នឥណទាន
- កំណត់ច្បាប់នានាទាក់ទងនឹងប្រតិបត្តិការរបស់បណ្តាធនាគារ និងស្ថាប័នឥណទាន
- ធ្វើការត្រួតពិនិត្យនិងស៊ើបអង្កេតរាល់ប្រតិបត្តិការនានា នៅក្នុងធនាគារទាំងមូលដើម្បីធានានូវសុវត្ថិភាពនិងប្រសិទ្ធភាពប្រព័ន្ធទូទាត់។

[23] ដកស្រង់ចេញពីប្រកាសផ្តល់ ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

### ៤.១.៩.ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិ

ធនាគារជាតិនៃកម្ពុជា គឺជាប្រភេទធនាគារមួយដែលដែលជាកម្មសិទ្ធរបស់រដ្ឋមានតួនាទីឯករាជ្យបោះផ្សាយក្រដាសប្រាក់នឹងគ្រប់គ្រងស្ថិរភាពប្រតិបត្តិការនានា ស្តីពីរូបិយវត្ថុ ឥណទាន និង ធនាគារដោយមានគោលបំណងរក្សាតម្លៃរូបិយវត្ថុជាតិ និង ស្ថិរភាពប្រព័ន្ធធនាគារ។ តាមរយៈលក្ខណៈនេះ ធនាគារជាតិបានអនុវត្តនូវឧបករណ៍សំខាន់បំផុត គឺនយោបាយរូបិយវត្ថុពីព្រោះធនាគារជាតិមានតួនាទីពិសេសក្នុងការគ្រប់គ្រង និងអនុវត្តម៉ាក្រូសេដ្ឋកិច្ចទូទាំងប្រទេសកម្ពុជា។[24]

### ៤.១.១០. ទទួលខុសត្រូវ និងអនុវត្តកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមជាមួយ ស្ថាប័នអន្តរជាតិសាធារណៈក្នុងកិច្ចការធនាគារ ឥណទាន រូបិយវត្ថុ

ធនាគារជាតិនៃកម្ពុជា មានតួនាទីក្នុងការទទួលខុសត្រូវ និង អនុវត្តនូវផែនការសកម្មភាពផ្សេងៗ ក្នុងនាមជាតំណាងអោយព្រះរាជាណាចក្រកម្ពុជានូវកិច្ចការទាំងឡាយដែលប្រទេសនេះសហការជាមួយស្ថាប័នអន្តរជាតិសាធារណៈក្នុងកិច្ចការ ធនាគារ ឥណទាន និងរូបិយវត្ថុ។ ធនាគារជាតិតំណាងអោយរដ្ឋាភិបាលក្នុងការធ្វើទំនាក់ទំនងជាមួយស្ថាប័នអន្តរជាតិ ចំពោះបញ្ហារូបិយវត្ថុ ឥណទាន និង ធនាគារ។ ក្នុងនោះដែរ ធនាគារនេះធ្វើកិច្ចព្រមព្រៀងស្តីពីរូបិយវត្ថុ ឥណទាន ធនាគារជាមួយបរទេស និង ចូលរួមជាសមាជិករបស់បណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដូចជា IMF, World Bank និង ADB ជាដើម។

### ៤.១.១១. តម្លើងតារាងជញ្ជីងទូទាត់

ជញ្ជីងទូទាត់ (BOP) គឺជាវិធីសាស្ត្រដែលបណ្តាប្រទេសទាំងអស់ប្រើដើម្បីតាមដានប្រតិបត្តិការរូបិយវត្ថុអន្តរជាតិនៅក្នុងរយៈពេលមួយជាក់លាក់។ BOPត្រូវបានគណនារាល់ត្រីមាសនិងរាល់ឆ្នាំ។ គ្រប់ពាណិជ្ជកម្មទាំងអស់ដែលធ្វើឡើងដោយវិស័យឯកជននិងសាធារណៈត្រូវបានគេរាប់បញ្ចូលក្នុង BOP ដើម្បីកំណត់ថា តើលុយចំនួនប៉ុន្មាននឹងត្រូវចូលនិងចេញពីប្រទេស? ប្រសិនបើប្រទេសមួយបានទទួលលុយនេះត្រូវបានគេស្គាល់ថាជាឥណទាន ហើយប្រសិនបើប្រទេសមួយបានបោះបង់ប្រតិបត្តិការនេះត្រូវបានគេរាប់បញ្ចូលថាជាឥណពន្ធ។ តាមទ្រឹស្តី BOP វាអាចបង្ហាញអោយឃើញថាតើប្រទេសមួយមានឱនភាពឬលើស? ហើយមានផ្នែកណាមួយក្នុងសេដ្ឋកិច្ចមានភាពខុសគ្នាកំពុងកើតមានឡើង?

### ៤.១.១២. ចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យជាមួយប្រទេសក្រៅ

ធនាគារជាតិនៃកម្ពុជាបានធ្វើការសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការចូលរួមគ្រប់គ្របបំណុល និងឥណទេយ្យជាមួយភាគីបរទេសនិងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀតក្នុងគោលបំណងធ្វើយ៉ាងណាអោយមានតម្លាភាពនិងគណនេយ្យភាព។

---

24 លោក ឃឹម សារិត ២០១៥ *តួនាទីរបស់ធនាគារជាតិ*

### ៤.១.១៣.ចូលរួមបង្កើត និងត្រួតពិនិត្យទីផ្សាររូបិយវត្ថុ និងទីផ្សារហិរញ្ញវត្ថុ

ដើម្បីអោយទីផ្សាររូបិយវត្ថុ និង ទីផ្សាហិរញ្ញវត្ថុមានស្ថិរភាព ធនាគារជាតិនៃកម្ពុជាមានតួនាទីចូលរួមរៀបចំនិងត្រួតពិនិត្យទៅលើស្ថានភាពទីផ្សាររូបិយវត្ថុ និងទីផ្សារហិរញ្ញវត្ថុនិងធ្វើការសម្របសម្រួលភាគីដែលពាក់ព័ន្ធ(stakeholders) ក្នុងទីផ្សារនេះតាមរយៈការចាត់វិធានការផ្លូវច្បាប់ចំពោះភាគីណាមួយ ដែលមិនគោរពនូវលក្ខខណ្ឌដែលបានកំណត់។

### ៤.១.១៤. ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថាន ដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ សន្ធារឹម ត្បូងថ្ម និងលោហធាតុមានតម្លៃ

មុខងារចម្បងរបស់នាយកដ្ឋានអាជ្ញាប័ណ្ណគឺធ្វើការសិក្សា និងវាយតម្លៃពីសមត្ថភាពនិងភាពគ្រប់គ្រាន់របស់គ្រឹះស្ថានថ្មី ដែលមានបំណងចូលមកធ្វើអាជីវកម្មក្នុងទីផ្សារធនាគារនៃកម្ពុជា។ ហើយនាយកដ្ឋាន ក៏ធ្វើការពិនិត្យឡើងវិញនិងបន្តសុពលភាពអាជ្ញាប័ណ្ណ ឬបញ្ចប់សុពលភាពអាជ្ញាប័ណ្ណដែលមានស្រាប់ផងដែរ។ ទន្ទឹមនឹងនេះ នាយកដ្ឋានអាជ្ញាប័ណ្ណធ្វើការពិនិត្យនិងតាមដានការវិវត្តនៃទីផ្សារហិរញ្ញវត្ថុទាំងក្នុងស្រុកនិងអន្តរជាតិ ព្រមទាំងពិនិត្យនិងតាមដានយ៉ាងយកចិត្តទុកដាក់លើបទដ្ឋាននិងឧត្តមានុភាពអន្តរជាតិ ។

### ៤.១.១៥. កំណត់អត្រាការប្រាក់

ផ្អែកលើគោលបំណងរបស់ខ្លួន ធនាគារជាតិនៃកម្ពុជាបានសម្រេចជ្រើសរើសយកកម្រិតអត្រាការប្រាក់ដ៏សមស្របមួយ។ ធនាគារជាតិអាចអនុវត្តការបង្កើន ឬ បន្ថយប្រាក់បម្រុងតាមរយៈប្រតិបត្តិការទីផ្សារ បើកចំហតាមអត្រាដែលនឹងអាចអោយទទួលបានគោលដៅនេះ។ បើអត្រាការប្រាក់ខ្ពស់ជាងអត្រាគោលដៅ នោះការបង្កើនអត្រាកំណើននៃប្រាក់បម្រុងនិងបង្កើនការផ្គត់ផ្គង់រូបិយវត្ថុហើយនាំអោយអត្រាការប្រាក់ចុះទាប។ ប៉ុន្តែបើអត្រាការប្រាក់ទាបជាងអត្រាគោលដៅ នោះការបន្ថយអត្រាកំណើននៃប្រាក់បម្រុងនិងការផ្គត់ផ្គង់រូបិយវត្ថុ ហើយនាំអោយអត្រាការប្រាក់កើនឡើង។ ដើម្បីបន្ធូរនយោបាយរូបិយវត្ថុធនាគារជាតិបន្ទាបកម្រិតអត្រាគោលដៅរបស់ខ្លួន ដើម្បីរឹតបន្តឹងនយោបាយរូបិយវត្ថុធនាគារជាតិបង្កើនកម្រិតការប្រាកក់ដៅរបស់ខ្លួន។

## ៤.២. ប្រតិបត្តិការរបស់ធនាគារកណ្តាល[25]

### ៤.២.១. ប្រតិបត្តិការប្រាក់បញ្ញើ

ធនាគារជាតិគឺ ជាស្ថាប័នហិរញ្ញវត្ថុរបស់រដ្ឋមួយដែលធ្វើប្រតិបត្តិការប្រាក់បញ្ញើដែរពីព្រោះធនាគារកណ្តាលអាចបើកគណនេយ្យអោយស្ថាប័នហិរញ្ញវត្ថុមួយចំនួនដែរ ដូចជា៖

- ❖ ស្ថាប័នរដ្ឋ ឬ អង្គភាពរដ្ឋបាលកណ្តាលដូចជារតនាគារជាតិជាដើម
- ❖ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានការអនុញ្ញាតពីធនាគារជាតិអោយធ្វើអាជីវកម្ម
- ❖ ធនាគារកណ្តាលបរទេស និង ស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ

25 ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា

### ៤.២.២. ផ្នែកឥណទានចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ធនាគារជាតិមានភារកិច្ចរៀបចំឯកសារផ្តល់ឥណទានអោយគ្រឹះស្ថានធនាគារ និងតាមរូបភាពប៉ង់ស្យុង)Repo) និងដកលើសសមតុល្យ (Overdraft) និងគណនាអត្រាការប្រាក់គោលសម្រាប់ហិរញ្ញប្បទាន។

- ឥណទានប៉ង់ស្យុង (Repo) គឺជាប្រភេទឥណទានដែលធនាគារជាតិបានអនុញ្ញាតអោយបណ្តាធនាគារពាណិជ្ជនិងស្ថាប័នហិរញ្ញវត្ថុខ្ចីប្រាក់ដោយដាក់បញ្ចាំ ប័ណ្ណរតនាគារតែអោយខ្ចីប្រាក់បានចំពោះតែអ្នកកាន់កាប់ប័ណ្ណរតនាគារណាដែលជិតដល់កាលកំណត់តែប៉ុណ្ណោះ។
- ឥណទានដកលើសសមតុល្យ (Overdraft Loan) គឺជាប្រភេទឥណទានដែលធនាគារជាតិអនុញ្ញាតិអោយធនាគារពាណិជ្ជ និងស្ថាប័នហិរញ្ញវត្ថុអាចដកប្រាក់លើសសមតុល្យដែលមាននៅក្នុងគណនេយ្យចរន្តរបស់ខ្លួន។

ការផ្តល់ឥណទានដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាប្រភេទឥណទានដែលធនាគារជាតិអនុញ្ញាតអោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខ្ចីប្រាក់ដោយយកប្រាក់បញ្ញើមានកាលកំណត់មកធនាគា។

### ៤.២.៣. ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ធនាគារជាតិផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានចំណុះដូចខាងក្រោម៖

- អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស
- អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- អាជីវកម្មប្តូរប្រាក់
- អាជ្ញាប័ណ្ណចំពោះអាជីវកម្មនាំចូលនាំចេញលោហធាតុនិងត្បូងមានតម្លៃ

#### ៤.២.៣.១. ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ

ចំពោះធនាគារពាណិជ្ជទាំងអស់ដែលចង់ធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ធនាគារទាំងនោះត្រូវបំពេញលក្ខខណ្ឌទៅតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជានឹងធ្វើការសិក្សាពីសមត្ថភាពធ្វើប្រតិបត្តិការរបស់បុគ្គលស្នើសុំ ដើម្បីសម្រេចគោលដៅរបស់ខ្លួន ដោយធ្វើយ៉ាងណាអោយបានស្របតាមការងារដ៏រលូនរបស់ខ្លួននៃប្រព័ន្ធធនាគារ ដើម្បីអោយមានសុវត្ថិភាពគ្រប់គ្រាន់សម្រាប់សាធារណៈជន។ ពាក្យស្នើរសុំប្រតិបត្តិការធនាគារដែលមិនត្រឹមត្រូវនឹងត្រូវបានបដិសេធមិនផ្តល់អាជ្ញាប័ណ្ណទេ។ ខាងក្រោមនេះជាចំនុចខ្លះដែលជាលក្ខខណ្ឌនៃការអាចក្លាយជាធនាគារពាណិជ្ជបាន៖

- ដើមទុនអប្បបរមា ចំនួន ១៥០,០០០,០០០,០០០ រៀល
- គ្រឹះស្ថាននិងធនាគារត្រូវមានបុគ្គលិកគ្រប់គ្រាន់ និងមានជំនាញសមស្រប ធនធានបច្ចេកទេសរួមទាំងប្រព័ន្ធពត៌មានវិទ្យាត្រូវមានប្រសិទ្ធិភាព និង ជឿជាក់បានជាពិសេសប្រព័ន្ធសុវត្ថិភាពប្រតិបត្តិការជាមួយសាធារណៈជន។

- ត្រូវធានាថា ប្រតិបត្តិការ រចនាសម្ព័ន្ធចាត់តាំង និតិវិធី ប្រតិបត្តិតាមច្បាប់ និងបទបញ្ញត្តិជាធរមាន និងអនុវត្តធុរកិច្ចនិងស្តង់ដាទូទៅ។
- ធានាគាគុណភាពរបាយការណ៍ហិរញ្ញវត្ថុនិងគណនេយ្យ
- ធានាប្រតិបត្តិការទៅតាមកម្រិតដែលបានកំណត់ចំពោះហានិភ័យ ជាពិសេសហានិភ័យសមភាគី ហានិភ័យអត្រាប្តូរប្រាក់និងហានិភ័យអត្រាការប្រាក់។

### ៤.២.៣.២. ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស

លក្ខខណ្ឌមួយចំនួន ដែលអាចក្លាយជាធនាគារឯកទេសដើម្បីធ្វើប្រតិបត្តិការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាមាន៖

- ដើមទុនអប្បបរមា ចំនួន ៣០០,០០០,០០០,០០០ រៀល
- នាម ឬ នាមការណ៍អាជីវកម្មរបស់គ្រឹះស្ថាន
- អាស័យដ្ឋានទីស្នាក់ការកណ្តាលដែលបានចុះបញ្ជី
- រូបភាពគតិយុត្តិនិងលក្ខន្តិកៈ ឬ ឯកសារបង្កើតផ្សេងៗ
- ប្រភេទមូលបត្រតំណាងអោយដើមទុន
- ចំនួនដើមទុនផ្ទាល់ដែលបានអនុញ្ញាត្តនិងដែលបានបង់
- ការបែងចែកភាគហ៊ុននិងសិទ្ធបោះឆ្នោត និងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកដែលដើរតួក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ
- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិច២ រូប ដែលទទួលខុសត្រូវក្នុងការដឹកនាំអោយមានប្រសិទ្ធិភាពនូវសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថាន
- អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមពីលើព័ត៌មានខាងលើត្រូវមានជីវប្រវត្តិ និង របាយការណ៍បញ្ជាក់ថាគ្មានការពាក់ព័ន្ធនិងការហាមឃាត់ដូចបានចែងក្នុងច្បាប់ស្តីពីគ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ។
- ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជាអង្គភាពដែលបានបង្កើតរួចហើយត្រូវផ្តល់មកនូវការអធិប្បាយអំពីមុខរបររបស់ខ្លួន ព្រមទាំងតារាងតុល្យការដែលបញ្ជាក់ពីស្នងការគណនេយ្យសម្រាប់ប្រតិបត្តិការ ក្នុងរយៈពេលបីឆ្នាំចុងក្រោយ។

### ៤.២.៣.៣. ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ដើម្បីធ្វើប្រតិបត្តិការណ៍អាជីវកម្មបាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវធ្វើការស្នើសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា។ ខាងក្រោមនេះជាលក្ខខណ្ឌដើម្បីក្លាយខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖

- គ្រឹះស្ថានដែលទទួលអាជ្ញាប័ណ្ណត្រូវមានដើមទុនអប្បបរមាចុះក្នុងលក្ខន្តិកៈចំនួន ពីររយហាសិបលានរៀល ២៥០,០០០,០០០ រៀល
- ឈ្មោះអាជីវកម្មរបស់គ្រឹះស្ថាន
- អាស័យដ្ឋាននៃទីស្នាក់ការកណ្តាលដែលបានចុះបញ្ជី

❖ រូបភាពគតិយុត្តិនិងលក្ខន្តិកៈ ឬ ឯកសារបង្កើតផ្សេងៗ
❖ ប្រភេទមូលបត្រតំណាងអោយដើមទុន និងចំណាងនៃការទាក់ទងកាន់កាប់មូលបត្រទាំងនោះនិងការអនុវត្តសិទ្ធក្នុងការបោះឆ្នោត
❖ ចំនួនដើមទុនដែលបានអនុញ្ញាត ឬ ដែលត្រូវបានបង់
❖ ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកដែលមានតួនាទីក្នុងការដឹកនាំនយោបាយរបស់គ្រឹះស្ថាន
❖ អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិច ២ រូប ដែលទទួលខុសត្រូវក្នុងការដឹកនាំអោយមានប្រសិទ្ធិភាពនូវសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថាន
❖ អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមពីលើព័ត៌មានខាងលើត្រូវមានជីវប្រវត្តិនិង របាយការណ៍បញ្ជាក់ថាគ្មានការពាក់ព័ន្ធនិងការហាមឃាត់ដូចបានចែងក្នុងច្បាប់ស្ដីពីគ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ។
❖ ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជាអង្គភាពដែលបានបង្កើតរួចហើយត្រូវផ្ដល់មកនូវការអធិប្បាយអំពី មុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការដែលបញ្ជាក់ពីស្នងការគណនេយ្យសម្រាប់ប្រតិបត្តិការក្នុងរយៈបីឆ្នាំចុងក្រោយ។
❖ ពិពណ៌នាផែនការសកម្មភាពអាជីវកម្មរយៈពេល ៣ ឆ្នាំខាងមុខ៖
   ✓ ទំហំនៃកម្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុង ឬ ក្រៅតារាងតុល្យការ
   ✓ ប្រភេទអតិថិជនដែលគ្រឹះស្ថានចង់ប្រាស្រ័យទាក់ទង
   ✓ ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក(មូលនិធិផ្ទាល់ ប្រាក់ឧបត្ថម្ភបំណុលបន្ទាប់បន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចីជាដើម ហើយបើចាំបាច់បញ្ជាក់ច្បាស់ពីដើមកំណើតនិងកម្មសិទ្ធធនធានទាំងនេះក្នុងករណីមិនប្រាកដ)
   ✓ ទីតាំងឬសាខាដែលបានបង្កើតមានហើយនឹងបម្រុងនឹងបង្កើត

### ៤.២.៣.៤. ការផ្ដល់អាជ្ញាប័ណ្ណអាជីវករប្ដូរប្រាក់[26]

បុគ្គលដែលមានបំណងធ្វើអាជីវកម្មប្ដូរប្រាក់ត្រូវតែសុំអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។ បុគ្គលដែលដាក់ពាក្យសុំធ្វើអាជីវកម្មប្ដូរប្រាក់ត្រូវមានកាតព្វកិច្ចនិងសិទ្ធិដូចតទៅ៖

❖ ត្រូវមានដើមទុនអប្បបរមាចំនួន ៨០,០០០,០០០ រៀល តម្កល់នៅធនាគារជាតិនៃកម្ពុជាជាអចិន្ត្រៃយ៍ដោយទទួលបានកម្រៃការប្រាក់ដែលបានកំណត់ដោយធនាគាជាតិនៃកម្ពុជា
❖ មានសិទ្ធិចូលរួមក្នុងការដេញថ្លៃទិញ-លក់ប្រាក់រៀលនៅធនាគារជាតិនៃកម្ពុជា
❖ មានសិទ្ធិចូលរួមក្នុងកម្មវិធីបណ្ដុះបណ្ដាលរបស់ធនាគារជាតិនៃកម្ពុជា លើការសម្គាល់រូបិយវត្ថុក្លែងក្លាយ។

26 ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា

#### ៤.២.៣.៥. ការផ្តល់អាជ្ញាប័ណ្ណដល់អាជីវកម្មនាំចូលនិងនាំចេញលោហធាតុ

- ❖ ចំពោះដើមទុនអប្បបរមា សម្រាប់អាជីវកម្មនាំចេញនាំចូលលោហធាតុនិងត្បូងមានតម្លៃ មិនទាន់មានការកំណត់ទេ (ពុំទាន់មានប្រកាសណាមួយបានចែង)
- ❖ ចំពោះនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណ
  - ដាក់ពាក្យសុំអាជ្ញាប័ណ្ណដើម្បីប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងមានតម្លៃត្រូវតែចុះបញ្ជីជាក្រុមហ៊ុនពាណិជ្ជកម្ម។
  - ឯកសារដែលត្រូវភ្ជាប់មកជាមួយរបស់ក្រុមហ៊ុនមាន៖
    - លិខិតចុះបញ្ជីពាណិជ្ជកម្ម
    - ឈ្មោះជាផ្លូវការរបស់តំណាងក្រុមហ៊ុន
    - អាស័យដ្ឋានរស់នៅ និង អាស័យដ្ឋានប្រកបអាជីវកម្ម
    - សម្មតិនាម ឬ ឈ្មោះអាជីវកម្ម
    - លិខិតបញ្ជាក់ពីសមត្ថកិច្ចស្តីពីការអនុញ្ញាតទីតាំងប្រកបអាជីវកម្ម
    - ឯកសារផ្សេងៗទៀតតាមតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា
- ❖ សិទ្ធិក្នុងការប្រើប្រាស់អាជ្ញាប័ណ្ណរាល់ការនាំចេញ ឬ នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃត្រូវស្នើសុំការអនុញ្ញាត ពីធនាគារជាតិនៃកម្ពុជានឹងត្រូវបង់សោហ៊ុយលិខិតអនុញ្ញាតចំនួន ២០០០០០០រៀល ក្នុងមួយប្រតិបត្តិការ។
- ❖ ក្រុមហ៊ុនទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាមានសិទ្ធិធ្វើអាជីវកម្ម ទិញ-លក់ និងនាំចេញ ឬ នាំចូលលោហធាតុ និង ត្បូងមានតម្លៃតែប៉ុណ្ណោះ។

## ៤.៣. អគ្គនាយកដ្ឋានត្រួតពិនិត្យ

### ៤.៣.១. ការគ្រប់គ្រង

អគ្គនាយកដ្ឋានត្រួតពិនិត្យបានបែងចែកនាយកដ្ឋានក្រោមឱវាទជាបួន។ នាយកដ្ឋាននីមួយៗតែងមានការិយាល័យបួនទៀត ដែលដឹកនាំដោយប្រធានមួយរូប អមដោយ អនុប្រធានមួយរូប ឬ ច្រើនរូបជួយធ្វើការតាមការចាំបាច់។

### ៤.៣.២. មុខងារនិងភារកិច្ច

អគ្គនាយកដ្ឋានត្រួតពិនិត្យទើបតែត្រូវបានផ្លាស់ប្តូររចនាសម្ព័ន្ធនាពេលថ្មីៗនេះ ហើយមានមុខងារ និង ភារកិច្ចចម្បងៗគឺ៖

- ❖ ចូលរួមតាក់តែងច្បាប់ បទបញ្ជា សារាចរ និងចេញគំរូរបាយការណ៍ស្តង់ដានានា ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្រុមហ៊ុនស្នងការគណនេយ្យ ឯករាជ្យគ្រឹះស្ថានជម្រៈបញ្ជីជាដើម
- ❖ ត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ ដោយប្រយោលទៅលើរបាយការណ៍ដែលបានទទួលប្រចាំគ្រានិងធ្វើអធិការកិច្ចដល់ទីកន្លែង

- ❖ ត្រួតពិនិត្យជាអចិន្ត្រៃយ៍នូវស្ថានភាពហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានចំណុះច្បាប់បន្ទាប់ពីបានរកឃើញការពិតជាក់ស្តែងតាមរយៈការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែង
- ❖ ដាក់ទណ្ឌកម្មខាងវិន័យចំពោះគ្រឹះស្ថានចំណុះច្បាប់ ដែលមិនបានអនុវត្តតាមច្បាប់ និងបទបញ្ជា
- ❖ ប្តឹងទៅតុលាការប្រសិនបើមានការរំលោភច្បាប់ និង បទបញ្ជាមានការប៉ះពាល់ដល់ផលប្រយោជន៍សារធារណៈ។

ចំពោះរាល់ការចេញសេចក្តីសម្រេចត្រូវអនុវត្តអោយបានជាក់លាក់។ រាល់សេចក្តីសម្រេចត្រូវមានការចុះហត្ថលេខាដោយប្រធាន និង អនុប្រធាននាយកដ្ឋាន ឬ ដោយអគ្គនាយកដ្ឋាន ឬ ទេសាភិបាលយោងទៅតាមសារៈសំខាន់នៃសេចក្តីសម្រេចនោះ។ ក្នុងករណីណាក៏ដោយ គ្រប់លិខិតស្នាមក្នុងការចេញអាជ្ញាប័ណ្ណ ឬ ដកហូតអាជ្ញាប័ណ្ណគ្រប់បទបញ្ជាត្រួតពិនិត្យថ្មីៗ ឬ កែសម្រួលគ្រប់លិខិតជូនដំណឹងពីការដាក់ទណ្ឌកម្មខាងពិន័យ គ្រប់លិខិតតែងតាំងអភិបាលបណ្តោះអាសន្ន ឬ អ្នកជម្រះបញ្ជីត្រូវមានហត្ថលេខាដោយទេសាភិបាល ឬ ដោយមន្ត្រីជាន់ខ្ពស់ដែលទេសាភិបាលបានចាត់តាំងជាពិសេសសម្រាប់គោលបំណងនេះ។

### ៤.៣.៣. នាយកដ្ឋានក្រោមឱវាទ

អគ្គនាយកដ្ឋានត្រួតពិនិត្យត្រូវបានរៀបចំអោយមាននាយកដ្ឋាន ៤៖

#### ៤.៣.៣.១. នាយកដ្ឋានត្រួតពិនិត្យឯកសារ

- ការិយាល័យត្រួតពិនិត្យឯកសារទី ១
- ការិយាល័យត្រួតពិនិត្យឯកសារទី ២
- ការិយាល័យត្រួតពិនិត្យឯកសារទី ៣
- ការិយាល័យត្រួតពិនិត្យឯកសារទី ៤

#### ៤.៣.៣.២. នាយកដ្ឋានត្រួតពិនិត្យដល់ទីកន្លែង

- ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង ១
- ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង ២
- ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង ៣
- ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង ៤

#### ៤.៣.៣.៣. នាយកដ្ឋានផ្តល់អាជ្ញាប័ណ្ណ

- ការិយាល័យអាជ្ញាប័ណ្ណ និង ជម្រះបញ្ជី
- ការិយាល័យវិភាគ និង តាមដានម៉ាក្រូ
- ការិយាល័យត្រួតពិនិត្យការិយាល័យឥណទាន
- ការិយាល័យគ្រប់គ្រងទិន្នន

**៤.៣.៣.៤. នាយកដ្ឋាននីតិកម្ម**

- ការិយាល័យគតិយុត្តិ និង វិវាទ
- ការិយាល័យបញ្ញត្តិកម្ម និង ស្រាវជ្រាវ
- ការិយាល័យបណ្តុះណ្តាល
- ការិយាល័យរដ្ឋបាល

# សេចក្ដីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក យោងតាមលទ្ធផលនៃការធ្វើសារណា និង ការសិក្សាស្រាវជ្រាវដែលមានសេចក្តីដូចខាងដើមខ្ញុំបាទអាចសន្និដ្ឋានបានថា ការខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា បានធ្វើអោយសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការរីកចម្រើនគួរអោយកត់សម្គាល់នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលអត្រានៃកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជាប្រមាណមាន៧%។ កំណើនដ៏រឹងមាំនេះសម្រេចបាននៅក្នុងបរិការណ៍ដែលសេដ្ឋកិច្ចពិភពលោក បានបន្តរងើបឡើងទោះជាមានល្បឿនយឺតក៏ដោយ តែអាចរក្សាស្ថិរភាពមាក្រូសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ហាហិរញ្ញវត្ថុប្រកបដោយចីរភាព។

ស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់បានចូលរួមចំណែកជាចម្បង ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋ-កិច្ច។ អត្រាអតិផរណាបានបន្តស្ថិតនៅក្នុងកម្រិតទាប ហើយអត្រាប្តូរប្រាក់រៀលមានស្ថិរភាពល្អប្រសើរ។ ទន្ទឹមនឹងនេះ ស្ថានភាពសន្ទនីយភាពក៏ត្រូវបានរក្សាអោយនៅក្នុងកម្រិតមួយខ្ពស់ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ភ្នាក់ងារសេដ្ឋកិច្ច ហើយទុនបម្រុងអន្តរជាតិត្រូវបានគរពូនជាលំដាប់ អោយស្ថិតនៅក្នុងកម្រិតមួយខ្ពស់សមស្របទៅនឹងស្ថានភាពសេដ្ឋកិច្ចជាតិ។

ស្របពេលដែលប្រព័ន្ធធនាគារបានបន្តរីកចម្រើនយ៉ាងរឹងមាំ ទាំងវិសាលភាពនិងទំហំប្រតិ-បត្តិការក្របខ័ណ្ឌបទប្បញ្ញត្តិ ការត្រួតពិនិត្យធនាគារ ការតាមដានហានិភ័យមកលើវិស័យធនាគារ និងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានពង្រឹងជាប្រចាំដើម្បីធានានូវការអភិវឌ្ឍន៍និងស្ថិរភាពហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធិភាព។

ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍន៍ទីផ្សារធនាគារនិងរូបិយវត្ថុនិងទីផ្សារប្តូរប្រាក់ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុដូចជា ប្រព័ន្ធទូទាត់ ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងបំពាក់នូវបច្ចេកវិទ្យាទំនើបនានា សំដៅសម្រួលនិងអភិវឌ្ឍន៍ក្នុងប្រព័ន្ធធនាគារអោយបាន់តែរីកចម្រើន។ ក្នុងនាមជាស្ថាប័នផ្តល់សេវាដល់រាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ស្ថាប័នអន្តរជាតិនានា ធនាគារជាតិនៃកម្ពុជាក៏សម្រេចបាននូវការលើកកម្ពស់គុណភាពសេវា ហើយសម្រួលប្រតិបត្តិការនានាក្នុងប្រព័ន្ធធនាគារ អោយប្រព្រឹត្តិទៅដោយរលូនឆាប់រហ័ស សុវត្ថិភាព និងប្រសិទ្ធិភាព។ សរុបរួមមក អ្វីដែលសម្រេចបាននេះ គឺដោយសារតែមានការខិតខំប្រឹងប្រែងអនុវត្តតួនាទីរបស់ខ្លួន យ៉ាងខ្លាំងដើម្បីអោយសម្រេចបាននូវលទ្ធផលដូចឆ្នាំនេះ ហើយនឹងបន្តភាពជោគជ័យនៅឆ្នាំបន្តទៀត។

## ២. ការផ្តល់អនុសាសន៍

ដោយផ្អែកទៅតាមការចុះស្រាវជ្រាវ និងការធ្វើសេចក្តីសន្និដ្ឋានខាងលើធ្វើអោយការស្រាវជ្រាវនេះអាចរកឃើញនូវចំណុចអវិជ្ជមានមួយចំនួន ដែលជាចំណុចបន្ថែមក្នុងការបំពេញភាពខ្វះចន្លោះរបស់ធនាគារជាតិដែលមានស្រាប់ និង ជាជំនួយដល់ប្រជាពលរដ្ឋកម្ពុជា ឬ ដៃគូរដែលពាក់

ព័ន្ធដើម្បីអោយមានភាពងាយស្រួលក្នុងស្វែងរកព័ត៌មានរបស់ធនាគារជាតិនៃកម្ពុជា។ ហើយចំណុចខ្លះក៏អាចជាគំនិតមួយចំនួនសម្រាប់ពិចារណាដើម្បីអោយធនាគារជាតិ អាចបំពេញតួនាទីរបស់ខ្លួនយ៉ាងពេញលេញសម្រាប់ប្រជាជាតិកម្ពុជាទាំងមូល។ យោបល់ទាំងអស់នោះដូចមានរៀបរាប់នៅខាងក្រោម៖

- ❖ បំពេញតួនាទីរបស់ខ្លួនអោយកាន់តែមានប្រសិទ្ធិភាព និង ជួយសម្រួលអោយមានលក្ខណៈងាយស្រួលទៅដល់ធនាគារពាណិជ្ជ
- ❖ ពង្រីកទំនាក់ទំនងជាមួយធនាគារពាណិជ្ជ ដើម្បីអោយមានដំណើរការផ្ទេរប្រាក់មានភាពងាយស្រួល
- ❖ ពង្រឹងប្រតិបត្តិការគណនេយ្យនឹងធ្វើអោយធនាគារពាណិជ្ជ ឬ គ្រឹះស្ថានហិរញ្ញវត្ថុទទួលបានទំនុកចិត្តពីអតិថិជន
- ❖ គួរផ្សព្វផ្សាយឯកសារដែលទាក់ទងនិងធនាគារជាតិនៃកម្ពុជា អោយបានច្រើនដើម្បីជួយសម្រួលដល់អ្នកដែលពាក់ព័ន្ធក្នុងការស្វែងរកឯកសារ
- ❖ ត្រូវពង្រឹងហេដ្ឋារចនាសម្ព័ន្ធរួមទាំងប្រព័ន្ធទូទាត់បន្ថែមទៀត
- ❖ ធនាគារពាណិជ្ជមួយចំនួនមានបញ្ហាប្រឈមទៅនិង ផែនការយុទ្ធសាស្ត្រ ការត្រួតពិនិត្យផ្ទៃក្នុង ការជ្រើសរើសក្រុមប្រឹក្សាភិបាលឯករាជ្យ ការបង្កើតគណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអសកម្ម និងគណៈកម្មាការសវនកម្ម និងការប្រកាន់ខ្ជាប់នូវការអនុវត្តតាមគោលនយោបាយនិងនិតិវិធីជាលាយលក្ខណ៍អក្សរ។

# ឯកសារយោង

# ឯកសារយោង


- ធនាគារជាតិនៃកម្ពុជា របាយការប្រចាំឆ្នាំរបស់នាយកដ្ឋានត្រួតពិនិត្យ ឆ្នាំ (២០១៥) ២០១៥ ភ្នំពេញ
- ធនាគារជាតិនៃកម្ពុជា (២០១៤)របាយការប្រចាំឆ្នាំរបស់នាយកដ្ឋានត្រួតពិនិត្យ ឆ្នាំ ២០១៥ ភ្នំពេញ
- ព្រះរាជក្រមលេខ នស/រកម ០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រិត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- ព្រះរាជក្រមលេខ នស/រកម ១០០៥/៣០ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រិះស្ថានមីក្រូ ហិរញ្ញវត្ថុ
- ព្រះរាជក្រមលេខ ធ ៨៩៨៨០ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៨ ដែលស្តីពីរចនាសម្ព័ន្ធ/ធនាគារជាតិនៃ កម្ពុជានិងតួនាទីក្រោមឪវាទនាយកដ្ឋានប្រតិបត្តិការ
- របាយការណ៏ប្រចាំឆ្នាំ ២០១៥ របស់ធនាគារជាតិនៃកម្ពុជា
- គេហទំព័ររបស់ធនាគារជាតិនៃ កម្ពុជា : www.nbc.org.kh
- ប្រកាសលេខ៧០០-០៦ប្រក ចុះថ្ងៃទី១១ ខែ មករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណ. ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់
- សុក ច័ន្ទរិទ្ធី .*ធនាគារកណ្តាល.* ភ្នំពេញគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ :, ២០១២.

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១



អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
(ស.ហ.ក)
ទេសាភិបាល
ទេសាភិបាលរង
សមាជិកក្រុមប្រឹក្សាភិបាល១.ទេសាភិបាល
២.ទេសាភិបាលរង
៣.តំណាងប្រមុខរាជរដ្ឋាភិបាល
៤.តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
៥.តំណាងមជ្ឈដ្ឋានឧត្តមសិក្សា
៦.តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច
៧.តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា
ទីប្រឹក្សា
អគ្គលេខាធិការដ្ឋាន
ខុទ្ទកាល័យ
នាយកដ្ឋានគណនេយ្យ
នាយកដ្ឋានគ្រប់គ្រង
មណ្ឌលសិក្សាបច្ចេកទេស
នាយកដ្ឋានព័ត៌វិទ្យា
នាយកដ្ឋានគតិយុត្ត
សាខារាជធនាគារជាតិ
អគ្គលេខាធិការដ្ឋានបច្ចេកទេស
នាយកដ្ឋានប្រតិបត្តិ
នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានស្ថិតិ
នាយកដ្ឋានប្រព័ន្ធទូទាត់សង
អគ្គនាយកដ្ឋានត្រួតពិនិត្យ
នាយកដ្ឋាននីតិកម្ម
នាយកដ្ឋានអាជ្ញាប័ណ្ណ
នាយកដ្ឋានត្រួតពិនិត្យដល់ទីកន្លែង
នាយកដ្ឋានត្រួតពិនិត្យលើឯកសារ
អគ្គាធិការដ្ឋាន
នាយកដ្ឋានអធិការកិច្ច
នាយកដ្ឋានសវនកម្មផ្ទៃក្នុង
អគ្គបេឡា
នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា
នាយកដ្ឋានជាងពុម្ព

ឧបសម្ព័ន្ធ ២

**ឧបសម្ព័ន្ធ៣**



ប្រធាន

**ឯកឧត្តម ជា ចាន់តូ**

អគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា



**លោកជំទាវ នាវ ច័ន្ទថាណា**

ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា



**ឯកឧត្តម ជូ គឹមឡេង**

តំណាងប្រមុខរាជរដ្ឋាភិបាល



**ឯកឧត្តម រស់ សីលវ៉ា**

តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម អ៊ីវ ថុង**

តំណាងមជ្ឈដ្ឋានឧត្តមសិក្សា



**លោក ឡាយ ម៉េងស៊ុន**

តំណាងមជ្ឈដ្ឋានធ្វើ សកម្មភាពសេដ្ឋកិច្ច



**អ្នកស្រី មៅ សុន**

តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា

**ឧបសម្ព័ន្ធ៤**

ធ៩-០៩-២៣០ ប្រ.ក

# ប្រកាស
## ស្តីពី
## ការផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងគ្រប់គ្រងរាល់អាជីវកម្មប្តូរប្រាក់ ដែលកំពុងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

និយមន័យ៖

១- **រូបិយវត្ថុ** សំដៅដល់ប្រាក់រៀលដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ។

២- **រូបិយប័ណ្ណ** សំដៅដល់រូបិយវត្ថុបរទេសឬមធ្យោបាយទូទាត់ជារូបិយវត្ថុបរទេស ។

៣-**អាជីវកម្មប្តូរប្រាក់** សំដៅដល់ការ ទិញ-លក់ ប្រាក់រៀលជាមួយនឹងរូបិយប័ណ្ណនានា ឬការទិញ-លក់រូបិយប័ណ្ណមួយជាមួយនឹងរូបិយប័ណ្ណផ្សេងៗទៀត។

**ប្រការ ៣.-**

ប្រតិបត្តិការដែលជាសកម្មភាពប្តូរប្រាក់ រួមមាន៖

- ទិញ និងលក់ក្រដាសប្រាក់ជារូបិយប័ណ្ណ
- ទិញមូលប្បទានប័ត្រទេសចរណ៍ ។

**ប្រការ ៤.-**

១- បុគ្គលដែលមានបំណងធ្វើអាជីវកម្មប្តូរប្រាក់ត្រូវតែសុំអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ។

២- បុគ្គលដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្មប្តូរប្រាក់ត្រូវមានកាតព្វកិច្ច និងសិទ្ធិ ដូចតទៅ៖

ក- ត្រូវមានដើមទុនអប្បបរមាចំនួន ៨០.០០០.០០០រៀល (ប៉ែតសិបលានរៀល) តម្កល់នៅធនាគារជាតិនៃកម្ពុជាជាអចិន្ត្រៃយ៍ដោយទទួលកម្រៃការប្រាក់ ដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា

ខ- មានសិទ្ធិចូលរួមក្នុងការដេញថ្លៃទិញ-លក់ប្រាក់រៀលនៅធនាគារជាតិនៃកម្ពុជា

គ-មានសិទ្ធិចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ធនាគារជាតិនៃកម្ពុជា លើការសម្គាល់រូបិយប័ណ្ណក្លែងក្លាយ។

**ប្រការ ៥.-**

១- ពាក្យសុំអាជ្ញាប័ណ្ណត្រូវមានបញ្ជាក់ឬមានភ្ជាប់ជាមួយនូវ៖

ក- នាមករណ៍យីហោ និងអាសយដ្ឋានធ្វើអាជីវកម្ម

ខ- លិខិតបង់ប្រាក់តម្កល់ដើមទុន

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

២- ពាក្យសុំលិខិតអនុញ្ញាតត្រូវមានបញ្ជាក់ឬមានភ្ជាប់ជាមួយនូវ៖

ក- ឈ្មោះ និងទីលំនៅអចិន្ត្រៃយ៍របស់អ្នកដាក់ពាក្យសុំ

ខ- ទីតាំងធ្វើអាជីវកម្មដោយមានបញ្ជាក់ពីអាជ្ញាធរខណ្ឌ ឬស្រុក និង

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦**.-

១-ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យលើពាក្យស្នើសុំក្នុងរយៈពេល៤៥ថ្ងៃគិតពីថ្ងៃបានទទួលពាក្យស្នើសុំពេញលេញហើយអាចចេញអាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតឬបដិសេធពាក្យស្នើសុំនោះ។

២- អាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតមិនអាចផ្ទេរឬប្តូរឈ្មោះបានឡើយ។

៣- អាជ្ញាប័ណ្ណមានសុពលភាពរយៈពេល៣ឆ្នាំគិតចាប់ពីថ្ងៃចេញអាជ្ញាប័ណ្ណ។

៤- លិខិតអនុញ្ញាតមានសុពលភាពរយៈពេល១ឆ្នាំគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត។

**ប្រការ ៧**.-

១- អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោម៖

ក- សោហ៊ុយដាក់ពាក្យសុំអាជ្ញាប័ណ្ណចំនួន ១០០.០០០(មួយរយពាន់រៀល)។

ខ- សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួន ១.២០០.០០០រៀល (មួយលានពីររយពាន់រៀល) ដែលត្រូវបង់នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។

គ- ក្នុងរយៈពេល៣០ថ្ងៃមុនអាជ្ញាប័ណ្ណអស់សុពលភាពអ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណជាថ្មី។

ឃ-ក្នុងករណីមិនបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណទាន់ពេលវេលាអ្នកកាន់អាជ្ញាប័ណ្ណនឹងត្រូវរងការផាកពិន័យជាប្រាក់ចំនួន២០.០០០រៀល (ម្ភៃពាន់រៀល)ក្នុងមួយថ្ងៃ។ ប្រសិនបើអាជ្ញាប័ណ្ណអស់សុពលភាពរយៈពេល៣០ថ្ងៃ អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំជាថ្មីឡើយ។

២- អ្នកដាក់ពាក្យសុំលិខិតអនុញ្ញាតប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោម៖

ក- សោហ៊ុយដាក់ពាក្យសុំលិខិតអនុញ្ញាតចំនួន ១០០.០០០រៀល (មួយរយពាន់រៀល)

ខ- សោហ៊ុយលិខិតអនុញ្ញាតប្រចាំឆ្នាំចំនួន ២០០.០០០រៀល (ពីររយពាន់រៀល)

គ- ក្នុងរយៈពេល៣០ថ្ងៃមុនលិខិតអនុញ្ញាតអស់សុពលភាព អ្នកកាន់លិខិតអនុញ្ញាតត្រូវដាក់ពាក្យសុំបន្តជាថ្មី។

៣- ចំពោះបុគ្គលដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណ សោហ៊ុយនឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដំណាច់ឆ្នាំ។

៤- អាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតត្រូវតែជាកម្មសិទ្ធិរបស់បុគ្គលដែលធ្វើអាជីវកម្មប្តូរប្រាក់។

៥- ក្នុងករណីមានទីតាំង ឬអាសយដ្ឋានធ្វើប្រតិបត្តិការច្រើនកន្លែង ទីតាំងធ្វើប្រតិបត្តិការនីមួយៗត្រូវតែមានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ហើយមិនត្រូវប្រកបអាជីវកម្មប្តូរប្រាក់នៅទីកន្លែងណាផ្សេងក្រៅពីអាសយដ្ឋាន ឬទីតាំងដែលបានអនុញ្ញាតឡើយ។

៦- រាល់ការផ្លាស់ប្តូរអាសយដ្ឋាន ទីតាំងធ្វើប្រតិបត្តិការ កម្មសិទ្ធិធ្វើអាជីវកម្ម ការបិទអាជីវកម្ម និងបើកទីតាំងថ្មី អាជីវករប្តូរប្រាក់ត្រូវតែជូនដំណឹងភ្លាមជាលាយលក្ខណ៍អក្សរដល់ធនាគារជាតិនៃ

កម្ពុជា។ រាល់ការកែប្រែទាំងនេះ មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការមុនពេលបានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជាឡើយ។

**ប្រការ ៨**.-

១- អ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត៖

ក- ត្រូវលើកយីហោនៅកន្លែងអាជីវកម្មរបស់ខ្លួនដោយដាក់អក្សរ "ប្តូរប្រាក់" និងអាចដាក់បន្ថែមជាភាសាអង់គ្លេស "Authorized Money Changer"

ខ- ត្រូវដាក់បង្ហាញអាជ្ញាប័ណ្ណគ្រប់ពេលវេលាទាំងអស់នៅកន្លែងដែលងាយមើលឃើញនៅក្នុងបរិវេណដែលបានអនុញ្ញាត

គ- ត្រូវដាក់បង្ហាញឱ្យសាធារណជនឃើញច្បាស់ជាប្រចាំនូវតារាងអត្រា ទិញ-លក់ ប្រចាំថ្ងៃរវាងប្រាក់រៀលជាមួយប្រាក់ដុល្លារនិងរវាងប្រាក់ដុល្លារជាមួយនឹងរូបិយប័ណ្ណផ្សេងៗ

ឃ-ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាមុនពេលចាប់ផ្តើមធ្វើអាជីវកម្មប្តូរប្រាក់នៅទីតាំងថ្មី។

២- អ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតត្រូវគោរពតាមក្រមប្រតិបត្តិដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៩**.-

ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត បើអ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត៖

ក- ល្មើសនឹងខ្លឹមសារនៃប្រកាសនិងឧបសម្ព័ន្ធនៃប្រកាសនេះ

ខ- មិនសហការជាមួយធនាគារជាតិនៃកម្ពុជាឬអាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យឬ អង្កេត

គ- បានប្រព្រឹត្តការក្លែងបន្លំនិងធ្វើការបំភ័ន្តដោយចេតនា

ឃ- ធ្វើវិច្ឆេទកម្មកេងយកចំណេញដោយការបំប៉ោងអត្រាប្តូរ

ង-ផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យសាធារណជនមានការយល់ច្រឡំ ឬបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល

ច-ល្មើសនឹងបទបញ្ញាពាក់ព័ន្ធនឹងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ១០**.-

ការខកខានមិនបានអនុវត្តតាមខ្លឹមសារនៃប្រកាសនេះត្រូវទទួលរងទណ្ឌកម្មយោងតាមមាត្រា៧០ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

**ប្រការ ១១**.-

ប្រកាសលេខ ធ៩-៩៨-៣៩៣ ប្រក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ចំពោះអាជីវកម្មប្តូរប្រាក់ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១២**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងខ្លួន។

**ឧបសម្ព័ន្ធ៥**

ធ៧-៩៧-១៤៧ ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

*ធ្វើវិសោធនកម្មដោយច្បាប់ ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ធ៩-៩៨-៤១៤ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៨ ស្តីពី ប្រភពទុនជាប្រាក់បញ្ញើសម្រាប់ប្រើប្រាស់ក្នុងស្រុករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធ៧-០១-១៣៧ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ ធ៧-០៥-៥៤ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៥ ស្តីពី គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាចផ្តល់ឥណទាន ប្រកាស ធ៧-០៦-២១០ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលប្រកាស ស្តីពី សោហ៊ុយបង្កើនដើមទុនសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ ធ៧-០៦-២២៦ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការត្រួតពិនិត្យហានិភ័យនៃឥណទានធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធ៧-០១-១៨៦ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី អចលនទ្រព្យរបស់ធនាគារ ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ និង ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ ប្រកាសលេខ ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ប្រកាសលេខ ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ។*

## ជំពូក១
## អំពីដើមទុន

**ប្រការ ១**.-

ដើមទុនរបស់គ្រឹះស្ថានត្រូវបានកំរិតដូចខាងក្រោម

១.១ : (ផុតកំណត់)

១.២ : (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ជាពិសេសប្រការ ៧ និង ប្រការ ៨)

១.៣ : (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ប្រកាសលេខ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ប្រកាសលេខ ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ និង ប្រកាសលេខ ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០)

១.៤ : (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០)

១.៥ : (ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១០-១៨២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០)

**ប្រការ ២**.-

ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១។

**ប្រការ ៣**.-

ដើមទុនក្នុងលក្ខន្តិកៈរបស់គ្រឹះស្ថានអាចត្រូវសុំបង្កើន ឬបន្ថយបាននៅក្រោមលក្ខខណ្ឌដែលត្រូវ ៖

៣.១ ត្រូវបានជំនួសដោយប្រកាស លេខ ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ និង ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០។

៣.២ ករណីបង្កើន :

(ធ្វើវិសោធនកម្មដោយប្រកាសលេខ ធ៧-០៦-២១០ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦)

រាល់ការបង្កើនដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ជាមុន។

ការបង្កើនដើមទុនត្រូវបង់សោហ៊ុយចំនួន សូន្យក្បៀសសូន្យបីភាគរយ (០,០៣%) លើចំនួនប្រាក់ដែលសុំបង្កើន។

៣.៣ ករណីបន្ថយ : ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ និង ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០។

**ប្រការ ៤**.-

ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១។

**ប្រការ ៥**.-

ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ និងធ៧-០០-០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០។

## ជំពូក២
## អំពីអាជ្ញាប័ណ្ណប្រកបអាជីវកម្ម

**ប្រការ ៦**.- អ្នកបង្កើតគ្រឹះស្ថានត្រូវបំពេញបែបបទជា ៣ ដំណាក់កាល ៖

៦.១ ដំណាក់កាលទី១ : ការផ្តល់ព័ត៌មាន និងណែនាំលក្ខខណ្ឌនៃសំណុំបែបបទ ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០០-០៦ ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ២០០០ ធ៧-០០-០៥ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ និង ធ៧-០០-០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០។

៦.២ ដំណាក់កាលទី២ : ការចេញលិខិតអនុញ្ញាតជាគោលការណ៍

៦.២.១ លិខិតអនុញ្ញាតជាគោលការណ៍ត្រូវបានធនាគារជាតិនៃកម្ពុជាចេញឱ្យបន្ទាប់ពីការសិក្សាសំណុំបែបបទឃើញមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវដើម្បីបង្កលក្ខណៈឱ្យផ្ទេរដើមទុនមកធនាគារជាតិនៃកម្ពុជា ដើម្បីរៀបចំទីស្នាក់ការ និងរៀបចំដំណើរការដោយអនុលោមទៅតាមរាល់លក្ខខណ្ឌដែលមានចែងនៅក្នុងនោះ។

៦.២.២ ក្នុងករណីដែលសាមីគ្រឹះស្ថានកំពុងផ្តើមបង្កើតមិនអាចដំណើរការបាននៅក្នុងកាលកំណត់នៃលិខិតអនុញ្ញាតជាគោលការណ៍នោះទេ ត្រូវរងការផាកពិន័យជាប្រាក់ចំនួន ៥.០០០.០០០.០០ (ប្រាំលាន)

## ជំពូក៤
## អំពីការកាន់កាប់អចលនទ្រព្យ

**ប្រការ៩, ១០ និង១១**.-

ត្រូវបានជំនួសដោយប្រកាស ធ៧-០១-១៨៦ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១។

**ប្រការ ១២**.-

អគ្គនាយកដ្ឋាន អធិការដ្ឋានផ្ទៃក្នុង ខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា មានភារកិច្ចរៀងៗខ្លួនអនុវត្តយ៉ាងម៉ឺងម៉ាត់តាមប្រកាសនេះ។

**ប្រការ ១៣**.-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធ៦**

ធ៧-០៨-១៩៣ ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និង លក្ខខណ្ឌសុំអាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានធនាគារ

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីអប្បបរមា និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណ ចំពោះគ្រឹស្ថាៈធនាគារ។ ធនាគារជាតិនៃកម្ពុជានឹងសិក្សាពីសមត្ថភាពធ្វើប្រតិបត្តិការ របស់បុគ្គលស្នើសុំ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍របស់ខ្លួន ដោយធ្វើយ៉ាងណាឱ្យបានស្របតាមការងារដំរលូននៃប្រព័ន្ធធនាគារ ដើម្បីផ្តល់សុវត្ថិភាពគ្រប់គ្រាន់សម្រាប់សាធារណជន។ ពាក្យស្នើសុំអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារ ដែលមិនត្រឹមត្រូវតាមលក្ខខណ្ឌដែលមានចែងនៅក្នុងប្រកាសនេះ នឹងត្រូវបដិសេធជាលាយលក្ខអក្សរ។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារត្រូវគ្រប់គ្រងដោយបុគ្គលយ៉ាងតិចចំនួនពីររូប ដែលមានភាពសុចរិត និងគុណវុឌ្ឍិ និងមានបទពិសោធន៍សមស្របលើប្រតិបត្តិការធនាគារ។

**ប្រការ ៣**.-

ភាគទុនិកមួយ ឬច្រើន ត្រូវមានភស្តុតាងបង្ហាញថាមានបទពិសោធន៍ក្នុងសកម្មភាពដែលគ្រឹះស្ថានធនាគារមានបំណងធ្វើប្រតិបត្តិការ។

**ប្រការ ៤**.-

គ្រឹះស្ថានធនាគារដែលនឹងត្រូវបង្កើតឡើង ត្រូវមានបុគ្គលិកគ្រប់គ្រាន់ និងមានជំនាញសមស្រប។ ធនធានបច្ចេកទេសរួមទាំងប្រព័ន្ធព័ត៌មានត្រូវមានប្រសិទ្ធភាព និងអាចជឿជាក់បាន ជាពិសេសប្រព័ន្ធសុវត្ថិភាពនៃប្រតិបត្តិការជាមួយសាធារណជន។

**ប្រការ ៥**.-

គ្រឹះស្ថានធនាគារដែលនឹងត្រូវបង្កើតឡើង ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអាចឱ្យគ្រឹះស្ថានធនាគារ ៖

- ធានាបានថាប្រតិបត្តិការ រចនាសម្ព័ន្ធចាត់តាំង នីតិវិធី ប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងការអនុវត្តធុរកិច្ច និងស្តង់ដារជាទូទៅ
- ធានាការប្រតិបត្តិតាមកម្រិតកំណត់ដែលបានដាក់ចេញចំពោះហានិភ័យ ជាពិសេសហានិភ័យសមភាគី ហានិភ័យអត្រាការប្រាក់ និងហានិភ័យអត្រាប្តូរប្រាក់
- ធានាគុណភាពរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

ភាពឋិតថេរផ្នែកហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារក្នុងរយៈពេលច្រើនឆ្នាំខាងមុខ ត្រូវបង្កើតឱ្យបានគ្រប់គ្រាន់តាមរយៈផែនការអាជីវកម្ម ការសិក្សាទីផ្សារ និងការសាកល្បងហិរញ្ញវត្ថុ (financial simulations) រួមទាំង ការធ្វើសេណារីយ៉ូសាកល្បង (stress scenarios) បើចាំបាច់។ ការសាកល្បងហិរញ្ញវត្ថុ ត្រូវមានសូចនាករ ដែលទទួលស្គាល់ជាទូទៅប្រើប្រាស់ក្នុងការវិភាគហិរញ្ញវត្ថុ និង បទដ្ឋានប្រុងប្រយ័ត្ន។

**ប្រការ ៧**.-

មាត្រា ១ នៃប្រកាសលេខ ធ៧-០០-៣៩ ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី ដើមទុនអប្បបរមារបស់ធនាគារពាណិជ្ជ ត្រូវជំនួសដោយប្រការដូចខាងក្រោម ៖

"ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពល យ៉ាងតិចមួយ ជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៥០.០០០.០០០.០០០ រៀល (ហាសិបពាន់លានរៀល)។ ចំពោះធនាគារពាណិជ្ជដែលមានភាគទុនិកជាវិនិយោគិនដែលជា ឯកត្តជន ឬក្រុមហ៊ុនត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ រៀល (មួយរយ ហាសិបពាន់លានរៀល)។"

**ប្រការ ៨**.-

មាត្រា ៤ នៃប្រកាសលេខ ធ៧-០០-០៥ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ ត្រូវជំនួសដោយប្រការដូចខាងក្រោម ៖

"ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយ ជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១០.០០០.០០០.០០០ រៀល (ដប់ពាន់លានរៀល)។ ចំពោះធនាគារឯកទេសដែលមានភាគទុនិកជាវិនិយោគិនដែលជា ឯកត្តជន ឬក្រុមហ៊ុនត្រូវមានដើមទុនអប្បបរមាស្មើនឹង ៣០.០០០.០០០.០០០ រៀល (សាមសិបពាន់លានរៀល)។"

**ប្រការ ៩**.-

នីតិវិធី និងការវាយតម្លៃបន្ថែមលើពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដោយសារាចរណែនាំដោយឡែក។

**ប្រការ ១០**.-

គ្រឹះស្ថានធនាគារដែលមានអាជ្ញាប័ណ្ណ ឬ ទទួលលិខិតអនុញ្ញាតជាគោលការណ៍បើកធនាគារមុនថ្ងៃប្រកាសនេះចូលជាធរមាន ត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ យ៉ាងយឺតបំផុតត្រឹមដំណាច់ឆ្នាំ២០១០។

**ប្រការ ១១**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១២**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធ៧**

ធ៧-០២-៤៩ ប្រ.ក

# ប្រកាស
# ស្តីពី
# ភាតព្វកិច្ចចុះបញ្ជីរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងការសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

ប្រការ ១ នៃប្រកាសលេខធ៧.០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបានលុបចោល និងជំនួសដោយប្រកាសនេះ។

**ប្រការ ២**.-

មីក្រូហិរញ្ញវត្ថុមានន័យថាការផ្តល់សេវាហិរញ្ញវត្ថុដូចជាការផ្តល់ឥណទាន និងទទួលប្រាក់បញ្ញើចំពោះគ្រួសារ ក្រីក្រ គ្រួសារដែលមានចំណូលតិច និងសហគ្រាសធុនតូច។

**ប្រការ ៣**.-

ការចុះបញ្ជីជាកាតព្វកិច្ចរបស់គ្រប់អង្គការក្រៅរដ្ឋាភិបាលសមាគម និងអង្គភាពផ្សេងទៀតដែលធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុហៅថាប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ដែលបានបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោមៈ

ក- សម្រាប់គ្រឹះស្ថានផ្តល់ឥណទាន

- សំពៀតឥណទានត្រូវមានចំនួន ១០០ លានរៀល ឬ ច្រើនជាង

ខ- សម្រាប់គ្រឹះស្ថានកេណ្ឌប្រមូលប្រាក់សញ្ញើ

- ប្រាក់សញ្ញើយដោយស្ម័គ្រចិត្តដែលប្រមូលបានពីសាធារណជនទូទៅមានចំនួន ១លានរៀល ឬ ច្រើនជាង
- ឬចំនួនអ្នកផ្ញើប្រាក់ ១០០ នាក់ ឬច្រើនជាង។

**ប្រការ ៤**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិ និងច្បាប់ជាធរមាន ហើយត្រូវបំពេញតាមស្តង់ដារនិងលក្ខណៈវិនិច្ឆ័យ ដែលធនាគារជាតិនៃកម្ពុជាបានកំណត់ក្នុងន័យអភិបាលកិច្ចល្អ តម្លាភាព និងការគ្រប់គ្រងប្រកបដោយសមត្ថភាពនិងដោយស្មោះត្រង់។

**ប្រការ ៥**.-

ធនាគារជាតិនៃកម្ពុជាផ្តល់វិញ្ញាបនបត្រ័បញ្ជាក់ការចុះបញ្ជី ដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានបំពេញតាមស្តង់ដារ និងលក្ខណៈវិនិច្ឆ័យ ដោយមានផ្តល់ឯកសារនិងព័ត៌មានដែលតម្រូវ ។ វិញ្ញាបនប័ត្រនេះអាចត្រូវបានដកហូត មកវិញ ហើយការចុះបញ្ជីត្រូវលុបចោលបើប្រតិបត្តិករទាំងនោះពុំអនុវត្តតាមលក្ខខណ្ឌដែលធនាគារជាតិនៃកម្ពុជា បានដាក់ចេញ។

**ប្រការ ៦**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលត្រូវបានធនាគារជាតិនៃកម្ពុជា បដិសេធ ឬលុបចោលការចុះបញ្ជីត្រូវបញ្ឈប់សកម្មភាពរបស់ខ្លួនទាំងអស់ក្នុងរយៈពេល៣ខែ ក្រោយពីបានទទួលសេចក្តីជូនដំណឹងអំពីការសំរេចរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៧**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី ត្រូវផ្តល់របាយការណ៍ស្តីពីសកម្មភាព និងចំណាត់ការរបស់ខ្លួនឱ្យបានទៀងទាត់តាមពេលវេលាកំណត់របស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៨**.-

ការសុំអាជ្ញាប័ណ្ណជាកាតព្វកិច្ចរបស់គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម ៖

ក- សម្រាប់គ្រឹះស្ថានផ្តល់ឥណទាន

- សំពៀតឥណទាន មានចំនួន ១,០០០ លានរៀល ឬច្រើនជាង
- ឬមានអ្នកខ្ចី ១,០០០ នាក់ ឬច្រើនជាង

ខ- សម្រាប់គ្រឹះស្ថានកេណ្ឌប្រមូលប្រាក់សញ្ញើ

- ប្រាក់សញ្ញើដោយស្ម័គ្រចិត្តដែលប្រមូលបានពីសាធារណជនទូទៅមានចំនួន ១០០ លានរៀល ឬ ច្រើនជាង
- ឬមានចំនួនអ្នកផ្ញើប្រាក់ ១,០០០ នាក់ ឬច្រើនជាង ។

**ប្រការ ៩**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានកាតព្វកិច្ចសុំអាជ្ញាប័ណ្ណ ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២។ គ្រឹះស្ថានដែលពុំបានមកសុំអាជ្ញាប័ណ្ណត្រូវបន្ថយទំហំសកម្មភាពប្រតិបត្តិការ ឱ្យមកត្រឹមលក្ខខណ្ឌត្រូវចុះបញ្ជីតាមប្រការ ៣ ដល់ប្រការ ៧ ខាងលើ។

**ប្រការ ១០**.-

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុឬគ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ១១**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១២**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធ៨**

ធ៩-៩៨-៤១១ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ តាមរយៈធនាគារជាតិនៃកម្ពុជា

**ប្រការ ១**.-

បញ្ឈប់ការផ្តល់ទិដ្ឋាការឱ្យធនាគារពាណិជ្ជនាំចេញនូវសាច់ប្រាក់ជាដុល្លារអាមេរិកតទៅទៀត ដោយអនុញ្ញាតឱ្យធ្វើការផ្ទេរប្រាក់តាមរយៈធនាគារជាតិនៃកម្ពុជា។

**ប្រការ ២**.-

ធនាគារពាណិជ្ជដែលមានបំណងផ្ទេរសាច់ប្រាក់ដុល្លារចេញ ត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់)។

**ប្រការ ៣**.-

សោហ៊ុយសេវាក្នុងប្រតិបត្តិការផ្ទេរប្រាក់ នឹងត្រូវកំណត់ទៅតាមកាលៈទេសៈតម្រូវការសាច់ប្រាក់ដុល្លារអាស្រ័យដោយអគ្គនាយកដ្ឋានធនាគារជាតិនៃកម្ពុជា ជាអ្នកសំរេចចេញសេចក្តីជូនដំណឹងឱ្យអនុវត្តជាក់ស្តែងប្រចាំគ្រានីមួយៗ។

**ប្រការ ៤**.-

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ជាពិសេសប្រកាសលេខ ធ៧-៩៨-៣៦៦ ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ និងប្រកាស លេខធ៩-៩៨-៣៨៦ ប្រក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាមានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះ។

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធ៩**

ធ៩-០៩-២៦២ ប្រ.ក

**ប្រកាស**
**ស្តីពី**
**ការផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុ**
**និងត្បូងថ្មមានតម្លៃ**

**ប្រការ ១**.-

ផ្តល់អាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនធ្វើអាជីវកម្ម នាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ តាមលក្ខខណ្ឌដូចខាងក្រោម:

១- អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណដើម្បីប្រកបអាជីវកម្ម នាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ ត្រូវចុះបញ្ជីជាក្រុមហ៊ុនពាណិជ្ជកម្ម។

២-ពាក្យស្នើសុំរបស់ក្រុមហ៊ុនត្រូវភ្ជាប់ជាមួយនូវ :

ក) លិខិតបញ្ជាក់ចុះបញ្ជីពាណិជ្ជកម្ម

ខ) ឈ្មោះផ្លូវការរបស់តំណាងក្រុមហ៊ុន

គ) អាសយដ្ឋានរស់នៅ និងអាសយដ្ឋានប្រកបអាជីវកម្ម

ឃ) សម្មតិនាម ឬឈ្មោះពាណិជ្ជកម្ម

ង) លក្ខន្តិកៈក្រុមហ៊ុន

ច) លិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចស្តីពីការអនុញ្ញាតទីតាំងប្រកបអាជីវកម្ម

ឆ) ឯកសារផ្សេងៗទៀតតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា

៣- អ្នកដាក់ពាក្យស្នើសុំត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួន ១.០០០.០០០រៀល (មួយលានរៀល) និងសោយហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំនួន២.០០០.០០០ រៀល (ពីរលានរៀល)។

**ប្រការ ២**.-

១- ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា មានសិទ្ធធ្វើតែអាជីវកម្មទិញ-លក់ និងនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ប៉ុណ្ណោះ។

២- ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណ ត្រូវប្រកបអាជីវកម្មនៅទីតាំងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ និងត្រូវដាក់បង្ហាញជាសាធារណៈនូវឈ្មោះក្រុមហ៊ុន ឬផ្លាកយីហោរបស់ក្រុមហ៊ុន។

៣- រាល់ការនាំចេញ-នាំចូល លោហធាតុនិងត្បូងថ្មមានតម្លៃ ត្រូវតែស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជានិងត្រូវបង់សាហ៊ុយ ចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) ក្នុងមួយប្រតិបត្តិការ។

**ប្រការ ៣**.-

អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃអាចត្រូវបានដកហូតវិញក្នុងករណីដែលមានការប្រព្រឹត្តល្មើសនឹងច្បាប់ និង បទប្បញ្ញត្តិនានា។

**ប្រការ ៤**.-

ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាព ឬប្តូរទីតាំងធ្វើអាជីវកម្ម ក្រុមហ៊ុនសាមីត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយភ្ជាប់នូវសំណុំឯកសារពាក់ព័ន្ធក្នុងរយៈពេលយ៉ាងយូរបំផុត ៣០ថ្ងៃជាមុន ដើម្បីជូនដំណឹងនិងសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥**.-

បុគ្គលណា ដែលប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃ ដោយគ្មានអាជ្ញាប័ណ្ណ ឬគ្មានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា នឹងត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៧០ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦**.-

ប្រកាសលេខ ធ៩-៩៤-០១ ប្រក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៤ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវអនុវត្តភារកិច្ចតាមប្រកាសនេះរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធ១០**

ធ៧-០១-១៣៦ ប្រ.ក

# ប្រកាស
# ស្តីពី
# ប្រាក់តំកល់ធានាលើដើមទុន

ធ្វើវិសោធនកម្មដោយប្រកាសលេខ ធ៥-០៩-០១១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពី ការកំណត់អត្រាការប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ។

**ប្រការ ១**.-

កំណត់ប្រាក់តំកល់ធានាលើដើមទុនដែលត្រូវដាក់ធ្វើជាអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងមាត្រា១៦នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន១០ភាគរយនៃដើមទុន។

**ប្រការ ២**.-(ផុតកំណត់)

**ប្រការ ៣**.-

(ត្រូវបានជំនួសដោយប្រកាសលេខ ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨)

គ្រឹះស្ថានធនាគារដែលមានអាជ្ញាប័ណ្ណ ឬ ទទួលលិខិតអនុញ្ញាតជាគោលការណ៍បើកធនាគារមុនថ្ងៃប្រកាសនេះចូលជាធរមាន ត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ យ៉ាងយឺតបំផុតត្រឹមដំណាច់ឆ្នាំ២០១០។

**ប្រការ ៤**.-

ប្រាក់តំកល់ធានាលើដើមទុនអាចអនុវត្តជាប្រាក់រៀល ឬជាប្រាក់ដុល្លារអាមេរិក។ បន្ទាប់ពីបានបង់ប្រាក់តំកល់ធានាលើដើមទុន ធនាគារសាមីមិនអាចផ្លាស់ប្តូរការជ្រើសរើសនេះបានទេ។ អត្រាប្តូរប្រាក់ប្រើប្រាស់សម្រាប់ការគណនាប្រាក់តំកល់ធានាលើដើមទុននេះ គឺជាអត្រាប្តូរប្រាក់ផ្លូវការនៅថ្ងៃដែលមូលនិធិត្រូវបានចុះឥណទានគណនីតំកល់ធានានៅធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥**.-

ប្រាក់តំកល់ធានាលើដើមទុនជាប្រាក់រៀល ទទួលបានកំរៃការប្រាក់មួយភាគពីរនៃអត្រាការប្រាក់បុនហិរញ្ញប្បទានក្នុងរយៈពេល ៦ ខែម្តងជាធរមាន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

(ធ្វើវិសោធនកម្មដោយប្រកាសលេខ ធ៥-០៩-០១១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩)

អត្រាការប្រាក់លើប្រាក់តម្កល់ធានាលើដើមទុន (Capital Guarantee) ត្រូវបានផ្តល់ជូនតាមអត្រា ១/៤ នៃ SIBOR គិតលើមូលដ្ឋាន ៦ ខែ។

**ប្រការ ៦**.-

ប្រាក់តំកល់ធានាលើដើមទុនត្រូវបានសងត្រលប់ទៅវិញតែក្នុងករណីមានការជំរះបញ្ជីធនាគារ និងស្របតាមលំដាប់អាទិភាពដែលមានចែងនៅមាត្រា៦៤ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៧**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ឧបសម្ព័ន្ធ១១**

ធ៩-០៩-២៣០ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់

## សម្រេច

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងគ្រប់គ្រងរាល់អាជីវកម្មប្តូរប្រាក់ ដែលកំពុងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២**.-

និយមន័យ៖

១- **រូបិយវត្ថុ** សំដៅដល់ប្រាក់រៀលដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ។

២- **រូបិយប័ណ្ណ** សំដៅដល់រូបិយវត្ថុបរទេសឬមធ្យោបាយទូទាត់ជារូបិយវត្ថុបរទេស ។

៣-**អាជីវកម្មប្តូរប្រាក់** សំដៅដល់ការ ទិញ-លក់ ប្រាក់រៀលជាមួយនឹងរូបិយប័ណ្ណនានា ឬការទិញ-លក់រូបិយប័ណ្ណមួយជាមួយនឹងរូបិយប័ណ្ណផ្សេងៗទៀត។

**ប្រការ ៣**.-

ប្រតិបត្តិការដែលជាសកម្មភាពប្តូរប្រាក់ រួមមាន៖

- ទិញ និងលក់ក្រដាសប្រាក់ជារូបិយប័ណ្ណ
- ទិញមូលប្បទានប័ត្រទេសចរណ៍ ។

**ប្រការ ៤**.-

១- បុគ្គលដែលមានបំណងធ្វើអាជីវកម្មប្តូរប្រាក់ត្រូវតែសុំអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ។

២- បុគ្គលដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្មប្តូរប្រាក់ត្រូវមានកាតព្វកិច្ច និងសិទ្ធិ ដូចតទៅ៖

ក- ត្រូវមានដើមទុនអប្បបរមាចំនួន ៨០.០០០.០០០រៀល (ប៉ែតសិបលានរៀល) តម្កល់នៅធនាគារជាតិនៃកម្ពុជាជាអចិន្ត្រៃយ៍ដោយទទួលកម្រៃការប្រាក់ ដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា

ខ- មានសិទ្ធិចូលរួមក្នុងការដេញថ្លៃទិញ-លក់ប្រាក់រៀលនៅធនាគារជាតិនៃកម្ពុជា

គ-មានសិទ្ធិចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ធនាគារជាតិនៃកម្ពុជា លើការសម្គាល់រូបិយប័ណ្ណក្លែងក្លាយ។

**ប្រការ ៥**.-

១- ពាក្យសុំអាជ្ញាប័ណ្ណត្រូវមានបញ្ជាក់ឬមានភ្ជាប់ជាមួយនូវ៖

ក- នាមករណ៍យីហោ និងអាសយដ្ឋានធ្វើអាជីវកម្ម

ខ- លិខិតបង់ប្រាក់តម្កល់ដើមទុន

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

២- ពាក្យសុំលិខិតអនុញ្ញាតត្រូវមានបញ្ជាក់ឬមានភ្ជាប់ជាមួយនូវ៖

ក- ឈ្មោះ និងទីលំនៅអចិន្ត្រៃយ៍របស់អ្នកដាក់ពាក្យសុំ

ខ- ទីតាំងធ្វើអាជីវកម្មដោយមានបញ្ជាក់ពីអាជ្ញាធរខណ្ឌ ឬស្រុក និង

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦**.-

១-ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យលើពាក្យស្នើសុំក្នុងរយៈពេល៤៥ថ្ងៃគិតពីថ្ងៃបានទទួលពាក្យស្នើសុំពេញលេញហើយអាចចេញអាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតឬបដិសេធពាក្យស្នើសុំនោះ។

២- អាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតមិនអាចផ្ទេរឬប្តូរឈ្មោះបានឡើយ។

៣- អាជ្ញាប័ណ្ណមានសុពលភាពរយៈពេល៣ឆ្នាំគិតចាប់ពីថ្ងៃចេញអាជ្ញាប័ណ្ណ។

៤- លិខិតអនុញ្ញាតមានសុពលភាពរយៈពេល១ឆ្នាំគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត។

**ប្រការ ៧**.-

១- អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោម៖

ក- សោហ៊ុយដាក់ពាក្យសុំអាជ្ញាប័ណ្ណចំនួន ១០០.០០០(មួយរយពាន់រៀល)។

ខ- សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួន ១.២០០.០០០រៀល (មួយលានពីររយពាន់រៀល) ដែលត្រូវបង់នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។

គ- ក្នុងរយៈពេល៣០ថ្ងៃមុនអាជ្ញាប័ណ្ណអស់សុពលភាពអ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណជាថ្មី។

ឃ-ក្នុងករណីមិនបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណទាន់ពេលវេលាអ្នកកាន់អាជ្ញាប័ណ្ណនឹងត្រូវរងការផាកពិន័យជាប្រាក់ចំនួន២០.០០០រៀល (ម្ភៃពាន់រៀល)ក្នុងមួយថ្ងៃ។ ប្រសិនបើអាជ្ញាប័ណ្ណអស់សុពលភាពរយៈពេល៣០ថ្ងៃ អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំជាថ្មីឡើយ។

២- អ្នកដាក់ពាក្យសុំលិខិតអនុញ្ញាតប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោម៖

ក- សោហ៊ុយដាក់ពាក្យសុំលិខិតអនុញ្ញាតចំនួន ១០០.០០០រៀល (មួយរយពាន់រៀល)

ខ- សោហ៊ុយលិខិតអនុញ្ញាតប្រចាំឆ្នាំចំនួន ២០០.០០០រៀល (ពីររយពាន់រៀល)

គ- ក្នុងរយៈពេល៣០ថ្ងៃមុនលិខិតអនុញ្ញាតអស់សុពលភាព អ្នកកាន់លិខិតអនុញ្ញាតត្រូវដាក់ពាក្យសុំបន្តជាថ្មី។

៣- ចំពោះបុគ្គលដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណ សោហ៊ុយនឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដំណាច់ឆ្នាំ។

៤- អាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតត្រូវតែជាកម្មសិទ្ធិរបស់បុគ្គលដែលធ្វើអាជីវកម្មប្តូរប្រាក់។

៥- ក្នុងករណីមានទីតាំង ឬអាសយដ្ឋានធ្វើប្រតិបត្តិការច្រើនកន្លែង ទីតាំងធ្វើប្រតិបត្តិការនីមួយៗត្រូវតែមានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ហើយមិនត្រូវប្រកបអាជីវកម្មប្តូរប្រាក់នៅទីកន្លែងណាផ្សេងក្រៅពីអាសយដ្ឋាន ឬទីតាំងដែលបានអនុញ្ញាតឡើយ។

៦- រាល់ការផ្លាស់ប្តូរអាសយដ្ឋាន ទីតាំងធ្វើប្រតិបត្តិការ កម្មសិទ្ធិធ្វើអាជីវកម្ម ការបិទអាជីវកម្ម និងបើកទីតាំងថ្មី អាជីវករប្តូរប្រាក់ត្រូវតែជូនដំណឹងភ្លាមជាលាយលក្ខណ៍អក្សរដល់ធនាគារជាតិនៃ

**ឧបសម្ព័ន្ធ**

ធ៧-០០-០៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ

ធ្វើវិសោធនកម្មដោយប្រកាស ធ៧-០៦-២០៨ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពី ការកែសំរួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស, ធ៧-០៤-២០៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៤ ស្តីពីសោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ធ៧-០១-១៨៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី ការផ្ទេរភាគហ៊ុនរបស់ធនាគារ, ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ។

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ធនាគារឯកទេសឥណទានជនបទ តទៅនេះហៅថាធនាគារឯកទេស ដូចមានកំណត់និយមន័យក្នុងជំពូកទី១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ អនុលោមតាមមាត្រា ១៤ នៃច្បាប់ដដែលនេះ។

**ប្រការ ២.-**

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើតែប្រតិបត្តិការណាដែលមានបញ្ជាក់ច្បាស់តាមខ្លឹមសារនៃលិខិតអនុញ្ញាត។

**ប្រការ ៣.-**

អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណសម្រាប់ធនាគារឯកទេស ត្រូវប្រកាន់យកនូវរូបភាពគតិយុត្តណាមួយក្នុងចំណោមរូបភាពគតិយុត្តដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៤.-**

(ជំនួសដោយ ប្រកាស ធ៧-០៨-១៩៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨)

ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១០.០០០.០០០.០០០ រៀល (ដប់ពាន់លានរៀល)។ ចំពោះធនាគារ ឯកទេសដែលមានភាគទុនិកជាវិនិយោគិនដែលជាឯកត្តជន ឬក្រុមហ៊ុនត្រូវមានដើមទុនអប្បបរមាស្មើនឹង ៣០.០០០.០០០.០០០ រៀល (សាមសិបពាន់លានរៀល)។

នីតិវិធី និងការវាយតម្លៃបន្ថែមលើពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដោយសារាចរណែនាំដោយឡែក។

គ្រឹះស្ថានធនាគារដែលមានអាជ្ញាប័ណ្ណ ឬទទួលលិខិតអនុញ្ញាតជាគោលការណ៍បើកធនាគារមុនថ្ងៃ ប្រកាសនេះចូលជាធរមាន ត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ យ៉ាងយឺតបំផុតត្រឹមដំណាច់ឆ្នាំ២០១០។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ

**ប្រការ ៥.-**

ពាក្យសុំអាជ្ញាប័ណ្ណ ត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការ ឬជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ) ស្របតាមបញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ ៖

ក- នាម ឬនាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលដែលបានចុះបញ្ជី

គ- រូបភាពគតិយុត្តនិងលក្ខន្តិកៈ ឬឯកសារបង្កើតផ្សេងៗទៀត

ឃ-ប្រភេទមូលប័ត្រតំណាងឱ្យដើមទុន។ ចំណងទាក់ទងរវាងការកាន់កាប់មូលប័ត្រទាំងនោះនិងការអនុវត្តន៍សិទ្ធិបោះឆ្នោត

ង- ចំនួនដើមទុនផ្ទាល់ដែលបានអនុញ្ញាតនិងដែលបានបង់

ច- ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោតនិង កិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកៈដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ

ឆ- ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះត្រូវផ្តល់ព័ត៌មានដូចមានរៀបរាប់ក្នុងប្រការ ៦ នៃប្រកាសនេះ

ជ- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំដោយមានប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ធនាគារឯកទេស។ អ្នកចាត់ការដែលត្រូវបានតែងតាំងដោយអ្នកមានសមត្ថកិច្ចត្រូវបំពេញជីវប្រវត្តិ និងសំនួរដូចមានក្នុងឧបសម្ព័ន្ធទី២ ហើយ ត្រូវផ្តល់នូវលិខិតថ្កោលទោស

ឈ-អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល និងដោយបន្ថែមពីលើព័ត៌មានខាងលើត្រូវមានជីវប្រវត្តិព្រមទាំងត្រូវមានរបាយការណ៍បញ្ជាក់ថា គ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានបទពិសោធន៍ខាងឥណទានយ៉ាងតិចបំផុតបីឆ្នាំ (៣ឆ្នាំ)

ញ- ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណគឺជាអង្គភាពដែលបានបង្កើតរួចហើយត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការដែលមានការបញ្ជាក់ពីស្នងការគណនីសម្រាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ(៣ឆ្នាំ)ចុងក្រោយ

ដ - ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ(៣ឆ្នាំ)ទៅមុខ ÷

- ទំហំនៃការឱ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុងឬក្រៅតារាងតុល្យការនិងសេវាផ្សេងៗទៀតដែលត្រូវផ្តល់ឱ្យអតិថិជនឬសមាជិក (ចំពោះឥណទាន ប្រភេទ ទម្រង់

គោលបំណង ខ្លឹមសារ និងល័ក្ខខណ្ឌចំបងៗ ផលកំរៃដែលទទួលបានប្រចាំឆ្នាំ និង ទឹកប្រាក់មិនទាន់សង)

- ប្រភេទអតិថិជនដែលធនាគារឯកទេសមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក ÷ មូលនិធិផ្ទាល់ ប្រាក់ឧបត្ថម្ភ បំណុល-បន្ទាប់បន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចី ជាដើម ហើយបើចាំបាច់ ត្រូវបញ្ជាក់ច្បាស់ពីដើមកំណើត និងកម្មសិទ្ធិនៃធនធានទាំងនេះក្នុងករណីមិនប្រាកដ(បំណុលបន្ទាប់បន្សំជាដើម)
- ចំនួនប្រហាក់ប្រហែលនៃនិយោជិកក្នុងរយៈពេលបីឆ្នាំ(៣ឆ្នាំ)ខាងមុខ និងបញ្ជីបើកបៀវត្ស ដោយរាយលំអិតតាមប្រភេទបុគ្គលិក
- ទីតាំងសាខាដែលមានស្រាប់ឬដែលគ្រោងឱ្យមាន
- ការចាត់តាំងនិងធនធាន ដែលបានគ្រោងទុក ពិសេសចំពោះទម្រង់ការគណនេយ្យ និងឧបករណ៍ កុំព្យូទ័រ
- តារាងតុល្យការនិងការព្យាករណ៍គណនីខាត-ចំណេញសម្រាប់ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ។ ត្រូវព្យាករណ៍កំរិតអនុបាតប្រុងប្រយ័ត្នចំបងៗ(ដូចបានកំណត់ដោយធនាគារជាតិនៃកម្ពុជា) នៅខាងចុងការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ)ខាងមុខ

ឋ- ការត្រួតពិនិត្យផ្ទៃក្នុង ÷

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលបានជ្រើសរើសពីបញ្ជីប្រតិស្រុតិ
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឱ្យស្នងការគណនីឯករាជ្យនោះ។

**ប្រការ ៦.-**

ភាគទុនិកដែលកាន់កាប់ប្រាំភាគរយ(៥%) ឬ លើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកស្នើសុំ ត្រូវផ្តល់ព័ត៌មានដូចតទៅ ÷

ក- អត្តសញ្ញាណរបស់ភាគទុនិកៈ ÷

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋានទីស្នាក់ការកណ្តាល និងលក្ខន្តិកៈ។

ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់ នាម គោត្តនាម ថ្ងៃខែឆ្នាំនិងទីកន្លែងកំណើត សញ្ជាតិ និងលំនៅដ្ឋាន។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេ។ ត្រូវប្រាប់ថា តើភាគទុនិកៈជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ។ បើមែនត្រូវធានាថា សមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទេ

ខ- បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត។ រៀបរាប់លំអិតពីការសំរបសំរួលខាងគតិយុត្តនិងខាងហិរញ្ញវត្ថុ ចំពោះការទទួលយកមូលប័ត្រ។ បង្ហាញថា តើសកម្មភាពប្រតិបត្តិការស្ថិតនៅក្រោមចំណុះ